**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

University Royale de Droit et des Sciences Economies

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្ន ចំពោះទ្រព្យ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ កញ្ញា **នី សុជា**

សាស្ត្រាចារ្យណែនាំ៖

លោក **ញឹក ខុឌ្ឍី**



ថ្នាក់បរិញ្ញាបត្រ៖ **នីតិសាស្ត្រ**

ជំនាន់៖ ២២

ឆ្នាំសិក្សា៖ ២០១៨

ឆ្នាំសរសេរសារណា៖ ២០២២

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **នី សុជា** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ក្រុម៤៨៦ ក្នុងឆ្នាំសិក្សា ២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ៖

-**លោកឪពុក អ្នកម្តាយ** ដែលបានបង្កើតរូបកាយកូនមករហូតមានជីវិតរស់នៅក្នុងសង្គមដូចពេលនេះ លោកអ្នកមានគុណទាំងទ្វេ បានផ្តល់ក្តីស្រលាញ់ដែលមិនចេះសាបសូន្យលះបង់គ្រប់បែបយ៉ាងធ្វើយ៉ាងណាឱ្យកូនទទួលបានអាហារហូបចុក ការអប់រំទូន្មានប្រៀបប្រដៅ ជាពិសេសបានបញ្ជូនកូនឱ្យបានចូលរៀនតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រនេះ ដើម្បីឱ្យកូនទទួលបានចំណេះដឹង និងយកសមត្ថភាពនោះទៅប្រកបរបរចិញ្ចឹមជីវិតខ្លួនឯង និងក្រុមគ្រួសារ និងក្លាយជាធនធានមនុស្សដ៏ល្អសង្គមនៅក្នុងជួយអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើន គុណយ៉ាងលើសលុបនេះ និងវិសេសវិសាលថ្លៃថ្លាបំផុតកូនមិនអាចសងអស់ឡើយ។ លោកទាំងទ្វេជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូបគ្មានថ្ងៃកូនអាចបំភ្លេចឡើយ។

-**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់ឱកាសដល់នាងខ្ញុំបានចូលសិក្សាក៏ដូចជាបានក្រេបជញ្ជក់យកចំណេះដឹង ជំនាញ កសាងសមត្ថភាពតាមរយៈការបង្រៀន ការចែករំលែកបទពិសោធន៍ ជាពិសេសបានជំរុញលើកទឹកនាងខ្ញុំឱ្យខិតខំរៀនសូត្រ និងជួយតម្រង់ទិសក្នុងការជ្រើសរើសជំនាញដែលខ្លួនស្រលាញ់ស្របតាមទីផ្សារការងារកំពុងមានតម្រូវការ និងមានពេលខ្លះ លោក/អ្នកគ្រូ បានអនុគ្រោះដល់និស្សិតដែលមានកំហុសក្នុងវិន័យសិក្សាផងក៏មាន។

-ជាពិសេសលោកសាស្ត្រាចារ្យ **ញឹក ឧុត្តី** ដែលទទួលបន្ទុកដឹកនាំធ្វើសារណារបស់នាងខ្ញុំ លោកបានចំណាយកម្លាំងកាយចិត្ត ស្មារតី ពេលវេលា និងយកចិត្តទុកដាក់ ណែនាំ និងចង្អុលបង្ហាញដោយផ្ទាល់ ក៏ដូចជាបានផ្តល់នូវគំនិតល្អៗ ត្រួតពិនិត្យ កែលម្អជាច្រើនលើក ជាច្រើនសារ និងជំរុញឱ្យនាងខ្ញុំខំសិក្សាស្រាវស្រាវ សរសេរចងក្រងនូវអត្ថបទសារណាមួយនេះឡើងឱ្យបានល្អប្រសើរ ដើម្បីប្រាកដថានាងខ្ញុំទទួលបាននូវសមិទ្ធផលស្រាវជ្រាវដ៏មានគុណភាពគុណតម្លៃ និងការទទួលស្គាល់ និងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ជាចុងបញ្ចប់ នាងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយ និងប្រសិទ្ធពរជ័យសិរីបវរជូនដល់ **លោកឪពុក អ្នកម្តាយ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ** តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រ និងមិត្តរួមជំនាន់ទាំងអស់ សូមជួបប្រទះតែព្រះពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សាអស់រយៈជិតពេល ០៤ឆ្នាំ ជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក ក្នុងឆ្នាំបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះបានជំរុញទឹកចិត្តនាងខ្ញុំ ក្នុងការសិក្សាស្វែងយល់ស្រាវជ្រាវ និងចាប់ផ្ដើមសរសេរនូវសារណាមួយនេះរហូតបានចងក្រងជាសៀវភៅមួយនេះឡើងក្រោមចំណងជើងថា “**នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យ**” ។

ការជ្រើសរើសប្រធានបទសារណា “**នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យ**” នេះមកធ្វើការស្រាវជ្រាវមិនមែនជារឿងចៃដន្យនោះទេ ប៉ុន្តែដោយសារមើលឃើញពីទំនាក់ទំនងរបស់មនុស្សនៅក្នុងសង្គមមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ការប្រាស័យទាក់ទងគ្នាក្នុងការធ្វើពាណិជ្ជកម្ម សកម្មភាពក្នុងការផ្ដល់ជាប្រាក់កម្ចី និងសកម្មភាពផ្សេងៗ ដែលទាមទារឱ្យច្បាប់ត្រូវបង្កើតរបបមួយ ដើម្បីទប់ស្កាត់រាល់សកម្មភាពឯកជនណាដែលអាចកើតមានបញ្ហាស្មុគស្មាញ និងធ្វើឱ្យខាតបង់ប្រយោជន៍របស់ភាគីណាមួយដែលកើតឡើងមកពីការមិនគោរពកាតព្វកិច្ចរបស់ភាគីណាមួយ។ ដើម្បីការពារសិទ្ធិរបស់ភាគី និងផ្ដល់យុត្តិធម៌ “**នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យ**” គឺជានីតិវិធីមួយនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលបានផ្ដល់ប្រយោជន៍ដល់បុគ្គលឯកជនទាំងឡាយណាអាចជ្រើសរើសយកនីតិវិធីនេះនូវក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបានដោយប្រើរយៈពេលឆាប់រហ័ស ។

គោលបំណងនៃកិច្ចស្រាវជ្រាវនេះ គឺចង់បង្ហាញពីដំណាក់កាលនីមួយៗ និងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដែលស្របទៅនឹងភាពរីកចម្រើនរបស់សង្គមនាពេលបច្ចុប្បន្ន ជាពិសេសនីតិវិធីការចាត់ចែងរក្សាការពារដែលផ្ដោតសំខាន់លើខ្លឹមសារនីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលវាមានស្មុគស្មាញពិបាកនឹងយល់ពីដំណើរការផ្ដើមនីតិវិធីរហូតដល់ការអនុវត្តជាក់ស្ដែងដែលតម្រូវឱ្យមានសិក្សាស្វែងយល់ឱ្យកាន់តែលម្អិត។

នាងខ្ញុំសង្ឃឹមថាស្នាដៃនេះ នឹងចូលរួមចំណែកក្នុងចែករំលែកនូវចំណេះដឹងពីការខិតខំសិក្សាស្រាវជ្រាវនូវឯកសារច្បាប់នានា និងការសាកសួរពីរាមច្បងជាអ្នកអនុវត្តច្បាប់ផ្ទាល់ដើម្បីច្បងក្រងឡើងធ្វើជាប្រយោជន៍ដល់អ្នកនិស្សិតទាំងឡាយជាពិសេសផ្នែកនីតិសាស្ត្រ ។

ចុងក្រោយនាងខ្ញុំសូមខន្តីអភ័យទុកជាមុន បើទោះបីជាមានការពិនិត្យយ៉ាងម៉ត់ចត់រួចហើយ ក៏នៅតែមានកំហុសឆ្គងពាក្យពេជន៍ អក្ខរាវិរុទ្ធមួយចំនួន ឬ រាល់ចំណុច ខ្វះខាតទាំងឡាយដែលអាចកើតមានឡើងដោយអចេតនា នាងខ្ញុំនឹងរីករាយទទួលយកនៅការិះគុណ ក្នុងន័យស្ថាបនាដើម្បីឱ្យសារណាមួយនេះកាន់តែមានភាពល្អប្រសើរ ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

៣.ចំណោទបញ្ហាការស្រាវជ្រាវ ........ ២

៤.សារៈសំខាន់នៃការជ្រើសរើសប្រធានបទ ........ ២

៥.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២

**ជំពូកទី១**

**សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្ន**

**ផ្នែកទី១ ការរឹបអូសជាបណ្តោះអាសន្ន** ........ ៤

**កថាភាគទី១. មូលហេតុនៃការរឹបអូសជាបណ្តោះអាសន្ន** ........ ៥

**កថាភាគទី២. កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន** ........ ៥

១. ចលនវត្ថុ ........ ៥

២. អចលនវត្ថុ ........ ៦

៣. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ........ ៦

៤. នាវា ........ ៨

**កថាភាគទី៣. លក្ខណៈពិសេសនៃការរឹបអូសជាបណ្តោះអាសន្ន** ........ ៩

១. លក្ខណៈបណ្តោះអាសន្ន ........ ៩

២. លក្ខណៈបន្ទាន់បង្ខំ ........ ៩

៣. លក្ខណៈបន្ទាប់បន្សំ ........ ១០

**ផ្នែកទី២. តុលាការដែលមានសមត្ថកិច្ចចំពោះការរឹបអូសជាបណ្តោះអាសន្ន** ........ ១១

**កថាភាគទី១. តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី** ........ ១១

**កថាភាគទី២.តុលាការមានសមត្ថកិច្ចនៅទីកន្លែងដែលវត្ថុនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្នស្ថិតនៅ** ........ ១២

**ផ្នែកទី៣ នីតិវិធីនៃការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន** ..... ១២

**កថាភាគទី១. ការដាក់ពាក្យសុំ** ........ ១២
១. ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ........ ១៣
២. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ........ ១៤
៣. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ........ ១៥
៤. ភាពចាំបាច់នៃការរក្សាការពារ ........ ១៥
៥. ភស្តុតាងតាមអង្គហេតុនីមួយៗ ........ ១៦
៦. ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំ ........ ១៧
**កថាភាគីទី២. សោហ៊ុយនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ........ ១៨
១. ពន្ធដាក់ពាក្យសុំ ........ ១៨
២. ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ........ ១៨
៣. បន្ទុកនៃប្រាក់ប្រដាប់ក្ដី ........ ១៨
**កថាភាគីទី៣ នីតិវិធីនៃការពិនិត្យពាក្យសុំ និងការវិនិច្ឆ័យ** ........ ១៩
១. នីតិវិធីនៃការពិនិត្យពាក្យសុំ ........ ១៩
២. ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ........ ២០

## ជំពូកទី២

## ប្រភេទដីកាសម្រេច និងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

**ផ្នែកទី១ ដីកាសម្រេចរក្សាការពារ** ........ ២១
**ផ្នែកទី២. ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ........ ២១
**កថាភាគទី១. ចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ........ ២១
១. ភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដី ........ ២១
២. ការសរសេរបញ្ជាក់នូវកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ........ ២៣
**កថាភាគទី២ លក្ខខណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ........ ២៣
១. សិទ្ធិដែលត្រូវបានរក្សាការពារចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ........ ២៣
២. ភាពចាំបាច់នៃការរក្សាការពារចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ........ ២៤
**កថាភាគទី៣. ប្រាតិភោគនៃការរឹបអូសជាបណ្ដោះអាសន្ន** ........ ២៤
១. គោលបំណងនៃប្រាតិភោគ ........ ២៥
២.ចំនួននៃប្រាតិភោគ ........ ២៥

៣. វិធីនៃការដាក់ប្រាតិភោគ ........ ២៦

**កថាភាគទី៤. ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន** ........ ២៧

១. គោលបំណងនៃប្រាក់រំដោះ ........ ២៧

២. ចំនួននៃប្រាក់រំដោះ ........ ២៧

៣. វិធីនៃការដាក់ប្រាក់រំដោះ ........ ២៨

**កថាភាគទី៥. ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន** ........ ២៨

១. ដីកាសម្រេចបង្គាប់ឱ្យរឹបអូសជាបណ្តោះអាសន្ន ........ ២៨

២. ដីកាសម្រេចលើកចោលពាក្យសុំ ........ ២៩

**ផ្នែកទី៣ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន** ........ ២៩

**កថាភាគទី១ ស្ថាប័នអនុវត្តការរឹបអូសជាបណ្តោះអាសន្ន** ........ ៣០

១. ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ........ ៣០

២. ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ........ ៣០

៣. ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងលើទ្រព្យសម្បត្តិផ្សេងទៀត ........ ៣០

៤. ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវ ........ ៣០

**កថាភាគទី២. ការដាក់ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្តោះអាសន្ន** ........ ៣០

១.ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ........ ៣១

២. សោហ៊ុយនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ........ ៣១

**កថាភាគទី៣. លក្ខខណ្ឌចាំបាច់នៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន** ........ ៣១

១.លិខិតយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ........ ៣២

២.អំឡុងពេលនៃការអនុវត្ត ........ ៣២

៣.ករណីដែលតុលាការឱ្យដាក់ប្រាតិភោគ ........ ៣២

**កថាភាគទី៤. របៀបនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន** ........ ៣២

១. ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ........ ៣២

១.១. ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដែលកូនបំណុលអនុវត្តកាន់កាប់ ........ ៣៤

១.២. ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដែលម្ចាស់បំណុលកាន់កាប់ ........ ៣៥

១.៣. ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដែលបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត ឬ តតិយជនកាន់កាប់ ........ ៣៥

២. ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ..... ៣៦
២.១. ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលបានចុះបញ្ជី ..... ៣៦
២.២. ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ..... ៣៨
៣. ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នលើសិទ្ធិលើបំណុល និងលើទ្រព្យសម្បត្តិផ្សេងទៀត... ៤០
៤. ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ..... ៤១

## ជំពូកទី៣

## ឧបាស្រ័យចំពោះដីកាសម្រេច និងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

**ផ្នែកទី១ ការតវ៉ាដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ..... ៤២
**កថាភាគី១. ការទាញហេតុផលដោយផ្ទាល់មាត់** ..... ៤៣
**កថាភាគទី២. ការបញ្ចប់ការវិនិច្ឆ័យចំពោះការតវ៉ា** ..... ៤៣
**កថាភាគទី៣. ការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ..... ៤៣
**ផ្នែកទី២ ការតវ៉ាចំពោះការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ..... ៤៤
**កថាភាគទី១. បណ្ដឹងតវ៉ារបស់តតិយជន** ..... ៤៤
**កថាភាគទី២. សមត្ថកិច្ច** ..... ៤៥
**ផ្នែកទី៣. ការលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ..... ៤៥
**កថាភាគទី១. ការទាញហេតុផលដោយផ្ទាល់មាត់** ..... ៤៧
**កថាភាគទី ២. ការផ្អាកលើការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ..... ៤៧
**សេចក្ដីសន្និដ្ឋាន** ..... ៤៨
**អនុសាសន៍** ..... ៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមរស់នៅសព្វថ្ងៃ មនុស្សតែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកដែលសកម្មភាពទាំងនោះលេចឡើងដូចជា ការទិញលក់ ការធ្វើពាណិជ្ជកម្ម ហើយមានពេលខ្លះដោយមានតម្រូវការចាំបាច់ត្រូវក្នុងការចិញ្ចឹមជីវិត រមែងមានការខ្វះខាតប្រាក់កាក់ក្នុងការត្រូវការដោះស្រាយលើបញ្ហាទាំងនោះ ដែលជៀសមិនផុតត្រូវការពឹងពាក់គ្នា ដោយមានការខ្ចីជាប្រាក់ពីក្រុមគ្រួសារ សាច់ញាតិ បងប្អូន មិត្តភក្តិ ឬ គ្រឹះស្ថានហិរញ្ញវត្ថុជាដើម ។ ដែលសកម្មភាពកម្ចីប្រាក់នោះ អាចគិតជាការប្រាក់ ឬ មិនគិតជាការប្រាក់ ឬ មានដាក់ទ្រព្យសម្បត្តិបញ្ចាំផ្សេងៗ និងមានរយៈពេលកំណត់សង ឬ មិនកំណត់ពេលសងជាដើម តាមរយៈសកម្មភាពខាងលើនេះមានករណីខ្លះភាគីម្ខាងមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន និងបង្កហានិភ័យដល់ភាគីម្ខាងទៀតបណ្តាលឱ្យរងការខាតបង់ផលប្រយោជន៍ ជាហេតុនាំឱ្យមានវិវាទកើតឡើង ហើយចាំបាច់ត្រូវមានការដោះស្រាយបញ្ហាទាំងនោះ និងទប់ស្កាត់ការខូចខាតនានា របស់ភាគីម្ខាងទៀតដែលហៅថា ម្ចាស់បំណុល ។ នៅពេលដែលមិនអាចដោះស្រាយវិវាទរវាងគូភាគីបាន ជាការពិតណាស់តម្រូវឱ្យមានតតិយជនចូលមកជួយដោះស្រាយនូវវិវាទទាំងនោះ ដោយឈរលើគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ ។ តតិយជនក្នុងន័យនេះ ចង់សំដៅដល់ប្រព័ន្ធតុលាការដែលមានសិទ្ធិអំណាចក្នុងការស្វែងរកយុត្តិធម៌ឱ្យប្រជាពលរដ្ឋ ។ តាមបរិបទសង្គមមានការរីកចម្រើន ទាមទារឱ្យមានរបបមួយដែលអាចការពារសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលឯកជន ដែលអាចនឹងទទួលនូវព្យសនកម្មដោយសារសកម្មភាពណាមួយដែលភាគីម្ខាងបានធ្វើការរំលោភបំពានមកលើសិទ្ធិរបស់ខ្លួន ។

តួយ៉ាង នៅក្នុងទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជន ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាននីតិវិធីមួយដែលមានដំណើរការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលប្រើពេលពេលខ្លី និងមានគោលបំណងការពារទប់ស្កាត់នូវហានិភ័យរបស់ម្ចាស់បំណុលដែលអាចកើតឡើងជាយថាហេតុ ដូច្នេះនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន ដែលម្ចាស់បំណុលមានគោលបំណងទាមទារឱ្យសងជាប្រាក់ អាចជ្រើសរើសយកនីតិវិធីនេះបានសម្រាប់ការពារសិទ្ធិ ពីព្រោះវាប្រើពេលឆាប់រហ័សនៃការចេញសេចក្តីសម្រេច បើប្រៀបធៀបជាមួយនីតិវិធីនៃបណ្តឹងត្រូវឆ្លងកាត់នីតិវិធីជាច្រើនមានរយៈពេលវែងទើបសាលក្រមចូលជាស្ថាពរទម្រាំតែម្ចាស់បំណុលអាចអនុវត្តសិទ្ធិបានរបស់ខ្លួន ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

អ្វីជានីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន ? ហើយដើម្បីអាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នបាន តើម្ចាស់បំណុលត្រូវធ្វើដូចម្តេចខ្លះទៅស្ថាប័នមានសមត្ថកិច្ច ? តើស្ថាប័នខ្លះណាមានសមត្ថកិច្ចអនុវត្តការរឹបអូសជាបណ្តោះអាសន្ន និងតម្រូវឱ្យមានលក្ខខណ្ឌអ្វីខ្លះទើបអាចអនុវត្តបាន ?

## ៣.ចំណោទបញ្ហាការស្រាវជ្រាវ

គោលបំណងនៃការជ្រើសរើសប្រធានបទនេះ គឺដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីនីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលស្របតាមក្រមនីតិវិធីរដ្ឋប្បវេណីប្រកាសឱ្យប្រើនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

## ៤.សារៈសំខាន់នៃការជ្រើសរើសប្រធានបទ

ការជ្រើសរើសប្រធានបទខាងលើយកមកស្រាវជ្រាវ ព្រោះចង់បង្ហាញឱ្យអ្នកសិក្សាគ្រប់មជ្ឈដ្ឋាន ស្វែងយល់ឱ្យបានស៊ីជម្រៅទៅលើនីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យនៅក្នុងប្រទេសកម្ពុជា និងទុកជាឯកសារសម្រាប់និស្សិតទាំងឡាយដែលមានបំណងចង់ស្វែងយល់ពីប្រធានបទនេះ ។

## ៥.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ប្រធានបទនេះ គឺផ្ដោតសំខាន់លើទ្រឹស្ដីច្បាប់ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននេះ សេចក្ដីពន្យល់អំពីនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ហើយចំពោះដែនកំណត់នៃការបកស្រាយគឺ កម្រិតក្នុងបណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេច និងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន គឺត្រឹមសាលាដំបូងប៉ុណ្ណោះ ដែលមិនធ្វើការបកស្រាយទៅដល់សាលាឧទ្ធរណ៍ ឬ តុលាការកំពូលឡើយ ។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទ “នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យ” នេះត្រូវបានធ្វើការបែងចែងជាបីជំពូកដូចខាងក្រោម៖

ជំពូកទី១ សញ្ញាណទូទៅនៃការរឹបអូសជាបណ្ដោះអាសន្ន

ជំពូកទី២ ដីកាសម្រេច និងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

ជំពូកទី៣ ឧបាស្រ័យចំពោះដីកាសម្រេច និងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដែលនឹងត្រូវបានបកស្រាយនៅក្នុងទំព័រខាងក្រោមជាបន្តបន្ទាប់ដូចតទៅនេះ ៖

# ជំពូកទី១
# សញ្ញាណទូទៅនៃការរើបអូសជា
# បណ្ដោះអាសន្ន

# ជំពូកទី១

# សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្ន គឺជាប្រភេទនៃការចាត់ចែងរក្សាការពារដែលស្ថិតក្នុងគន្ថីទី៧ មានបញ្ញត្តិចាប់ពីមាត្រា៥៣០ ដល់មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ នៃព្រះរាជាណាចក្រកម្ពុជា។ គោលគំនិតនៃការចាត់ចែងរក្សាការពារនេះ គឺផ្តល់នូវការការពារ នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភ នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ ។ ដូច្នេះ ម្ចាស់បំណុលដែលចង់ទាមទារសិទ្ធិរបស់ខ្លួន អាចអនុវត្តតាមរយៈការចាត់ចែងរក្សាការពារបានទៅតាមប្រភេទនៃដីកាសម្រេចនោះ។ ការចាត់រក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗដែលមានខ្លឹមសារដូចកំណត់ដូចខាងក្រោមៈ

- ការរឹបអូសជាបណ្តោះអាសន្នៈ គឺជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។
- ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទៈ គឺជាការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថាម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។
- ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នៈ គឺជាការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

នៅពេលមានវិវាទកើតឡើង រវាងភាគីជម្លោះជៀសមិនផុតត្រូវប្តឹងទៅតុលាការដើម្បីទទួលបានការកាត់សេចក្តីមួយដែលប្រកបដោយសមភាព ក្នុងករណីម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលហើយមានគោលបំណងទាមទារឱ្យសងជាប្រាក់ អាចអនុវត្តសិទ្ធិរបស់ខ្លួនបានតាមរយៈការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ។ ដោយសារតែការរឹបអូសជាបណ្តោះអាសន្នត្រូវឆ្លងកាត់នូវច្រើនដំណាក់កាលដែលនីតិវិធីមានភាពស្មុគស្មាញ ទើបអាចចេញដីកាសម្រេចរក្សាការពារបាន ដែលយើងត្រូវស្វែងយល់ឱ្យកាន់តែលម្អិត ។ ហេតុដូច្នេះ បានជាប្រធានបទសារណានេះ គឺនាងខ្ញុំសូមលើកយកការរឹបអូសជាបណ្តោះអាសន្នចំពោះទ្រព្យមកធ្វើការសិក្សា និងបកស្រាយឱ្យកាន់ស៊ីជម្រៅដែលជាដំបូង

ដើម្បីអាចឱ្យយើងយល់បន្ថែមពីនីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យនោះ គឺត្រូវសិក្សាលើពីសញ្ញាណទូទៅនៃការរឹបអូសជាបណ្ដោះអាសន្នជាមុនសិន ។

## ផ្នែកទី១ ការរឹបអូសជាបណ្ដោះអាសន្ន

ការរឹបអូសជាបណ្ដោះអាសន្ន គឺជាវិធីរក្សាការពារមួយដែលមានលក្ខណៈជាបណ្ដោះអាសន្នក្នុងការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុល ។ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិដោយរឹបអូសបានចំពោះវត្ថុផ្សេងៗទៀត ដែលជាទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីជៀងវាងនូវចេតនាទុច្ចរិតរបស់កូនបំណុលធ្វើការបញ្ចៀសទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការរឹបអូសដោយយកទ្រព្យនោះទៅចាត់ចែងក្នុងការលក់ ឬ ផ្ទេរកម្មសិទ្ធិ ឬ ធ្វើអំណោយ ទៅឱ្យតតិយជនណាមួយបាត់ ដែលនឹងធ្វើឱ្យការរឹបអូសមិនអាចធ្វើទៅបាន ។ តាមរយៈការរឹបអូសជាបណ្ដោះអាសន្ន អាចធ្វើឡើងក្នុងករណីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារឱ្យសងជាប្រាក់ប៉ុណ្ណោះ ។ ម៉្យាងវិញទៀត ការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើបានចំពោះតែ ចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និងនាវា។

ដូច្នេះ ការរឹបអូសជាបណ្ដោះអាសន្ន គឺជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់[1] ។

ឧទាហរណ៍៖ លោក សម្បត្តិ ជាកូនបំណុល បានចុះកិច្ចសន្យាខ្ចីប្រាក់ចំនួន USD ៥,០០០០ ដុល្លារអាមេរិក ជាមួយលោកស្រី សុផល ជាម្ចាស់បំណុល នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ដោយឥតការប្រាក់ និងមានរយៈកំណត់ពេលសងប្រាក់ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១។ លុះដល់ថ្ងៃកំណត់សង លោក សម្បត្តិ នៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន បើទោះបីជាលោកស្រី សុផល បានជូនដំណឹង និងបានពន្យារពេលសងយ៉ាងណាក៏ដោយ ។ លោក សម្បត្តិ មានដីមួយកន្លែងនៅក្រុងភ្នំពេញ ។ នៅក្នុងនីតិវិធីនៃបណ្ដឹងទាមទារប្រាក់ គឺត្រូវចំណាយពេលយូរធ្វើឱ្យលោកស្រី សុផល នឹងអាចបាត់បង់ផលប្រយោជន៍ដែលបណ្ដាលមកពីការលក់ដី ឬ ផ្ទេរ ទៅឱ្យតតិយជន ។ ហេតុនេះ លោកស្រី សុផល ជាម្ចាស់បំណុលដើម្បីរក្សាស្ថានភាពបច្ចុប្បន្នកុំឱ្យមានផ្លាស់ប្ដូរ និងការពារផលប្រយោជន៍ បានដាក់ពាក្យសុំទៅតុលាការឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលើដីរបស់លោក សម្បត្តិ ដើម្បីធានាការអនុវត្តសិទ្ធិរបស់លោកស្រី សុផល នៅពេលដែលឈ្នះក្ដី ។

ដូច្នេះ នៅពេលដែលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលើដីរបស់លោក សម្បត្តិ ជាហេតុនាំឱ្យលោក សម្បត្តិ មិនអាចលក់ ឬ ផ្ទេរកម្មសិទ្ធិដីរបស់ខ្លួនបានទៀតឡើយ។

[1] មាត្រា ៥៣១-ក ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## កថាភាគទី១. មូលហេតុនៃការរឹបអូសជាបណ្តោះអាសន្ន

នៅក្នុងករណីម្ចាស់បំណុលដែលមានសិទ្ធិទាមទារឱ្យជាសងប្រាក់ មានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬ មានការបារម្ភថាមានការលំបាកយ៉ាងខ្លាំងនៅក្នុងការអនុវត្តដោយបង្ខំនោះ ជាចាំបាច់តុលាការត្រូវចាត់វិធាន ដោយចេញនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះកម្មវត្ថុដែលម្ចាស់បំណុលទាមទារឱ្យរឹបអូសជាបណ្តោះអាសន្នដោយផ្អែកសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលមានចំពោះកូនបំណុល ដើម្បីថែរក្សាស្ថានភាពបច្ចុប្បន្ននោះកុំឱ្យមានការផ្លាស់ប្តូរ នឹងរង់ចាំមាននីតិវិធីបណ្តឹងអង្គសេចក្តីក្នុងការសម្រេចសេចក្តីដោយបញ្ជាក់ពីអត្ថិភាព ឬ នត្ថិភាពសិទ្ធិទាមទាររបស់ម្ចាស់បំណុលមានពិតមែនដែរ ឬទេ ។

ដូច្នេះ ការរឹបអូសជាបណ្តោះអាសន្ន គឺជារបបធានានូវតម្លៃនៃទ្រព្យរបស់កូនបំណុលឱ្យនៅស្ថិតនៅដដែល ដើម្បីអាចអនុវត្តដោយបង្ខំទាមទារឱ្យសងប្រាក់ ។

## កថាភាគទី២. កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន

កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នមានដូចខាងក្រោម៖

- ចលនវត្ថុ
- អចលនវត្ថុ
- សិទ្ធិលើបំណុល និងលើទ្រព្យសម្បត្តិផ្សេងទៀត
- និងនាវា

កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នមានបួនប្រភេទ គឺ ចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល និងលើទ្រព្យសម្បត្តិផ្សេងទៀត និងនាវា គឺជាវត្ថុ និងសិទ្ធិដែលត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលក្នុងការធានាដល់ការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនាពេលអនាគត ។ កម្មវត្ថុនៃការរឹបអូសនេះម្ចាស់បំណុលជាអ្នកជ្រើសរើសដោយខ្លួនឯងថាចង់រឹបអូសទៅលើកម្មវត្ថុមួយណា ដោយហេតុថាតុលាការពុំមានសិទ្ធិក្នុងការជ្រើសរើសយកកម្មវត្ថុរឹបអូសណាមួយរបស់កូនបំណុល មកចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយឆន្ទានុសិទ្ធិខ្លួនឯងបានឡើយ ។

### ១. ចលនវត្ថុ

ក្នុងន័យទូទៅ ចលនវត្ថុ ចង់សំដៅទៅលើវត្ថុដែលអាចរំកិល ឬ ផ្លាស់ទីតាំងបាន ដូចជា តុ ទូរ កៅអី ទោចក្រយានយន្ត ត្រីចក្រយានយន្ត ទូក ជាអាទិ៍ ។ ន័យមួយទៀត ចលនវត្ថុ សំដៅលើវត្ថុក្រៅពីអចលនវត្ថុ ។[2] ម៉្យាងវិញទៀត ចលនវត្ថុក្នុងន័យនេះ រួមមានចលនវត្ថុតាមក្រមរដ្ឋប្បវេណី និងផលធម្មជាតិដែលមិនទាន់បំបែកពីដី ហើយចលនវត្ថុក៏រាប់បញ្ចូលនូវរូបិយវត្ថុមានដូចជា ក្រដាសប្រាក់ និងប្រាក់កាក់ផងដែរ ។ ហេតុនេះ នៅក្នុងករណីដែលម្ចាស់បំណុលមានការបារម្ភថាកូនបំណុលអាចនឹងលាក់បាំង ឬ ផ្ទេរនូវទ្រព្យរបស់ខ្លួនដែលជាចលនវត្ថុ

[2] មាត្រា១២០-៣ ក្រមរដ្ឋប្បវេណី ២០០៧

តុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបានទៅតាមពាក្យសុំរបស់ម្ចាស់បំណុល ដើម្បីធ្វើការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុនោះដោយរក្សាការពារទុក ដើម្បីម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនបាននាពេលអនាគត ។

ឧទាហរណ៍៖ លោក សុខ បានឱ្យប្រាក់ លោក រិទ្ធី ខ្ចីចំនួន USD ១០,០០០ ដុល្លារអាមេរិក នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ និងកំណត់សងនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ តែលោក រិទ្ធី មិនព្រមសង ។ លោក សុខ ជាម្ចាស់បំណុលឃើញលោក រិទ្ធី ជាកូនបំណុលប្រើប្រាស់រថយន្ត ហើយគិតថារថយន្តនោះជាកម្មសិទ្ធិរបស់កូនបំណុល ។ ក្នុងករណីនេះ លោក សុខ បានដាក់សុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលើរថយន្តដែលលោក រិទ្ធី កំពុងប្រើប្រាស់ ។

ដូច្នេះ រថយន្ត គឺជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន។

**២. អចលនវត្ថុ**

រីឯអចលនវត្ថុ គឺសំដៅទៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្ដូរទីកន្លែងបាន មានដូចជា អគារ សំណង់ រុក្ខជាតិ ជាអាទិ៍[3] ។ ដូចនេះ ក្នុងករណីម្ចាស់បំណុលចង់ទាមទារសិទ្ធិរបស់ខ្លួនក្នុងគោលបំណងឱ្យសងជាប្រាក់ នៅពេលដែលកូនបំណុលមិនបំពេញកាតព្វកិច្ច ម្ចាស់បំណុលអាចដាក់ពាក្យស្នើសុំដីកាសម្រេចរឹបអូសបណ្ដោះអាសន្នបានដោយបង្ហាញអំពីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ និងកំណត់កម្មវត្ថុដែលអាចជាអចលនវត្ថុរបស់កូនបំណុលដែលម្ចាស់បំណុលចង់រក្សាការពារលើអចលនវត្ថុនោះ ដើម្បីបង្ការនូវហានិភ័យដែលអាចកើតឡើងជាយថាហេតុ និងបង្ខំឱ្យមានការអនុវត្តកាតព្វកិច្ច ។

ឧទាហរណ៍៖ នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ លោក មករា ជាម្ចាស់បំណុល ហើយលោក រក្សា ជាកូនបំណុល បានចុះកិច្ចសន្យាទិញលក់ទិញគោក្នុងតម្លៃចំនួន USD ៥០,០០០ ដុល្លារអាមេរិក ហើយនៅថ្ងៃចុះកិច្ចសន្យា លោក មករា បានប្រគល់គោទៅឱ្យលោក រក្សា តែលោក រក្សា សុំជំពាក់ប្រាក់ចំនួន USD ៣០,០០០ ដុល្លារអាមេរិក សិន ។ ដល់ថ្ងៃកំណត់ប្រគល់ថ្លៃលក់ទិញ លោក រក្សា មិនព្រមបង់ថ្លៃលក់ទិញដែលនៅសល់ឱ្យទៅលោក មករា វិញទេ ។ លោក មករា ចង់ទាមទារឱ្យលោក រក្សា បង់ប្រាក់ថ្លៃលក់ទិញគោដែលនៅសល់។ លោក មករា បានដឹងថា លោក រក្សា ជាកម្មសិទ្ធិករនៃដីមួយកន្លែងនៅខេត្តកណ្ដាលតាមរយៈសៀវភៅគោលបញ្ជីដីធ្លី ។

ដូច្នេះ ដីនៅខេត្តកណ្ដាលដែលជាកម្មសិទ្ធិរបស់លោក រក្សា គឺជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ។

**៣. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត**

- **ករណីសិទ្ធិលើបំណុល**

ក្នុងករណីកូនបំណុល មានសិទ្ធិលើបំណុលចំពោះបុគ្គលជាក់លាក់ណាមួយទៀត បុគ្គលដែលជាកូនបំណុលរបស់កូនបំណុលនៃការអនុវត្តត្រូវបានហៅថាកូនបំណុលទី៣ បើធៀបជាមួយនឹងម្ចាស់បំណុល ។ មានន័យថាកូនបំណុលនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស ហៅថាកូនបំណុលទី៣។ សិទ្ធិលើកូនបំណុលទី៣នេះ

[3] មាត្រា១២០-២ ក្រមរដ្ឋប្បវេណី ២០០៧

គឺជាប្រភេទសិទ្ធិមួយដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ។ សិទ្ធិលើបំណុល ដែលអាចជាកម្មវត្ថុនៃការរឹបអូសរួមមាន សិទ្ធិទាមទារឱ្យសងជាប្រាក់ សិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ សិទ្ធិធានាលើហ៊ីប៉ូតែក សិទ្ធិប្រាតិភោគលើបំណុល សិទ្ធិលើប្រាក់បៀវត្ស សិទ្ធិលើប្រាក់សោធននិវត្តន៍ សិទ្ធិលើថ្លៃឈ្នួលដី សិទ្ធិលើថ្លៃឈ្នួល សិទ្ធិលើការប្រាក់ ជាអាទិ៍ ។ សូមលើកយកតែសិទ្ធិមួយចំនួនមកបកស្រាយពន្យល់ គឺសិទ្ធិទាមទារឱ្យសងជាប្រាក់ ចង់សំដៅលើសិទ្ធិបំណុលដែលម្ចាស់បំណុលទាមទារឱ្យកូនបំណុលសងជាប្រាក់ ក្នុងករណីដែលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នដែលមានកម្មវត្ថុទាមទារឱ្យកូនបំណុលសងប្រាក់បញ្ញើពីធនាគារ និងហាមឃាត់កូនបំណុលនៃការអនុវត្តមិនអាចដកប្រាក់បញ្ញើ និងជូនដំណឹងទៅធនាគារមិនឱ្យកូនបំណុលនៃការអនុវត្តដកប្រាក់នោះចេញពីគណនីបានឡើយ ។ ចំពោះសិទ្ធិលើប្រាក់បៀវត្ស គឺម្ចាស់បំណុលនៃការអនុវត្ត ធ្វើការរឹបអូសសិទ្ធិលើប្រាក់ថ្លៃឈ្នួលដែលហាមនិយោជកមិនឱ្យបើកប្រាក់ខែទៅឱ្យកូនបំណុលនៃការអនុវត្ត ប៉ុន្តែសិទ្ធិនេះក៏អាចបាត់បង់អានុភាពដោយសារតែក្រោយការរឹបអូសសិទ្ធិលើប្រាក់ថ្លៃឈ្នួលកូនបំណុលអាចរំលាយកិច្ចសន្យាការងារបាន ។ សិទ្ធិលើប្រាក់បៀវត្សនេះដែលបន្ទាប់ពីបានកាត់ពន្ធអាករ និងប្រាក់ធានារ៉ាប់រងសង្គមកិច្ច អាចរឹបអូសបានលុះត្រាតែប្រាក់ឈ្នួលនោះលើសពី ៦.០០០.០០០ ប្រាំមួយលាន រៀល ក្នុងមួយខែ អាចរឹបអូសយកបានទាំងអស់ ។

ឧទាហរណ៍៖ លោក x បានខ្ចីប្រាក់ចំនួន USD ៥,000 ដុល្លារអាមេរិក ពីលោក Y នាថ្ងៃទី០១ ខែមករា ឆ្នាំ ២០២០ និងកំណត់អំឡុងពេលសងប្រាក់វិញនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ។ លោក x បានចុះកិច្ចសន្យាខ្ចីប្រាក់ជាមួយលោកស្រី z ចំនួន USD ១,0000 ដុល្លារអាមេរិក នាថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយលោកស្រី z ត្រូវសងប្រាក់ឱ្យលោក x វិញ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ ។ លុះដល់ថ្ងៃកំណត់សង លោក x គេចវេះមិនព្រមសង ។ ក្នុងករណីនេះ លោក x ដែលជាកូនបំណុលមានកូនបំណុលជាលោកស្រី z ។

ដូច្នេះ លោក Y អាចរឹបអូសជាបណ្ដោះអាសន្នចំពោះបំណុលរបស់លោកស្រី z បានតាមរយៈដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលរបស់លោក x មានចំពោះលោកស្រី z ។

ឧទាហរណ៍៖ លោក ចាន់ ធឿន បានចុះកិច្ចសន្យាទិញផ្ទះពី កញ្ញា សុដា ក្នុងតម្លៃចំនួន USD ២0,000 ដុល្លារអាមេរិក នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ និងកំណត់ពេលប្រគល់ប្រាក់លក់ទិញផ្ទះនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ ។ លុះដល់ថ្ងៃកំណត់សង លោក ចាន់ ធឿន មិនព្រមប្រគល់ប្រាក់ទៅឱ្យ កញ្ញា សុដា ឡើយ ។ កញ្ញា សុដា បានរកឃើញថា លោក ចាន់ ធឿន មានប្រាក់បញ្ញើនៅធនាគារ ABD ។ កញ្ញា សុដា បារម្ភថា លោក ចាន់ ធឿន នឹងយកប្រាក់នោះទៅចាយវាយអស់ និងពិបាកក្នុងការអនុវត្តសិទ្ធិរបស់ខ្លួននាពេលអនាគត ។

ដូច្នេះ កញ្ញា សុដា បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះប្រាក់បញ្ញើនៅធនាគារ ABD ដែលចាត់ទុកថាជាកូនបំណុលទី៣ ដើម្បីកុំឱ្យលោក ចាន់ ធឿន ដកប្រាក់បញ្ញើនោះបាន និងហាមឃាត់មិនឱ្យធនាគារ ABD ដកលុយឱ្យលោក ចាន់ ធឿន ។

- **សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត**

ដោយឡែកក្រៅពីសិទ្ធិលើបំណុល ចលនវត្ថុ អចលនវត្ថុ នាវា គឺមានសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុល ក៏អាចក្លាយជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នបានដែរ មានដូចជា៖ សិទ្ធិលើកម្មសិទ្ធិបញ្ញា សិទ្ធិលើប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិសហគ្រាស សិទ្ធិទាមទារឱ្យប្រគល់នាវា សិទ្ធិលើមូលបត្រ សិទ្ធិលើភាគហ៊ុន ជាអាទិ៍។ ចំពោះសិទ្ធិលើកម្មសិទ្ធិបញ្ញា ម្ចាស់បំណុលអាចធ្វើរឹបអូសបាន ពីព្រោះសិទ្ធិនេះមានវាទៅលើស្នាដៃជាក់លាក់ណាមួយដោយអាចគណនាជាតម្លៃសេដ្ឋកិច្ចបាន ។ ក្នុងករណីកូនបំណុលមានភាគហ៊ុននៅក្រុមហ៊ុនណាមួយ ដូច្នេះម្ចាស់បំណុលអាចរឹបអូសជាបណ្តោះអាសន្នលើភាគហ៊ុននោះបាន ។

ឧទាហរណ៍៖ លោក អេឡិច ជាអ្នកនិពន្ធរឿងប្រលោមលោក សៀវភៅរបស់លោក ត្រូវបានប្រគល់សិទ្ធិលក់ឱ្យទៅកញ្ញា នីតា ជាម្ចាស់ហាងលក់សៀវភៅ "នីតាប៊ុកសេនធើ" ។ សិទ្ធិអ្នកនិពន្ធសំដៅដល់សិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌ ។ សិទ្ធិបេតិកភណ្ឌមានតម្លៃជាសេដ្ឋកិច្ច ដែលអាចជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នបាន ។ ដោយកញ្ញា នីតា មិនបានប្រគល់ប្រាក់ថ្លៃនិពន្ធរឿងប្រលោមលោក អេឡិច ។ លោក អេឡិច ទាមទារប្រាក់ពីកញ្ញា នីតា ជាច្រើនដង ប៉ុន្តែនៅតែកញ្ញា នីតា មិនបានប្រគល់ប្រាក់ថ្លៃដដែល ។ លោក អេឡិច ជាម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដើម្បីរក្សាការពារចំពោះសិទ្ធិបេតិកភណ្ឌរបស់កូនបំណុលកញ្ញា នីតា ។

ដូច្នេះ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺ សិទ្ធិលើបេតិកភណ្ឌ។

### ៤. នាវា

នាវា សំដៅទៅលើជលយានដែលមានចំណុះ សរុបជាតោនស្មើនឹង និងលើសពី ២០ (ម្ភៃ) តោន ទោះជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងជលយានដែលមានចំណុះសរុបជាតោនក្រោម២០ (ម្ភៃ) តោន[4] ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ។ លិខិតបញ្ជាក់សញ្ជាតិនាវា សំដៅទៅលើឯកសារដែលបញ្ជាក់សញ្ជាតិរបស់នាវា និងឯកសារផ្សេងទៀតដែលចាំបាច់ដើម្បីបើកបរនាវាដោយស្របច្បាប់ ។ តាមន័យរដ្ឋប្បវេណី នាវា គឺជាចលនវត្ថុ ប៉ុន្តែដោយសារតែលទ្ធកម្ម ការបាត់បង់ ឬ ការផ្លាស់ប្តូរនូវកម្មសិទ្ធិលើនាវា ដែលធ្វើឡើងតាមរយៈការចុះបញ្ជីត្រូវតែប្រកាសជាសាធារណៈ គេយកវិធាននៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមកប្រើដូចគ្នា ហេតុនេះនាវាមិនចាត់ទុកថាជាចលនវត្ថុឡើយ តែមានលក្ខណៈដូចអចលនវត្ថុទៅវិញ។ នាវាដែលជាកម្មវត្ថុការរឹបអូសជាបណ្តោះអាសន្នចំពោះនាវា នៅក្នុងន័យនេះចង់សំដៅលើនាវាទាំងឡាយណាដែលមានរចនាសម្ព័ន្ធជាក់លាក់មួយ និងមានសមត្ថភាពអាចធ្វើដំណើរតាមផ្លូវទឹកក្នុងគោលបំណងដឹកអ្នកដំណើរ ឬ វត្ថុផ្សេងទៀតបាន ហើយពាក្យទឹកក្នុងន័យនេះ សំដៅដល់ក្នុងទឹក និងនៅលើទឹក។

ចំពោះវត្ថុដែលមានរូបរាង ដូចជានាវាតែមិនបានរាប់ចូលជានាវា មានដូចជា ក្បូន នាវាពន្លឺ ឃ្លាំងទំនិញនៅលើទឹក ផ្ទះបណ្តែតទឹក ជាអាទិ៍ ព្រោះសមត្ថភាពរបស់វាប្រើក្នុងគោលបំណងការធ្វើដំណើរតាមផ្លូវជិតប៉ុណ្ណោះ។

[4] មាត្រា៤៥៤ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ចំពោះសញ្ជាតិរបស់នាវា ក្នុងករណីនាវាដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ម្ចាស់នាវាឱ្យតែនាវានោះសិទ្ធិក្នុងដែនអធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវាអាចធ្វើទៅបាន។

ឧទាហរណ៍៖ លោក ពិសិដ្ឋ ជាម្ចាស់បំណុល បានចុះកិច្ចសន្យាបរិភោគជាមួយលោក សម្បត្តិ ជាកូនបំណុលក្នុងចំនួន USD ៤០,០០០ ដុល្លារអាមេរិក កំណត់ពេលសងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ។ ប៉ុន្តែផុតកាលកំណត់អស់រយៈពេល១ឆ្នាំ មកហើយក៏ លោក សម្បត្តិ នៅតែមិនសងប្រាក់ទៅលោក ពិសិដ្ឋ វិញ ។ លោក ពិសិដ្ឋ រកឃើញឈ្មោះលោក សម្បត្តិ ជាកម្មសិទ្ធិករលើនាវា ST ។ លោក ពិសិដ្ឋ បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះនាវារបស់លោក សម្បត្តិ។

ដូច្នេះ នាវា ST គឺជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ។

## កថាភាគទី៣. លក្ខណៈពិសេសនៃការរឹបអូសជាបណ្ដោះអាសន្ន

### ១. លក្ខណៈបណ្ដោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺជាដីកាសម្រេចមានលក្ខណៈបណ្ដោះអាសន្ន ពោលគឺពុំមានឥទ្ធិពលទៅលើសេចក្ដីសម្រេចបញ្ចប់នៃលិខិតអនុវត្តទេ លើសពីនេះ បើទោះជាតុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នក៏ដោយក៏មិនមែនមានន័យថាទទួលស្គាល់ជាអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិក្នុងបណ្ដឹងអង្គសេចក្ដីនោះទេ ។ លើសពីនេះទៀត ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នក៏អាចបំលែងទៅការអនុវត្តដោយបង្ខំដែរ ដូច្នេះ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គ្រាន់តែធ្វើការចាត់ចែងជាបណ្ដោះអាសន្នក្នុងអំឡុងពេលមួយប៉ុណ្ណោះ ទម្រាំរហូតម្ចាស់បំណុលអាចសម្រេចនូវគោលបំណងនៃការអនុវត្តដោយបង្ខំ ។

ឧទាហរណ៍៖ លោក វិចិត្រ ជាកូនបំណុល បានខ្ចីប្រាក់ ពីលោកស្រី មីនា ចំនួន USD ៣០,០០០ ដុល្លារអាមេរិក ។ លុះដល់ថ្ងៃកំណត់សងមកដល់ តែលោក វិចិត្រ ពុំសងឡើយ ហើយទោះបីជាមានការដាស់តឿនជាច្រើនលើក ជាច្រើនសារក៏ដោយ ។ លោក វិចិត្រ មានដីមួយកន្លែងនៅខណ្ឌសែនសុខ ។ ដោយដឹងថាលោក វិចិត្រ ជំពាក់បំណុលគេច្រើន លោកស្រី មីនា គ្មានជម្រើសអ្វីក្រៅពីដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលើដីរបស់លោក វិចិត្រ និងបានដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីទាមទារឱ្យលោក វិចិត្រ សងប្រាក់មកវិញ ។ តុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតាមការស្នើសុំរបស់លោកស្រី មីនា ។ ចំពោះបណ្ដឹងទាមទារប្រាក់លោកស្រី មីនា បានទៅតុលាការនោះប្រព្រឹត្តទៅជាធម្មតា ។

ដូច្នេះ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានចេញរួចហើយក៏ដោយទៅលើសិទ្ធិលើបំណុលនៃបណ្ដឹងទាមទារប្រាក់តែមិនប្រាកដថាត្រូវបានទទួលស្គាល់នូវអត្ថិភាពនៃសិទ្ធិលើបំណុលលើបណ្ដឹងអង្គសេចក្ដីនោះទេ ។

### ២. លក្ខណៈបន្ទាន់បង្ខំ

ការរឹបអូសជាបណ្ដោះអាសន្ន មិនអាចការពារផលប្រយោជន៍ ឬ សិទ្ធិរបស់ម្ចាស់បំណុលដែលអាចរងការខូចខាតនាពេលអនាគតដ៏ខ្លីប្រសិនជាមិនអនុវត្តឱ្យបានឆាប់រហ័ស ។ ហេតុនេះ តុលាការអាចចេញដីកាសម្រេច

រឹបអូសជាបណ្តោះអាសន្នដោយពិនិត្យលើតែសេចក្តីបញ្ជាក់ដំបូងជាការគ្រប់គ្រាន់ ។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានអានុភាព អនុវត្តភ្លាមៗ ហើយត្រូវអនុវត្តក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍[5] ។ ដោយសារមានភាពបន្ទាន់បង្ខំ តុលាការនៃសំណុំរឿងរក្សាការពារមានលក្ខណៈជាសមត្ថកិច្ចផ្តាច់មុខ ។

**៣. លក្ខណៈបន្ទាប់បន្សំ**

នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន គឺជានីតិវិធីរណបឱ្យបណ្តឹងអង្គសេចក្តីដែលតម្រូវឱ្យម្ចាស់បំណុលត្រូវបញ្ជាក់ឱ្យឃើញនូវសិទ្ធិរបស់ខ្លួននៅក្នុងបណ្តឹងអង្គសេចក្តី ។ ហេតុដូចនេះ កូនបំណុលអាចទាមទារឱ្យតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់បណ្តឹងអង្គសេចក្តី ។ តុលាការត្រូវចេញដីកាបង្គាប់ឱ្យម្ចាស់បំណុលដាក់បណ្តឹងអង្គសេចក្តី ដោយកំណត់អំឡុងពេលសមរម្យ បើមានពាក្យសុំរបស់កូនបំណុលដែលការបង្គាប់របៀបនេះ គឺហៅថាភាពបន្ទាប់បន្សំ ។ ហើយប្រសិនជាមិនបានដាក់បណ្តឹងអង្គសេចក្តីតាមការបង្គាប់របស់តុលាការទេ ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នរបស់ម្ចាស់បំណុលនឹងត្រូវបានលុបចោល ។

ឧទាហរណ៍៖ លោក A ជាកូនបំណុល មានផ្ទះនៅខេត្តកណ្តាល បានខ្ចីប្រាក់ពីលោក B ជាម្ចាស់បំណុល រស់នៅរាជធានីភ្នំពេញចំនួន USD ៥០,០០០ ដុល្លារអាមេរិក ។ ដល់ថ្ងៃកំណត់សង តែ លោក A មិនព្រមសង បើទោះបីជាដាស់តឿន ពីលោក B ក៏ដោយ ។ លោក A មានទ្រព្យលើដី លោកស្រី C នៅខេត្តព្រះសីហនុ ហើយកំពុងប្រកាសលក់ ។ លោក B បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើដីរបស់លោកស្រី C ។ លោក B ដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីទាមទារឱ្យលោក A បង់ប្រាក់ ។

ដូច្នេះ តុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើទ្រព្យរបស់លោក A ប៉ុន្តែដោយសារការមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមការបង្គាប់របស់តុលាការ ជាហេតុនាំឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានលុបចោលដែលអាចសន្មតថាមានការផ្លាស់ប្តូរស្ថានភាពនៃទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ឬ លែងមានភាពចាំបាច់នៃរក្សាការពារទៀតហើយ ។

**៤. លក្ខណៈសម្ងាត់**

ការរឹបអូសជាបណ្តោះអាសន្ន ផ្តល់ផលប្រយោជន៍ដល់ម្ចាស់បំណុលក្នុងការរក្សាភាពសម្ងាត់ដោយមិនឱ្យកូនបំណុលបានដឹងជា មុនអំពីចំណាត់ការរបស់តុលាការទៅលើកម្មវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្នទេ ប្រសិនបើ កូនបំណុលបានដឹងជាមុននាំឱ្យកូនបំណុលនឹងធ្វើការចាត់ចែងកម្មវត្ថុការរឹបអូសជាបណ្តោះអាសន្ននោះបាត់មុន ឬ លាក់បាំងដែលជាហេតុនាំឱ្យការរឹបអូសជាបណ្តោះអាសន្នមិនអាចធ្វើទៅបាន ។ ដូច្នេះ នៅពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការមិនជូនដំណឹងទៅកូនបំណុលអំពីដីកាសម្រេចរឹបអូសជាបណ្តោះ

[5] សូមមើលមាត្រា៥៦២ -២,៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

អាសន្ននោះទេ ពោលគឺដើម្បីរក្សាការសម្ងាត់របស់ម្ចាស់បំណុលម្យ៉ាងវិញការសម្ងាត់នេះនឹងលែងមានន័យប្រសិនជាកូនបំណុលបានដឹង ប៉ុន្តែក៏មានករណីលើកលែងដែលតម្រូវឱ្យកូនបំណុលបានដឹងពីនីតិវិធីផងដែរ ។

## ផ្នែកទី២. តុលាការដែលមានសមត្ថកិច្ចចំពោះការរឹបអូសជាបណ្ដោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចឱ្យតុលាការចេញសេចក្ដីសម្រេចបាន លុះត្រាតែមានពាក្យសុំនិងដាក់ពាក្យសុំនោះចូលទៅស្ថាប័នដែលមានសមត្ថកិច្ច ។ ដូច្នេះ តុលាការដែលមានសមត្ថកិច្ចលើរឿងក្ដីរក្សាការពារនេះ គឺត្រូវតែជាតុលាការដែលមានសមត្ថកិច្ចផ្ដាច់មុខ[6] ដោយមិនអាចផ្លាស់ប្ដូរតាមការព្រមព្រៀងរបស់គូភាគីបានឡើយ ។ ការកំណត់សមត្ថកិច្ចរបស់តុលាការនេះ ក៏ព្រោះតែតុលាការមានតាមបណ្ដាលខេត្ត និងរាជធានីហើយប្រសិនបើមិនកំណត់សមត្ថកិច្ចនោះទេវាអាចនាំឱ្យមានការជាន់សមត្ថកិច្ចគ្នា ។ ដូច្នេះចាំបាច់ត្រូវបែងចែកសមត្ថកិច្ចតុលាការក្នុងរឿងក្ដីរក្សាការពារនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលត្រូវបានបែងចែកដូចខាងក្រោម៖

### កថាភាគទី១. តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី

តុលាការមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី គឺជាតុលាការដែលពាក្យបណ្ដឹងត្រូវបានដាក់ចំពោះសិទ្ធិលើបំណុលដែលនឹងត្រូវបានរក្សាការពារ ។ នៅពេលដែលអង្គសេចក្ដីកំពុងត្រូវបានចាត់ការ ជាគោលការណ៍ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី គឺតុលាការជំនុំជម្រះលើកទី១[7] ។ ប៉ុន្តែ ប្រសិនបើបណ្ដឹងអង្គសេចក្ដីត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី គឺជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍[8] ។ ផ្ទុយទៅវិញ ប្រសិនជាបណ្ដឹងអង្គសេចក្ដីកំពុងចាត់ក្នុងនីតិវិធីបណ្ដឹងសារទុក្ខ ត្រូវត្រឡប់ទៅរកគោលការណ៍ដើមវិញ ពោលគឺ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដីចំពោះរឿងក្ដីរក្សាការពារ គឺជាតុលាការដែលជំនុំជម្រះលើកទី១ ដោយហេតុថា តុលាការកំពូលមិនអាចក្លាយជាតុលាការដែលមានសមត្ថកិច្ចចាត់ការលើរឿងក្ដីរក្សាការពារបានឡើយ ។ ជាទូទៅសិទ្ធិទទួលបានការជម្រះក្ដីមានត្រឹមតែពីរដង ត្រូវបានធានាចំពោះភាគីដើម្បីអាចធ្វើការតវ៉ា និងជំទាស់នឹងដីកាសម្រេច ។ ហេតុនេះ ប្រសិនបើតុលាការកំពូលជាតុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះនាំឱ្យសិទ្ធិខាងលើនឹងមិនត្រូវបានធានានោះទេ ។

ឧទាហរណ៍៖ លោក ក ជាម្ចាស់បំណុល បានឱ្យលោក ខ ជាកូនបំណុល ខ្ចីប្រាក់ចំនួន USD ៥០,០០០ ដុល្លារអាមេរិក ។ លោក ខ មានដីចំការនៅខេត្តព្រៃវែង។ ដោយលោក ខ មិនអនុវត្តកាតព្វកិច្ចសងប្រាក់មកលោក ក វិញ ។ លោក ក សម្រេចចិត្តដាក់ពាក្យបណ្ដឹងលើ លោក ខ ក្នុងគោលបំណងទាមទារឱ្យសងប្រាក់ចូលទៅសាលាដំបូងខេត្តព្រៃវែង ។ នៅក្នុងករណីនេះ សាលាដំបូងខេត្តព្រៃវែង ជាតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដីទាមទារឱ្យសងប្រាក់វិញ ។ ចំណែកឯពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចដាក់ទៅ

[6] សូមមើលមាត្រា ៥៣៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[7] សូមមើលមាត្រា ៥៤០-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[8] មាត្រា ៥៤០-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

សាលាដំបូងខេត្តព្រៃវែងបានផងដែរ ។ ដូច្នេះ សាលាដំបូងខេត្តព្រៃវែងមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដីផង និងមានសមត្ថកិច្ចលើរឿងក្ដីរក្សាការពារដែរ ។

**កថាភាគទី២.តុលាការមានសមត្ថកិច្ចនៅទីកន្លែងដែលវត្ថុនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ**

ក្រៅពីតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចត្រូវបានដាក់នៅសាលាដំបូងដោយផ្អែកតាមទីតាំងនៃវត្ថុដែលនឹងត្រូវរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ ។ សម្រាប់កម្មវត្ថុជាចលនវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន មិនចាំបាច់កំណត់បញ្ជាក់វត្ថុដែលជាកម្មវត្ថុនោះទេ តែត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុស្ថិតនៅ ហើយក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នជាសិទ្ធលើបំណុល ឬ លើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវចាត់ទុកថាសិទ្ធិនោះ ស្ថិតនៅឯលំនៅឋានរបស់កូនបំណុលទី៣[9] ។

ឧទាហរណ៍៖ ដើមចោទឈ្មោះ សុជា បានដាក់ពាក្យបណ្ដឹងទៅសាលាដំបូងខេត្តកណ្ដាល ដើម្បីទាមទារឱ្យកញ្ញា ពិសី សងប្រាក់ដែលបានកម្ចីចំនួន USD ២០,០០០ ដុល្លារអាមេរិក ។ កម្មវត្ថុអចលនវត្ថុដែលត្រូវអនុវត្តនៅពេល សុជា ឈ្នះក្ដី គឺផ្ទះរបស់ កញ្ញា ពិសី ដែលមានទីតាំងនៅរាជធានីភ្នំពេញ ជាកម្មសិទ្ធិរបស់កញ្ញា ពិសី ។ ដោយមានការបារម្ភថាផ្ទះរបស់កញ្ញា ពិសី ត្រូវបានប្រកាសលក់តាមរយៈក្រុមហ៊ុនអចលនទ្រព្យ ភីភី ខ្មែរ រៀលអ៊ីស្ទេត មុនពេលដែលសុជា អាចអនុវត្តដោយបង្ខំបាន ។ ហេតុនេះ សុជា អាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន នៅតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលអចលនវត្ថុនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ ។

ដូច្នេះ នៅក្នុងករណីនេះ សុជា អាចដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននៅសាលាដំបូងខេត្តកណ្ដាល ឬ សាលាដំបូងរាជធានីភ្នំពេញ ។

## ផ្នែកទី៣ នីតិវិធីនៃការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំរបស់ម្ចាស់បំណុល[10] ។ អាចនិយាយបានម្យ៉ាងទៀត គឺតុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបាន នៅពេលដែលមានពាក្យសុំរបស់ម្ចាស់បំណុលបានដាក់ចូលមកតាមរយៈរដ្ឋបាលរបស់តុលាការទើបជាការត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ ។

**កថាភាគទី១. ការដាក់ពាក្យសុំ**

ដើម្បីអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបាន លុះត្រាតែម្ចាស់បំណុលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមទម្រង់ច្បាប់ ដាក់ចូលទៅតុលាការ

[9] សូមមើលមាត្រា ៥៤០-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[10] សូមមើល មាត្រា ៥៣២-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ដែលមានសមត្ថកិច្ច និងមានការវាយត្រាចូលពីសំណាក់រដ្ឋបាលរបស់តុលាការ[11] ។ ការដាក់ពាក្យសុំនេះ តម្រូវឱ្យម្ចាស់បំណុលសរសេររៀបរាប់នូវខ្លឹមសារដែលជាមូលដ្ឋាននៃការទាមទារ និងត្រូវចំណាយសោហ៊ុយក្នុងការនីតិវិធីត្រៀម ។ ចំពោះខ្លឹមសារដែលមាននៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវសរសេរឱ្យបានច្បាស់លាស់ទៅលើចំណុចសំខាន់ៗ និងបញ្ជាក់នូវចំណុចនីមួយៗដូចខាងក្រោមនេះ ៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ។
- សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។
- ភាពចាំបាច់នៃការរក្សាការពារ[12] ។

ចំណុចទាំង៤ខាងលើនេះ គឺជាមូលដ្ឋានគ្រឹះដ៏មានសារៈសំខាន់ដែលម្ចាស់បំណុល ចាំបាច់ត្រូវសរសេរឱ្យបានច្បាស់នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ។ រីឯអត្ថន័យដែលមាននៅក្នុងចំណុចនីមួយៗ នឹងគួរសរសេរបែបណានោះមានបញ្ជាក់តាមលំដាប់ដូចខាងក្រោម៖

### ១. ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុលត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់អំពីឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល ឬ អ្នកដាក់ពាក្យសុំ ថាតើនរណាជាអ្នកប្ដឹងសុំ ហើយរស់នៅកន្លែងណា ក្នុងករណីប្រសិនជាម្ចាស់បំណុលមិនដាក់ពាក្យសុំដោយផ្ទាល់ទេ ច្បាប់អនុញ្ញាតឱ្យម្ចាស់បំណុលជ្រើសរើសអ្នកតំណាងដែលច្បាប់បានកំណត់ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបាននៅក្នុងបណ្ដឹងអំពីសិទ្ធិដែលត្រូវបានរក្សាការពារដោយត្រូវមានលិខិតបញ្ជាក់ហើយត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងស្របច្បាប់នោះ[13] ។ ជាទូទៅ អ្នកតំណាងស្របច្បាប់ គឺមានតែជាមេធាវីតំណាងដោយអាណត្តិប៉ុណ្ណោះដែលអាចមានសិទ្ធិប្ដឹងសុំជំនួសទៅបាន ប៉ុន្តែអាចលើកលែងចំពោះករណីដែលបានកំណត់ដូចខាងក្រោម៖

- ករណីក្រមនេះ ឬ ច្បាប់ដ៏ទៃទៀត អនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្ដឹងជំនួសភាគី ។
- ករណីដែលភាគីជារដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬ ស្ថាប័នរដ្ឋដទៃទៀត និង ដែលស្ថាប័ននោះ ឬ អ្នកតំណាងនៃស្ថាប័ននោះ តែងតាំងបុគ្គលិកនៃស្ថាប័ននោះជាអ្នកតំណាង ។

[11] សូមមើល មាត្រា ៥៣៤-ក ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[12] មាត្រា ៥៤១-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[13] មាត្រា៥៤-២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- ករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជន ដែលមិនមែនជាមេធាវីក្នុងរឿងក្ដីដែលតម្លៃកម្មវត្ថុនៃបណ្ដឹងតិចជាង ១.០០០.០០០ (មួយលាន) រៀល[14] ។

សិទ្ធិដែលត្រូវបានផ្ដល់ឱ្យក្នុងការតំណាងដោយអាណត្តិឱ្យបុគ្គលណាម្នាក់ ឬ ច្រើននាក់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមរយៈលិខិតប្រគល់សិទ្ធិមានស្នាមមេដៃអ្នកប្រគល់សិទ្ធិ និងចុះហត្ថលេខាប្រថាប់ត្រារបស់មេធាវី ហើយត្រូវបានដាក់ចូលទៅតុលាការទើបអាចទទួលស្គាល់ និងយកជាការបាន ។ ម្យ៉ាងវិញទៀត ដើម្បីផ្ដល់ភាពងាយស្រួលក្នុងការទំនាក់ទំនងដែលស្របទៅនឹងភាពជឿនលឿននៃសង្គមផងនោះ ម្ចាស់បំណុលអាចដាក់លេខទូរស័ព្ទរបស់ខ្លួនសម្រាប់ទំនាក់ទំនងសរសេរភ្ជាប់នៅក្នុងពាក្យសុំ ពីព្រោះវាមានភាពងាយស្រួលក្នុងការជូនដំណឹងពីក្រឡាបញ្ជី ឬ អាជ្ញាសាលា។

## ២. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ

ខ្លឹមសារនៃដីកាសម្រេចរក្សាការពារមានសារៈសំខាន់ណាស់ដែលពុំអាចខ្វះបាន ជាគោលការណ៍ កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នត្រូវកំណត់ឱ្យបានជាក់លាក់ ។ ហេតុនេះ ម្ចាស់បំណុលត្រូវសរសេររៀបខ្លឹមសារនៃដីកាសម្រេចឱ្យបានច្បាស់លាស់ ពីព្រោះអត្ថន័យរបស់វាបានបញ្ជាក់អំពីប្រភេទនៃដីកាសម្រេចរក្សាការពារ និងការទាមទាររបស់ម្ចាស់បំណុលចង់ឱ្យតុលាការចេញដីកាសម្រេចប្រភេទណាមួយចំពោះកម្មវត្ថុជាក់លាក់ណាមួយ។ ប៉ុន្តែក្នុងករណីការទាមទារកម្មវត្ថុនោះជាចលនវត្ថុ ម្ចាស់បំណុលមិនចាំបាច់សរសេរជាក់លាក់អំពីចលនវត្ថុនីមួយៗនោះទេ ដោយគ្រាន់តែបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះ[15] ។ ចំពោះខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមានដូចខាងក្រោម៖

- ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ
- ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ
- ការរឹបអូសជាបណ្ដោះអាសន្នទៅលើសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត
- ការរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា

• នៅក្នុងរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

ឧទាហរណ៍៖ ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ "រឹបអូសជាបណ្ដោះអាសន្ននូវចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល រហូតដល់គ្រប់នឹងតម្លៃដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលមានចំពោះកូនបំណុល" ។

• នៅក្នុងរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

[14] មាត្រា ៥៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[15] សូមមើលមាត្រា ៥៤៦-២ និងមាត្រា ៥៦៥-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ឧទាហរណ៍៖ ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ "រឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលដែលមានប័ណ្ណសម្គាល់អចលនវត្ថុ០០១២៣២៤៣ ស្ថិតនៅភូមិក ផ្លូវ លេខ ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ"។

- នៅក្នុងរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល

ឧទាហរណ៍៖ ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ "រឹបអូសជាបណ្ដោះអាសន្ននូវសិទ្ធិលើបំណុលដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធដែលកូនបំណុលមានចំពោះកូនបំណុលទី៣ ដើម្បីរក្សាការពារការអនុវត្តសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានចំពោះកូនបំណុល" ។

### ៣. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

នៅត្រង់ចំណុចសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារត្រង់ចំណុចនេះ ម្ចាស់បំណុលត្រូវសរសេរនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬ អង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងកំណត់ចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ ។ ការសរសេររៀបរាប់អំពីអង្គហេតុនេះ គឺដើម្បីបង្ហាញពីសិទ្ធិ និងភាពចាំបាច់របស់ម្ចាស់បំណុលដែលមានទៅលើកូនបំណុល ក្នុងការទាមទារឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ។ នៅក្នុងអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺត្រូវសរសេរតែនៅក្នុងពាក្យបណ្ដឹងប៉ុណ្ណោះ ប៉ុន្តែដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចចេញមុនការដាក់ពាក្យបណ្ដឹង មានន័យថាសិទ្ធិ ឬ ទំនាក់ទំនងគិតយុត្តដែលនឹងត្រូវបានរក្សាការពារត្រូវសរសេរអត្ថន័យ និងខ្លឹមសារដូចជាការសរសេរនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារដែរ ដើម្បីឱ្យតុលាការយល់ឃើញថាម្ចាស់បំណុលមានសិទ្ធិទាមទារ។ ចំពោះការសរសេរអំពីចំនួនទឹកប្រាក់នៃសិទ្ធិទាមទារនេះវិញ គឺម្ចាស់បំណុលត្រូវរៀបរាប់អំពីចំនួនទឹកប្រាក់សរុបដែលកូនបំណុលបានជំពាក់រហូតមកដល់ថ្ងៃដាក់ពាក្យសុំថាមានទំហំបំណុលចំនួនប៉ុន្មាន ។

ឧទាហរណ៍៖ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ លោក A បានចុះថ្ងៃកិច្ចសន្យាទិញពេជ្រ ពីលោក B ចំនួន USD ១០,000 ដុល្លារអាមេរិក។ តែលោកA សុំបង់ប្រាក់បន្ថែមចំនួន USD ៥,000 ដុល្លារអាមេរិក នៅថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២១ ។ ប៉ុន្តែដល់ថ្ងៃកំណត់ប្រគល់ប្រាក់ថ្លៃទិញ លោក B មិនបានបង់ ហេតុនេះ លោក B បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ។

ដូច្នេះ អង្គហេតុនៃការទាមទារ គឺកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ លោក A បានចុះថ្ងៃកិច្ចសន្យាទិញពេជ្រ ពីលោក B ចំនួន USD ១០,000 ដុល្លារអាមេរិក។

### ៤. ភាពចាំបាច់នៃការរក្សាការពារ

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ភាគីម្ចាស់បំណុលត្រូវសរសេរបញ្ជាក់យ៉ាងណាឱ្យបានច្បាស់លាស់នូវភាពចាំបាច់ដែលត្រូវរក្សាការពារ ពីព្រោះវាអាចនឹងខុសគ្នាទៅតាមស្ថានភាព និងប្រភេទនៃដីកាសម្រេចនីមួយៗ ។ ភាពចាំបាច់ដែលនឹងត្រូវរក្សាការពារដែលត្រូវសរសេររៀបរាប់ គឺត្រូវពន្យល់ពីស្ថានភាព

ដែលម្ចាស់បំណុលកំពុងស្ថិតនៅក្នុងហានិភ័យលើទ្រព្យសម្បត្តិរបស់កូនបំណុល ឬ មានហានិភ័យដល់ការអនុវត្ត ដោយបង្ខំរបស់ម្ចាស់បំណុលហើយអំពីបញ្ហាប្រឈមផ្សេងៗ ប្រសិនជាតុលាការមិនចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលើទ្រព្យនោះជាបន្ទាន់ទៅដែលត្រង់កន្លែងនេះ ម្ចាស់បំណុលគប្បីត្រូវសរសេរបង្ហាញឱ្យឃើញពីភាពចាំបាច់ត្រូវរក្សាការពារដើម្បីអាចឱ្យតុលាការជឿជាក់ថានឹងអាចមានការខូចខាត ប្រសិនជាមិនមានការថែរក្សាការពារ ។

ភាពចាំបាច់ដែលត្រូវរក្សាការពារ មានច្រើនករណីដូចខាងក្រោម៖

- ស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលអាចនឹងធ្លាក់ថ្លៃ ជាបរិមាណ ឬ ជាគុណភាព ឬ ទ្រព្យសម្បត្តិនោះពិបាកប្ដូរជាប្រាក់ក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះនៅសល់ ការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ជាអាទិ៍ ។
- ករណីកូនបំណុលគេចខ្លួន ឬ ប្ដូរអាសយដ្ឋានជាញឹកញាប់ ។

ឧទាហរណ៍៖ លោកស្រី ក ជាកូនបំណុលបានជំពាក់ប្រាក់របស់ម្ចាស់បំណុលច្រើនណាស់ និងត្រូវយកលុយព្យាបាលជំងឺប្ដី ដោយលោកស្រី ក ត្រូវទទួលអំរែកសងប្រាក់កម្ចីទាំងនោះ ហើយគ្មានទ្រព្យសម្បត្តិអ្វីក្រៅពីដី និងផ្ទះទេ ចំណែកឯអាជីវកម្មរបស់លោកស្រី ក ក៏បិទលែងដំណើរការទៀត ។ ក្នុងករណីលោកស្រី ក លក់ដី និងផ្ទះនោះទៅឱ្យតតិយជនបាត់ហើយធ្វើការចាត់ចែងអស់ ។ លោក ខ ជាម្ចាស់បំណុល បារម្ភថាមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ។ ហេតុនេះ ប្រសិនជាបណ្ដោយឱ្យស្ថានភាពបច្ចុប្បន្នរបស់លោកស្រី ក ឱ្យនៅដដែលនោះ លោក ខ ពិបាកក្នុងការអនុវត្តដោយបង្ខំ ឬ មិនអាចអនុវត្តបាន ពីព្រោះ លោកស្រី ក អាចធ្វើអនុប្បទានដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ។

ដូច្នេះ លោក ខ អាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយត្រូវបញ្ជាក់ពីស្ថានភាពហានិភ័យលើទ្រព្យសម្បត្តិរបស់កូនបំណុល ដែលជាភាពចាំបាច់នៃការរក្សាការពារ ។

## ៥. ភស្តុតាងតាមអង្គហេតុនីមួយៗ

នៅពេលដែលម្ចាស់បំណុលបានសរសេររៀបរាប់នូវចំណុចស្ដីពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងចំណុចភាពចាំបាច់នៃការរក្សាការពាររួចហើយ ម្ចាស់បំណុលគប្បីត្រូវសរសេរចំណុចនេះឱ្យបានច្បាស់លាស់ និងសរសេរភស្តុតាងតាមអង្គហេតុនីមួយៗ[16] ។ ភស្តុតាងទាំងនោះជាឯកសារសេចក្ដីបញ្ជាក់ដំបូងដែលបញ្ជាក់ពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត និងភាពចាំបាច់នៃការរក្សាការពារ ដោយការយោងនេះវាបានផ្ដល់ប្រយោជន៍សម្រាប់តុលាការក្នុងស្វែងរកនូវទំនាក់ទំនងរវាងអង្គហេតុ និងភស្តុតាង ។ ឯកសារសម្រាប់ធ្វើសេចក្ដីបញ្ជាក់ដំបូងដែលម្ចាស់បំណុលត្រូវភ្ជាប់ជូនតុលាការមានដូចជា ៖ លិខិតកិច្ចសន្យាខ្ចីប្រាក់ , លិខិតយថាភូតនៃការចុះបញ្ជីអចលនវត្ថុ , រូបថត , ប័ណ្ណកម្មសិទ្ធិ ប័ណ្ណសម្គាល់អចលនវត្ថុ ជាអាទិ៍ ។

[16] មាត្រា៥៤១-២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ៦. ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំ

បន្ទាប់ពីសរសេរនូវចំណុចពាក្យសុំរួចរាល់អស់ហើយ ម្ចាស់បំណុលត្រូវភ្ជាប់នូវឯកសារជាភស្តុតាងដើម្បីអាចឱ្យតុលាការពិនិត្យទៅលើឯកសារទាំងអស់នោះ ដោយហេតុថានីតិវិធីនៃការចេញដីកាសម្រេចនេះ តុលាការមិនចាំបាច់សួរសាមីភាគី ឬធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទេ ពោលគឺតុលាការចាំបាច់ពិនិត្យទៅលើឯកសារដែលបានភ្ជាប់មកជាមួយពាក្យសុំប៉ុណ្ណោះ ដោយសារតែដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានលក្ខណៈបន្ទាន់បង្ខំ ។ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំរួមមាន ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង ឯកសារបញ្ជាក់អំពីសិទ្ធិតំណាងដោយអាណត្តិ ឯកសារបញ្ជាក់អំពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន និងឯកសារផ្សេងៗទៀត ។

- ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង គឺជាភស្តុតាងដែលអាចឱ្យតុលាការពិនិត្យបានភ្លាមៗក៏ព្រោះតែវាជាដំណាក់កាលបណ្តោះអាសន្ន និងបន្ទាន់ ។ ឯកសារដែលត្រូវភ្ជាប់ដែលម្ចាស់បំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង គឺឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត រួមមាន លិខិតកិច្ចសន្យាបរិភោគ , លិខិតយថាភូតនៃការចុះបញ្ជីអចលនវត្ថុ , ប័ណ្ណកម្មសិទ្ធិ មតកសាសន៍ បង្កាន់ដៃ មូលប្បទាន និងឯកសារដែលបញ្ជាក់ពីភាពចាំបាច់នៃរក្សាការពារ ម្ចាស់បំណុលត្រូវផ្តល់ឯកសារចាំបាច់ និងសរសេររៀបរាប់ពីស្ថានភាពរបស់កូនបំណុលដែលបានជំពាក់ប្រាក់គេជាច្រើននាក់ អាជីវកម្មត្រូវបានក្ស័យធន ក្រុមគ្រួសារកើតជំងឺធ្ងន់ធ្ងរត្រូវការប្រាក់សម្រាប់ព្យាបាលជាបន្ទាន់ ដែលបង្ហាញពីភាពចាំបាច់របស់ម្ចាស់បំណុលពិបាកនឹងអនុវត្តដោយបង្ខំ ដើម្បីតុលាការពិចារណាចាត់វិធានរក្សាការពារ ។
- ឯកសារបញ្ជាក់អំពីសិទ្ធិតំណាងដោយអាណត្តិ គឺម្ចាស់បំណុលដែលជ្រើសរើសអ្នកតំណាងដោយអាណត្តិ ត្រូវភ្ជាប់នូវឯកសារលិខិតប្រគល់សិទ្ធិក្នុងពាក្យសុំរវាងម្ចាស់បំណុល និងមេធាវី ឬ អ្នកដែលច្បាប់បានកំណត់ ដើម្បីមានសិទ្ធិធ្វើសកម្មភាពបណ្តឹងជំនួសបាននូវចំពោះមុខតុលាការ ។
- ឯកសារបញ្ជាក់អំពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺម្ចាស់បំណុលត្រូវបញ្ជាក់យ៉ាងណាថាកម្មវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ននោះជាកម្មសិទ្ធិរបស់កូនបំណុល ដើម្បីអាចឱ្យតុលាការដឹងថាទ្រព្យមួយណាដែលនឹងត្រូវរឹបអូស ។
- ឯកសារផ្សេងៗ គឺម្ចាស់បំណុលត្រូវភ្ជាប់មកជាមួយពាក្យសុំ រួមមាន ឯកសារបញ្ជាក់ពីភាគី លិខិតបញ្ជាក់របស់នីតិបុគ្គលដើម្បីបញ្ជាក់ពីសកម្មភាពធ្វើជាភាគី ឯកសារបញ្ជាក់ពីអ្នកដែលច្បាប់បានកំណត់ ឬ ឯកសារបញ្ជាក់ហិតូបត្ថម្ភកៈជាដើម ។

## កថាភាគីទី២. សោហ៊ុយនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

សោហ៊ុយសម្រាប់ការចំនាយមុន នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលម្ចាស់បំណុលត្រូវបង់ទៅតុលាការមានពីរគឺ៖

- ពន្ធដាក់ពាក្យសុំ
- ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ។

### ១. ពន្ធដាក់ពាក្យសុំ

ក្នុងនីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចត្រូវបង់ពន្ធចំនួន ៥.០០០រៀល ទៅតុលាការ[17] ។ ពន្ធពាក្យសុំខាងលើត្រូវបង់ជាដាច់ខាត ក្នុងករណីពន្ធពាក្យសុំខាងលើមិនត្រូវបានបង់ទេ តុលាការនឹងបង្គាប់ម្ចាស់បំណុលឱ្យបង់ពន្ធនៅក្នុងអំឡុងពេលសមរម្យ[18] ។ ហើយប្រសិនជាម្ចាស់បំណុលមិនបង់ពន្ធពាក្យសុំតាមការបង្គាប់របស់តុលាការទេ នាំឱ្យពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវលើកចោលដោយដីកាសម្រេច[19] ។

### ២. ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

ក្រៅពីការបង់ពន្ធដាក់ពាក្យសុំ ម្ចាស់បំណុលត្រូវបង់ពន្ធផ្សេងទៀតដែលជាប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ សម្រាប់ការចំនាយក្នុងការប្រើប្រាស់របស់តុលាការក្នុងការបញ្ជូនឯកសារទៅកូនបំណុល ជាអាទិ៍ ។ ចំពោះចំនួនទឹកប្រាក់ដែលត្រូវបង់សម្រាប់នីតិវិធីនៅតុលាការ គឺត្រូវបានកំណត់ដោយតុលាការមានដូចខាងក្រោម៖

- ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូន ឯកសារ ឬសកម្មភាពផ្សេងទៀតតាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី ។
- ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីដែលត្រូវចេញទៅក្រៅតុលាការ ។

### ៣. បន្ទុកនៃប្រាក់ប្រដាប់ក្ដី

បន្ទុកនៃការបង់ប្រាក់ប្រដាប់ក្ដី ម្ចាស់បំណុលជាអ្នកដាក់ពាក្យឱ្យចេញសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺត្រូវទទួលបន្ទុកបង់ ដូច្នេះវាមិនបានធ្វើឱ្យមិនប៉ះពាល់ដល់បណ្ដឹងអង្គសេចក្ដីទេ ។ ជាការពិតណាស់បណ្ដឹងអង្គសេចក្ដី ជាទូទៅភាគីអ្នកចាញ់ក្ដីជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី[20] ។ ដោយសារតែតុលាការនៅក្នុងរឿងក្ដីរដ្ឋប្បវេណីជាតុលាការអកម្ម ហេតុនេះម្ចាស់បំណុលគួរណាតែស្នើសុំបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្ដីនៅក្នុងពាក្យសុំ ឬ បណ្ដឹងរបស់ខ្លួនជាមុននៅក្នុងពាក្យសុំដើម្បីអាចឱ្យតុលាការធ្វើការវិនិច្ឆ័យ ។ តាមការអនុវត្តជាក់

[17] សូមមើលមាត្រា ៥៣៧-១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[18] សូមមើលមាត្រា ៥៣៩-១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[19] មាត្រា ៧៨-២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[20] មាត្រា ៦៤-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ស្តែងការបង់ប្រាក់ប្រដាប់ក្តីតុលាការចេញដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធចំនួនពី១៥ម៉ឺន ទៅ ២០ ម៉ឺន រៀល។

## កថាភាគីទី៣ នីតិវិធីនៃការពិនិត្យពាក្យសុំ និងការវិនិច្ឆ័យ

### ១. នីតិវិធីនៃការពិនិត្យពាក្យសុំ

នៅពេលដែលបានទទួលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការទទួលបន្ទុកលើបណ្តឹងនឹងត្រូវពិនិត្យលើពាក្យសុំត្រឹមត្រូវតាមទម្រង់ដែរ ឬទេ ហើយប្រសិនជាមានចំណុចខ្វះខាត តុលាការត្រូវបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនោះ ដោយទុកក្នុងអំឡុងពេលសមរម្យមួយ [21] ។ ក្នុងករណីម្ចាស់បំណុលពុំបានសរសេរតាមការបង្គាប់ឱ្យកែតម្រូវពាក្យសុំនោះទេ ពាក្យសុំនោះនឹងត្រូវបានលើកចោល ។ ហើយតុលាការក៏ត្រូវពិនិត្យទៅលើសមត្ថកិច្ចរបស់តុលាការលើពាក្យសុំចេញដីកាសម្រេចនោះថាមានសមត្ថកិច្ច ឬ គ្មាន ប្រសិនតុលាការយល់ឃើញថា កង្វះសមត្ថកិច្ចចំពោះរឿងក្តី ចៅក្រមមានឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំរបស់ម្ចាស់បំណុលដោយអាចផ្ទេរសំណុំរឿងនោះទៅតុលាការដែលមានសមត្ថកិច្ច។ ពន្ធលើពាក្យសុំ ក៏ជាចំណុចចាំបាច់ដែលតុលាការត្រូវពិនិត្យថាតើម្ចាស់បំណុលបានបង់ពន្ធលើពាក្យសុំរួចហើយ ឬ នៅ ។ ប្រសិនជាមិនទាន់បានបង់ទេ តុលាការត្រូវបង្គាប់ឱ្យម្ចាស់បំណុលធ្វើការបង់ក្នុងអំឡុងពេលសមរម្យមួយ ក្នុងករណីមិនបានបង់តាមការបង្គាប់ទេ ពាក្យសុំត្រូវបានលើកចោល [22] ។

ចំពោះការពិនិត្យទៅលើរឿងក្តី តុលាការនឹងពិនិត្យលើឯកសារសេចក្តីបញ្ជាក់ដំបូង និងឯកសារផ្សេងៗទៀតដែលម្ចាស់បំណុលបានដាក់ភ្ជាប់មក ជាមួយពាក្យសុំដើម្បីអាចឱ្យតុលាការស្វែងយល់ពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត មានដែរ ឬ អត់ និងភាពចាំបាច់នៃការរក្សាការពារ តើមានភាពចាំបាច់ដែរ ឬ ទេ ដូច្នេះតុលាការនឹងបង្គាប់ឱ្យម្ចាស់បំណុលធ្វើសេចក្តីបញ្ជាក់ដំបូងដែលវាមានសារៈសំខាន់ណាស់ សម្រាប់ឱ្យតុលាការយល់ថាអង្គហេតុនោះទំនងជាមាន។ សេចក្តីបញ្ជាក់ដំបូងនេះ ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចឱ្យតុលាការពិនិត្យភ្លាមៗបាន ក៏ព្រោះតែវាជាដំណាក់បណ្តោះអាសន្ន និងបន្ទាន់ ។ លើសពីនេះ នៅក្នុងនីតិវិធីធ្វើសេចក្តីបញ្ជាក់ដំបូងមិនមែនកំណត់តែភស្តុតាងជាឯកសារ ប៉ុណ្ណោះទេ ប៉ុន្តែ ក៏មានការសាកសួរភាគីដែរ ប្រសិននៅពេលដែលមានវត្តមានរបស់ភាគី គឺអាចសួរបានយ៉ាងឆាប់រហ័ស ពោលគឺតុលាការអាចហៅម្ចាស់បំណុលមកសួរបានទាក់ទងព័ត៌មានបន្ថែម ឬ អាចឱ្យឆ្លើយធ្វើជាលាយលក្ខណ៍អក្សរក៏បាន ហើយបង្គាប់ឱ្យម្ចាស់បំណុលដាក់ឯកសារបន្ថែមទៀត ហៅសួរនេះ គឺធ្វើនៅបន្ទប់ធម្មតា ដោយមិនចាំបាច់ធ្វើកំណត់ហេតុនោះទេ ។ ការហៅសួរនេះ គ្រាន់តែតុលាការចង់ឱ្យម្ចាស់បំណុលធ្វើសេចក្តីបញ្ជាក់ខ្លឹមសារបន្ថែមលើពាក្យសុំ ឬ ភស្តុតាងជាឯកសារ ហើយវិធីនេះក៏មិនដាច់ខាតត្រូវតែតម្រូវឱ្យធ្វើនោះដែរ ។ ក្រៅពីសួរម្ចាស់បំណុល កូនបំណុលក៏អាចត្រូវបានហៅមកសួរផងដែរ ក្នុងករណីតុលាការឃើញថានឹងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់កូនបំណុល ឬ រឿងក្តីមានលក្ខណៈស្មុគស្មាញ ដែលតុលាការជឿកជាក់ថា កូនបំណុលអាចនឹងតវ៉ានឹងពាក្យសុំបានផ្តល់ឱកាសដល់កូនបំណុលអះអាង និងអាចធ្វើ

---

[21] មាត្រា ៧៨ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[22] សូមមើលមាត្រា ៥៣៩ និងមាត្រា៧៨ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

សេចក្ដីបញ្ចាក់ដំបូង ។ នៅក្នុងដំណើរការនីតិវិធីនៃរឿងក្ដីរក្សាការពារ ជាទូទៅតុលាការមិនចាំបាច់ សួរភាគី ឬទាញហេតុផលដោយផ្ទាល់មាត់ទេ ប៉ុន្តែប្រសិនជារឿងក្ដីនោះមានលក្ខណៈពិបាក និងស្មុគស្មាញខ្លាំង តុលាការអាចជ្រើសរើសយកនីតិវិធីទាញហេតុផលដោយផ្ទាល់ ធ្វើឡើងជាសាធារណៈ និងត្រូវធ្វើកំណត់ហេតុ ។ បន្ទាប់ពីបញ្ចប់នីតិវិធីរួច តុលាការនឹងត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលចរិតលក្ខណៈដីកាសម្រេចនេះមានទាមទារឱ្យធ្វើឡើងជាលក្ខណៈសម្ងាត់ បន្ទាន់បង្ខំ ។

ដូច្នេះ តុលាការចាំបាច់សួរតែភាគីម្ចាស់បំណុលប៉ុណ្ណោះ ដោយបារម្ភខ្លាចកូនបំណុលបង្កការលំបាកដល់ការអនុវត្តដោយបង្ខំ លួចលាក់ ឬ បញ្ចៀសទ្រព្យសម្បត្តិតាមវិធីការពារណាមួយបាត់ ។

### ២. ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ក្រោយពីបានពិនិត្យទៅលើពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការអាចចេញដីកាសម្រេចឱ្យរឹបអូសជាបណ្ដោះអាសន្នតាមពាក្យសុំរបស់ម្ចាស់បំណុល ឬ ក៏អាចលើកពាក្យសុំនោះចោលក៏មាន ។ នៅក្នុងការចេញដីកាសម្រេចនេះ តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ឬ មិនដាក់បាន គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ហើយអាចឱ្យដាក់ប្រាតិភោគនេះមុនពេលចេញ ឬ ដំណាលពេលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬមុនពេលអនុវត្តការរឹបអូសជាបណ្ដោះអាសន្នផងដែរ ។

# ជំពូកទី២
# ប្រភេទដីកាសម្រេច និងការអនុវត្តការ
# រឹបអូសជាបណ្ដោះអាសន្ន

# ជំពូកទី២
# ប្រភេទដីកាសម្រេច និងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអាចចេញបានលុះត្រាតែមានពាក្យសុំ និងការគោរពទៅតាមលក្ខខណ្ឌនៃនីតិវិធីច្បាប់កំណត់ ។ ហើយការសម្រេចសេចក្តីលើពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះផងដែរ គឺត្រូវធ្វើឡើងដោយដីកាសម្រេចរក្សាការពារ[23] ។

## ផ្នែកទី១ ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ គឺមានលក្ខណៈដូចគ្នាទៅនឹងការចាត់ចែងរក្សាការពារដែរ ហេតុនេះដីកាសម្រេចរក្សាការពារមានពីរប្រភេទធំៗមានដូចខាងក្រោម៖

- ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
- និងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។ ហើយដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នត្រូវបានចែកចេញជាពីរទៀត គឺដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។

នៅត្រង់ជំពូកនេះ ដើម្បីឆ្លើយតបនឹងប្រធានបទសារណាខាងលើ នាងខ្ញុំសូមលើកយកតែដីកាសម្រេចរក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្នមកបកស្រាយប៉ុណ្ណោះ ។

## ផ្នែកទី២. ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺជាដីកាសម្រេចដែលមានគោលបំណងឱ្យសងជាប្រាក់ ។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះមិនអាចចេញបានឡើយ ប្រសិនបើខ្វះលក្ខខណ្ឌសម្រាប់ធ្វើបណ្តឹង ដូចជាគ្មានលក្ខណៈគ្រប់គ្រាន់ជាសមត្ថភាពភាគី និងលក្ខណៈសម្បត្តិជាភាគី និងខ្វះលក្ខខណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន ។ ក្នុងករណីដែលខ្វះលក្ខខណ្ឌណាមួយ សម្រាប់ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នពាក្យសុំនោះនឹងត្រូវបានលើកចោល ។

### កថាភាគទី១. ចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ជាការពិតណាស់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការទទួលបន្ទុកក្នុងសំណុំរឿងមិនអាចចេះតែសរសេរទៅតាមការស្រម៉ៃនឹកឃើញ ឬ ចង់បានដោយគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវឡើយ ពោលគឺត្រូវតែគោរពតាមចំណុចនីមួយៗដែលច្បាប់បានកំណត់ដូចខាងក្រោម ៖

#### ១. ភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្តី

ភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្តី មុនពេលចេញដីកាសម្រេចរក្សារឹបអូសជាបណ្តោះអាសន្ន គឺមានចំណុច

[23] មាត្រា ៥៣៥-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

សំខាន់ៗដែលតុលាការចាំបាច់ត្រូវសរសេរបញ្ជាក់នៅក្នុងរឿងក្ដីដែលនឹងត្រូវសរសេរនោះរួមមានៈ អត្តសញ្ញាណភាគី សញ្ញាណសិទ្ធិលើបំណុលដែលទាមទារ ព័ត៌មានអំពីកម្មវត្ថុដែលត្រូវបានរក្សាការពារ និងលេខសំណុំរឿង ។

- អត្តសញ្ញាណភាគី គឺជាចំណុចសំខាន់មួយដែលចាំបាច់ត្រូវបញ្ជាក់នៅក្នុងរឿងក្ដី ពីព្រោះវាបង្ហាញអំពីព័ត៌មានរបស់ភាគី តើភាគីមានឈ្មោះអ្វី និងអាសយដ្ឋាននៅទីណា ឬ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។
- សញ្ញាណសិទ្ធិលើបំណុលដែលទាមទារ គឺក៏ជាចំណុចសំខាន់មួយដែលចាំបាច់ត្រូវបញ្ជាក់នៅក្នុងរឿងក្ដីផងដែរ ដោយមូលហេតុថាអាចឱ្យយើងដឹងទាក់ទងសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានលើកូនបំណុល ថាតើវាមានទំហំនៃបំណុលកម្រិតប៉ុន្មានដែលត្រូវបានរក្សាការពារ។
- ព័ត៌មានអំពីកម្មវត្ថុត្រូវបានរក្សាការពារ ក៏អាចជាចំណុចសំខាន់ដែលចាំបាច់ត្រូវបញ្ជាក់នៅក្នុងរឿងក្ដី ដោយសារតែអាចឱ្យយើងដឹងអំពីគោលបំណងរបស់ម្ចាស់បំណុល ក្នុងការស្នើសុំរក្សាការ ពារលើកម្មវត្ថុមួយនាដែលខ្លួនចង់ឱ្យតុលាការចេញរឹបអូសជាបណ្ដោះអាសន្ន ។
- លេខសំណុំរឿង សំដៅលើលេខសម្រាប់សម្គាល់រឿងក្ដី និងចៅក្រមណាជាទទួលបន្ទុកក្នុងរឿងក្ដីរក្សាការពារនោះងាយស្រួលសម្រាប់ឱ្យម្ចាស់បំណុល ឬ អ្នកតំណាងស្របច្បាប់ ទទួលបានព័ត៌មាន ឬ តាមដានដំណើររឿងក្ដី ។

ដូច្នេះ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចចេញបានដោយមានការដាក់ពាក្យសុំហើយត្រូវតែជាដីកាសម្រេចដែលទាក់ទងនឹងពាក្យសុំដែលបានដាក់ពាក្យសុំ ។ លើសពីនេះ ប្រសិនបើមិនអាចបញ្ជាក់អំពីអត្តសញ្ញាណនៃរឿងក្ដីបានទេនោះនាំឱ្យដីកាសម្រេចក៏មិនអាចសរសេរនូវចំណុចសំខាន់ៗដើម្បីបញ្ជាក់រឿងក្ដីបានដែរ ។ តាមការអនុវត្តជាក់ស្ដែង ចំពោះខ្លឹមសារសម្រាប់ការសរសេរដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមានពីរជម្រើសៈ

- ចៅក្រមអាចសរសេរនូវអត្ថន័យ ទាំងមូលនៃភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដីនៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតែម្ដងក៏បាន ប៉ុន្តែវាអាចនឹងមានផលវិបាកដោយហេតុថាធ្វើឱ្យដីកាសម្រេចនោះវែង និងចំនាយពេលវេលាវែងច្រើន ។
- ចៅក្រមអាចសរសេរនូវអត្ថន័យ ក្នុងទម្រង់សង្ខេបលើភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដី ។ បន្ថែមពីនេះ ចៅក្រមអាចប្រើបញ្ជីដែលពិពណ៌នាភាគី បញ្ជីសិទ្ធិលើបំណុល និងបញ្ជីទ្រព្យសម្បត្តិដែលបានពីឯកសារភ្ជាប់ពាក្យសុំរបស់ម្ចាស់បំណុលដែលបានដាក់មក និងបញ្ជាក់អំពីរឿងក្ដីភ្ជាប់មកជាមួយនឹងបញ្ជីទាំងនោះ ទៅនឹងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតែម្ដង ។ គុណប្រយោជន៍នៃការសរសេរសង្ខេបដីកាសម្រេចនេះ គឺចំណេញពេលវេលាក្នុងការសរសេរ ពីព្រោះការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺត្រូវមានភាពឆាប់រហ័សដើម្បីទប់ស្កាត់ទ្រព្យរបស់កូន

បំណុលនឹងអាចធ្វើ ចាត់ចែងទៅតតិយជនបាត់ ដែលនាំឱ្យខូចខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ម្ចាស់បំណុល ។

**២. ការសរសេរបញ្ជាក់នូវកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

ជាគោលការណ៍ តុលាការនឹងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់នូវកម្មវត្ថុឱ្យបានជាក់លាក់ ពោលគឺភាពជាក់លាក់នូវកម្មវត្ថុលើអចលនវត្ថុ ប៉ុន្តែប្រសិនជាកម្មវត្ថុដែលត្រូវរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុវិញ តុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយមិនចាំបាច់កំណត់កម្មវត្ថុទេ[24] ។ តុលាការអាចពិនិត្យមើលអំពីព័ត៌មានសំខាន់ៗលើឯកសារ ដែលម្ចាស់បំណុលបានដាក់ភ្ជាប់ជាមួយពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះដោយបង្ហាញអំពីព័ត៌មាននៃទ្រព្យសម្បត្តិរបស់កូនបំណុលមែន ហើយលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់កូនបំណុលចំពោះទ្រព្យសម្បត្តិ មានដូចជា ដី ឬ ផ្ទះ ឬ អគារ មានទំហំប្រវែងប៉ុន្មាននៅទីតាំងណា និយាយរួមព័ត៌មាននោះ គឺសំដៅលើប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុដែលជាឯកសារចេញដោយការិយាល័យភូមិបាល ក្នុងករណីម្ចាស់បំណុលអាចរកឯកសារទាំងនោះបាន ។ ប៉ុន្តែផ្ទុយមកវិញ ប្រសិនបើម្ចាស់បំណុលមិនអាចរកឯកសារទាំងនោះដាក់ជូនតុលាការបានទេ អាចរកតាមមធ្យោបាយផ្សេងៗទៀត ដែលតុលាការអាចទទួលយកបាន គឺតាមការបញ្ជាក់ពីមេភូមិ ឬ ចៅសង្កាត់ជាដើម ។

**កថាភាគទី២ លក្ខខណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

មុនពេលដែលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការចាំបាច់ពិចារណាឱ្យបានច្បាស់លាស់ជាមុនសិន ដោយមិនចេះតែចេញដីកាសម្រេចតាមពាក្យសុំរបស់ម្ចាស់បំណុលតែម្តងនោះទេ គឺតុលាការនឹងពិនិត្យទៅលើពាក្យសុំនោះ តើមានមូលដ្ឋានស្របតាមទម្រង់ដែលច្បាប់បានកំណត់ដែរ ឬ ទេ ។ ម៉្យាងវិញទៀត តុលាការ ត្រូវពិនិត្យទៅលើចំណុចសិទ្ធិដែលត្រូវបានរក្សាការពារ និងភាពចាំបាច់ក្នុងការរក្សាការពារ ចំណុចទាំងពីរនេះឱ្យបានល្អិតល្អន់ ដែលជាលក្ខខណ្ឌក្នុងការឱ្យតុលាការជឿជាក់និងអាចវិនិច្ឆ័យតាមអ្វីដែលម្ចាស់បំណុលបានអះអាង និងភស្តុតាងដែលដាក់ជូនតុលាការ ។

**១. សិទ្ធិដែលត្រូវបានរក្សាការពារចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

សិទ្ធិដែលត្រូវបានរក្សាការពារនេះវាអាចនឹងខុសគ្នា អាស្រ័យទៅតាមប្រភេទនៃដីកាសម្រេចរក្សាការពារដែលមានគោលបំណងទាមទារខុសៗពីគ្នា ។ សិទ្ធិដែលត្រូវបានរក្សាការពារចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចាំបាច់ ត្រូវតែជាសិទ្ធិទាមទារដែលម្ចាស់បំណុលមានគោលបំណងទាមទារឱ្យកូនបំណុលសងជាប្រាក់[25] ។ ចំពោះម្ចាស់បំណុលដែលមានសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ប្រសិនជាមានគោលបំណងឱ្យសងជាប្រាក់អាចស្នើសុំដីកាសម្រេចតាមរយៈការរឹបអូសជាបណ្តោះអាសន្នបានផងដែរ ។ ហើយសិទ្ធិទាមទារដែលត្រូវបានរក្សាការពារអាចជាសិទ្ធិដែលមានភ្ជាប់នឹងលក្ខខណ្ឌ ឬ ពេលកំណត់ ករណីនេះម្ចាស់បំណុលអាចសុំចេញដីកាសម្រេចរឹបអូស

[24] មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[25] សូមមើលមាត្រា ៥៤៥-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ជាបណ្ដោះអាសន្នបាន[26] ។ ប៉ុន្តែចំពោះសិទ្ធិទាមទារដែលភ្ជាប់នឹងលក្ខខណ្ឌបង្អង់ចាំបាច់មានអត្ថិភាពនៃមូលដ្ឋាននៃសិទ្ធិ ។ លើសពីនេះ សិទ្ធិទាមទារដែលភ្ជាប់នឹងកិច្ចសន្យាមជ្ឈត្តកម្ម ឬ សិទ្ធិទាមទារដែលស្ថិតក្រោមសិទ្ធិជម្រះក្ដីរបស់តុលាការបរទេស ជាអាទិ៍ ក៏អាចធ្វើការរឹបអូសជាបណ្ដោះអាសន្នបានដែរ ដោយផ្អែកលើភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ។

**២. ភាពចាំបាច់នៃការរក្សាការពារចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មិនពឹងផ្អែកទៅលើលក្ខខណ្ឌនៃសិទ្ធិដែលត្រូវបានរក្សាការពារតែមួយចំណុចទេ ពោលគឺត្រូវផ្អែកទៅលើភាពចាំនៃការរក្សាការពារដែលជាលក្ខខណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលភាពចាំបាច់នោះវាអាស្រ័យទៅប្រភេទនៃដីកាសម្រេចផងដែរ ។ នៅក្នុងករណីដែលម្ចាស់បំណុលមានការបារម្ភថា ការអនុវត្តដោយបង្ខំនាពេលអនាគត នឹងមិនអាចធ្វើបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ប្រសិនជាបណ្ដោយឱ្យស្ថានភាពនោះស្ថិតនៅដដែល ដូច្នេះ ត្រូវចាត់ទុកថាពិតជាមានភាពចាំបាច់ត្រូវរក្សាការពារ ។ ការរក្សាការពារដែលមានចាំបាច់ គឺទាក់ទងស្ថានភាពទ្រព្យសម្បត្តិរបស់បំណុលអាចនឹងធ្លាក់ថ្លៃ ឬ បរិមាណ ទាក់ទងនឹងការចាយវាយខ្ជះខ្ជាយ កូនបំណុលគេចខ្លួនទៅបរទេស ជាដើម ។ ចំណុចដែលមិនមែនជាភាពចាំបាច់នៃការរក្សាការពារដូចជា មិនព្រមអនុវត្តកាតព្វកិច្ច អសាធនភាព ជាអាទិ៍ ។

**កថាភាគទី៣. ប្រាតិភោគនៃការរឹបអូសជាបណ្ដោះអាសន្ន**

នៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការអាចធ្វើដោយបង្គាប់ឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន [27] ។ តុលាការមានឆន្ទានុសិទ្ធិក្នុងសម្រេចឱ្យម្ចាស់បំណុល ដាក់ប្រាតិភោគ ឬ មិនគួរដាក់ប្រាតិភោគ មានន័យថា ការដាក់ប្រាតិភោគនេះ គឺជាលក្ខខណ្ឌមួយដើម្បីអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ពីព្រោះ ជាគោលការណ៍ តុលាការអាចចេញដីកាសម្រេចបានដោយមិនចាំបាច់សួរកូនបំណុលទេ ដោយគ្រាន់តែសម្រេចតាមសេចក្ដីបញ្ជាក់ដំបូងជាការគ្រប់គ្រាន់ ។ ប៉ុន្តែនៅក្នុងករណីខ្លះ ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ មុនពេលដែលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នផងដែរ ដើម្បីការពារនៅពេលមានការខូចខាតរបស់កូនបំណុល ។ យ៉ាងណាមិញ តុលាការក៏អាចត្រូវឱ្យកូនបំណុលដាក់ប្រាតិភោគបានដែរ នៅពេលដែលតុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បន្ទាប់ពីតុលាការចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ។ លើសពីនេះតុលាការក៏អាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ជាលក្ខខណ្ឌសម្រាប់ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នបានផងដែរ ។

---

[26] មាត្រា ៥៤៥-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[27] សូមមើលមាត្រា ៥៤២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ដូច្នេះ យើងអាចសន្និដ្ឋានបានថា ប្រាតិភោគ គឺជាប្រព័ន្ធធានាសំណងនៃការខូចខាតចំពោះកូនបំណុល នៅពេលដែលម្ចាស់បំណុលចាញ់បណ្តឹងអង្គសេចក្តី ។

ឧទាហរណ៍៖ លោក ពិសាល ជាម្ចាស់បំណុល បានដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើដីរបស់ លោកស្រី គន្ធា ដោយផ្អែកលើសិទ្ធិលើបំណុលក្នុងករណីនេះតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ មុននឹងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ប៉ុន្តែក្រោយមក តុលាការបានចេញនូវសេចក្តីសម្រេចមានខ្លឹមសារថាម្ចាស់បំណុលចាញ់ក្នុងបណ្តឹងអង្គសេចក្តី ។ ហេតុនេះប្រសិនបើម្ចាស់បំណុល លោក ពិសាល ចាញ់ក្តី លោកស្រី គន្ធា ដែលជាកូនបំណុលអាចទាមទារនូវសំណងនៃការខូចខាត និងជំងឺចិត្តពីលោក ពិសាល បានដោយផ្អែកលើអំពើអនីត្យានុកូល ហើយប្រសិនជាលោកស្រី គន្ធា ឈ្នះក្តីក្នុងការទាមទារសំណងនៃការខូចខាត និងអាចដាក់បណ្តឹងអនុវត្តចំពោះទ្រព្យសម្បត្តិរបស់ម្ចាស់បំណុលជាកម្មវត្ថុនៃប្រាតិភោគដែលបានដាក់ក្នុងសំណុំរឿងរក្សាការពារ។ លើសពីនេះ លោកស្រី គន្ធា នឹងទទួលបានការសងមានអាទិភាពចំពោះប្រាតិភោគដែលបានតម្កល់នោះ[28] ។

## ១. គោលបំណងនៃប្រាតិភោគ

ក្នុងករណីខ្លះ តុលាការយល់ឃើញថាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់កូនបំណុល ជាហេតុនាំឱ្យតុលាការបង្គាប់ម្ចាស់បំណុលឱ្យដាក់ប្រាតិភោគ។ គោលបំណងនៃការដាក់ប្រាតិភោគ គឺជាការទប់ស្កាត់ពីការប្រើប្រាស់សិទ្ធិហួសប្រមាណរបស់ម្ចាស់បំណុល ។ មានន័យថា ម្ចាស់បំណុលមិនអាចចង់ដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតាមតែទំនើងចិត្ត និងតាមការនឹកឃើញរបស់ខ្លួនបានទេ ហើយប្រសិនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះមានភាពខុសពីការពិត ដូច្នេះម្ចាស់បំណុលត្រូវប្រាតិភោគដើម្បីជាការធានាសំណងដល់ការខូចខាតរបស់កូនបំណុល ។ យ៉ាងណាមិញក៏មានការលំបាកសម្រាប់កូនបំណុលដែរក្នុងការទាមទារសំណង នៅពេលការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមួយចំនួនមិនបានបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ ។

## ២.ចំនួននៃប្រាតិភោគ

ប្រសិនបើតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគនោះ តុលាការខ្លួនឯងក៏ត្រូវពិចារណាលើទំហំនៃការខូចខាតដែលនឹងកើតឡើងជាយថាហេតុលើកូនបំណុល និងកំណត់ចំនួនប្រាតិភោគឱ្យបានល្អិតល្អន់ ពីព្រោះថាការវាយតម្លៃពីសំណាក់តុលាការនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ បន្ទាប់ពីការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលទាមទារឱ្យតុលាការមានបទពិសោធន៍លើវាយតម្លៃក្នុងការកំណត់ចំនួនដែលត្រូវដាក់ប្រាតិភោគ ហើយនៅពេលដែលមានការខូចខាតរបស់កូនបំណុលនាពេលអនាគតការតបស្នងនៃការខូចខាតនោះ គឺត្រូវ

[28] មាត្រា ៥៣៩ និងមាត្រា ៧២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ធ្វើការសងជាតម្លៃវិញបានតាមរយៈការដាក់ប្រាតិភោគ ។ មូលដ្ឋាននៃការកំណត់ចំនួននៃប្រាតិភោគត្រូវបានកំណត់ដោយផ្អែកលើលក្ខខណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានដូចខាងក្រោម៖

- កម្មវត្ថុនៃរឹបអូសជាបណ្តោះអាសន្ន: តុលាការត្រូវពិចារណាដល់ប្រភេទនៃកម្មវត្ថុនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នសំដៅដល់សិទ្ធិលើបំណុល ឬ លើទ្រព្យសម្បត្តិផ្សេងទៀត ចលនវត្ថុ អចលនវត្ថុ នានា ។
- សិទ្ធិលើបំណុលរបស់ម្ចាស់បំណុល: តុលាការក៏ត្រូវគិតអំពីចំនួនទឹកប្រាក់ដែលម្ចាស់បំណុលមានសិទ្ធិទៅលើកូនបំណុលមានចំនួនសរុបប៉ុន្មាន ។
- សេចក្តីបញ្ជាក់ដំបូង: តុលាការនឹងពិនិត្យលើឯកសារនៃសេចក្តីបញ្ជាក់ដំបូង ឬ ក៏អាចសួរម្ចាស់បំណុល កូនបំណុល ឬ ពិនិត្យឯកសារផ្សេងៗទៀត ។ ក្នុងករណីការធ្វើសេចក្តីបញ្ជាក់ដំបូងមានលក្ខណៈរឹងមាំ នោះនឹងនាំឱ្យចំនួនប្រាតិភោគដែលត្រូវដាក់មានចំនួនទាប ឬ តិចតួច ។ ផ្ទុយមកវិញប្រសិនបើ សេចក្តីបញ្ជាក់ដំបូងនោះធ្វើឡើងមិនរឹងមាំវិញ ម្ចាស់បំណុលនឹងតម្រូវឱ្យដាក់ប្រាតិភោគក្នុងកម្រិតខ្ពស់ ឬ ច្រើន ។

### ៣. វិធីនៃការដាក់ប្រាតិភោគ

ការដាក់ប្រាតិភោគក៏អាចជាលក្ខខណ្ឌមួយដើម្បីអាចអនុវត្តរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវដាក់ប្រាតិភោគឱ្យបាននូវមុនពេលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ហើយប្រសិនជាម្ចាស់បំណុលមិនដាក់ប្រាតិភោគការអនុវត្តរឹបអូសជាបណ្តោះអាសន្នក៏មិនអាចធ្វើទៅបានដែរ ។ ម៉្យាងវិញទៀត ក្នុងករណីម្ចាស់បំណុលបានដាក់ប្រាតិភោគរួចហើយ ម្ចាស់បំណុលត្រូវតែបញ្ជាក់ទៅតុលាការអំពីការដាក់ប្រាតិភោគរបស់ខ្លួនដោយភ្ជាប់ជាមួយនូវ សេចក្តីថ្លែងការណ៍ ឬ របាយការណ៍ស្តីពីការដាក់ប្រាតិភោគ ។ ប្រាតិភោគមានអានុភាព នៅពេលដែលមានការផ្ញើប្រាក់ ឬ ឧបករណ៍ដែលអាចជួញដូរបាន ដែលត្រូវបានតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគ ឬ តុលាការអនុវត្តរក្សាការពារ[29] ។ ការតម្កល់ ឬ ការផ្ញើ គឺជារបបមួយដែលមានករណីយកិច្ចដាក់ប្រាតិភោគជាប្រាក់ ឬ ឧបករណ៍ដែលជួញដូរបាន មានដូចជា ចលនវត្ថុ អចលនវត្ថុ ឬ វត្ថុផ្សេងៗទៀត សម្រាប់អាចឱ្យអ្នកមានសិទ្ធិលើប្រាតិភោគអាចទាមទារយកវត្ថុដែលតម្កល់ទុកនោះបាន ។ ចំពោះនីតិវិធីនៃការដាក់ប្រាតិភោគលម្អិតត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។

ដូច្នេះ នៅពេលដែលមានការដាក់ប្រាតិភោគរួចហើយ តុលាការនឹងចេញសេចក្តីសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

[29] មាត្រា ៥៣៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## កថាភាគទី៤. ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

ក្នុងករណីប្រសិនបើកូនបំណុលចង់ឱ្យរួចផុតពីការរឹបអូសជាបណ្ដោះអាសន្ន ដែលបានផ្ដល់ការលំបាកដល់ផលប្រយោជន៍របស់ខ្លួនពីការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នកូនបំណុលនោះត្រូវតែផ្ញើប្រាក់រំដោះមកតុលាការដែលបង្គាប់ឱ្យដាក់ប្រាក់រំដោះ ដើម្បីជំនួសនូវកម្មវត្ថុដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ននោះ[30] ។ ផ្ទុយមកវិញ ប្រសិនជានៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការមិនបានបង្គាប់ឱ្យដាក់ប្រាក់រំដោះទេ គឺដីកាសម្រេចនោះធ្វើឡើងពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ ។

### ១. គោលបំណងនៃប្រាក់រំដោះ

គោលបំណងនៃប្រាក់រំដោះ គឺដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលទាមទារមានគោលបំណងឱ្យសងជាប្រាក់ ។ នៅពេលដែលកូនបំណុល ទទួលការលំបាកពីការរឹបអូសជាបណ្ដោះអាសន្នលើទ្រព្យសម្បត្តិ ឬ សិទ្ធិរបស់ខ្លួនត្រូវបានហាមឃាត់មិនអាចចាត់ចែងបាន ប្រសិនជាកូនបំណុលចង់រួចផុតពីការរឹបអូសជាបណ្ដោះអាសន្ននោះ ហេតុនេះក្នុងករណីកូនបំណុលបានផ្ញើប្រាក់រំដោះតាមចំនួនទឹកប្រាក់ស្មើនឹងចំនួននៃទឹកប្រាក់សិទ្ធិទាមទារ ជាហេតុនាំឱ្យកូនបំណុលរួចផុតពីការរឹបអូសជាបណ្ដោះអាសន្ន ហើយកូនបំណុលអាចចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនបានដោយសេរី ពីព្រោះវាមិនមានការខូតខាតដល់ម្ចាស់បំណុលទៀតទេ ម៉្យាងវិញទៀតដីកាសម្រេចនឹងលែងមានអានុភាពអនុវត្តដោយសារតែការលុបចោលនូវការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន[31] ។ ហើយដើម្បីទទួលបានប្រាក់រំដោះនេះ ម្ចាស់បំណុលត្រូវដាក់បណ្ដឹងមួយទៀត ក្នុងករណីម្ចាស់បំណុលឈ្នះក្ដីនៅនិងទទួលបានលិខិតអនុវត្តហើយ ម្ចាស់បំណុលអាចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ប្រាក់ដែលបានផ្ញើមកតុលាការផ្អែកទៅលើលិខិតអនុវត្ត ។

### ២. ចំនួននៃប្រាក់រំដោះ

ចំពោះចំនួននៃប្រាក់រំដោះដែលត្រូវកំណត់ចំនួនប៉ុន្មាន គឺពុំមានបញ្ញត្តិណាមួយចែងឡើយ ប៉ុន្តែតុលាការដែលទទួលបន្ទុកក្នុងសំណុំរឿងរក្សាការពារមានឆន្ទានុសិទ្ធិក្នុងការកំណត់ចំនួនប្រាក់រំដោះ ដែលត្រូវឱ្យកូនបំណុលផ្ញើមកតុលាការ ។ មានចំណុចពីរ សម្រាប់អាចឱ្យតុលាការពិចារណាអំពីការដាក់ចំនួនប្រាក់រំដោះដោយគិតលើផលប្រយោជន៍របស់គូភាគី ។

- ចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន: មានន័យថាតុលាការត្រូវពិចារណាពីតម្លៃនៃទ្រព្យរបស់កូនបំណុលដែលម្ចាស់បំណុលធ្វើការស្នើសុំរឹបអូសជាបណ្ដោះអាសន្ន និងយកចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ននោះធ្វើជាចំនួនប្រាក់រំដោះ ពីព្រោះ

[30] សូមមើលមាត្រា ៥៤៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[31] មាត្រា ៥៦៩ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ប្រាក់រំដោះ ជាប្រាក់មួយប្រភេទដែលកូនបំណុល អាចដាក់ជំនួសនូវទ្រព្យរបស់ខ្លួន ដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ននោះ។

- សិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ: មានន័យថា តុលាការត្រូវគិតពីសមតុល្យរវាងសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារជាចំនួនប្រាក់ដែលត្រូវរំដោះ ដោយហេតុថាគោលបំណងនៃការរឹបអូសជាបណ្ដោះអាសន្ននឹងធានាដល់ការអនុវត្តដោយបង្ខំនាពេលអនាគតចំពោះកម្មវត្ថុនៃបណ្ដឹងដែលមានគោលបំណងទាមទារឱ្យសងជាប្រាក់ និងប្រាក់ដែលមានតម្លៃសមមូលទៅនឹងចំនួននៃសិទ្ធិលើបំណុល គឺអាចអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលបានហើយ ។

### ៣. វិធីនៃការដាក់ប្រាក់រំដោះ

ចំពោះវិធីនៃការដាក់ប្រាក់រំដោះ នៅពេលដែលកូនបំណុលបានធ្វើប្រាក់រំដោះ គឺត្រូវធ្វើទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការអនុវត្តរក្សាការពារ[32] ។ ចំពោះនីតិវិធីនៃការធ្វើប្រាក់រំដោះ ត្រូវបានកំណត់ដោយសេចក្ដីណែនាំរបស់ក្រសួងយុត្តិធម៌ស្ដីពី នីតិវិធីនៃការធ្វើប្រាក់ប្រាតិភោគទៅតុលាការ ។

## កថាភាគទី៥. ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

នៅពេលដែលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នទៅភាគី[33] ។ ហើយការបញ្ជូននេះអាចធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ លើកលែងតែក្នុងករណីមានបញ្ញត្តិពិសេសនៅក្នុងច្បាប់[34] ។ ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លងដែលពាក់ព័ន្ធទាំងអស់លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

### ១. ដីកាសម្រេចបង្គាប់ឱ្យរឹបអូសជាបណ្ដោះអាសន្ន

ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះ មានគោលបំណងជូនដំណឹងអំពីសេចក្ដីសម្រេចនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយវាក៏ជាឱកាសមួយដែលអាចឱ្យកូនបំណុលមានសិទ្ធិក្នុងប្ដឹងតវ៉ានឹងដីកាសម្រេចនេះដែរ ។ មន្ត្រីដែលទទួលបន្ទុកក្នុងការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺត្រូវធ្វើឡើងដោយក្រឡាបញ្ជី ។ ចំពោះការបញ្ជូននេះ គឺត្រូវប្រតិបត្តិដោយ បុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី [35] ។ ដើម្បីជៀសវាងនូវការរារាំងដល់ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចៅក្រមមានសិទ្ធិក្នុងការបញ្ជូន ឬ មិនបញ្ជូន ប៉ុន្តែជាគោលការណ៍ តុលាការត្រូវបញ្ជាក់ពីការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចប់សព្វគ្រប់សិន ទើបមន្ត្រីទទួលបន្ទុកត្រូវបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះទៅកូនបំណុល ដោយសារការធ្វើបែបនេះ គឺជា

[32] មាត្រា ៥៤៧-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[33] មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[34] មាត្រា ២៤៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[35] មាត្រា ២៤៦-៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នក៏អាចអនុវត្តបាន នៅមុនពេលដែលដីកាសម្រេចនោះត្រូវបញ្ជូនទៅកូនបំណុល [36] ហើយការអនុវត្តដូចនេះ គឺដើម្បីរក្សាការសម្ងាត់ ព្រោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវចេញជាការប្រញាប់បន្ទាន់ និងសម្ងាត់ មុនពេលអាចអនុវត្តការរឹបអូសជាបណ្តោះអាសន្នបាន ។ បន្ទាប់ពីបានបញ្ជូនទៅម្ចាស់បំណុល និងកូនបំណុលរួចហើយ ក្រឡាបញ្ជីយករបាយការណ៍បញ្ជូនពីមន្រ្តីទទួលបន្ទុកក្នុងការបញ្ជូនទៅចៅក្រមពិនិត្យមើលថាតើការបញ្ជូននេះត្រឹមត្រូវដែរ ឬទេ ។ បន្ទាប់មកទៀត ក្រឡាបញ្ជីត្រូវរក្សារបាយការណ៍នៃការបញ្ជូនចូលក្នុងសំណុំរឿង រក្សាការពារនោះដើម្បីឱ្យដឹងពីការបញ្ជូនបានដល់អ្នកដែលទទួលការបញ្ជូនរួចរាល់ហើយ ។

**២. ដីកាសម្រេចលើកចោលពាក្យសុំ**

នៅពេលដែលម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទៅតុលាការមានសមត្ថកិច្ចហើយ ប៉ុន្តែត្រូវបានតុលាការចេញដីកាសម្រេចលើកចោលពាក្យសុំនោះ ដោយមូលហេតុណាមួយ គឺពុំមានការបញ្ជូនដំណឹងពីការលើកចោលពាក្យសុំទៅកូនបំណុលទេ ពីព្រោះវាពុំបានធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ដល់កូនបំណុលទេ លើសពីនេះការធ្វើដូចនេះ គឺដើម្បីរក្សាការសម្ងាត់របស់ម្ចាស់បំណុល ។ ផ្ទុយមកវិញ ការជូនដំណឹងនោះចាំបាច់ត្រូវបញ្ជូនមកម្ចាស់បំណុលវិញ ដើម្បីអាចឱ្យម្ចាស់បំណុលធ្វើបណ្តឹងជំទាស់ ហើយវាក៏បានទុកពេលដល់ម្ចាស់បំណុលក្នុងការស្វែងរកភស្តុតាងបន្ថែម ដើម្បីបង្ហាញពីភាពចាំបាច់របស់ម្ចាស់បំណុល ឈានដល់ការចាត់វិធានការរក្សាការពារពីតុលាការ ម៉្យាងវិញទៀត ម្ចាស់បំណុលក៏អាចដាក់ពាក្យស្នើសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នសាជាថ្មីបានដែរ ។ ក្នុងករណីមាននីតិវិធីការសួរទៅកូនបំណុល ឬ ការទាញហេតុផលដោយផ្ទាល់មាត់មុនពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតុលាការត្រូវជូនដំណឹងស្តីពីការលើកចោលពាក្យសុំរបស់ម្ចាស់បំណុលដល់កូនបំណុលដែរ ដោយហេតុថាការរក្សាភាពសម្ងាត់នឹងលែងមានអត្ថិភាពនៅក្នុងករណីនេះ [37] ។

**ផ្នែកទី៣ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន**

ក្រោយពីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតាមពាក្យសុំហើយ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ដើម្បីយកឯកសារចម្លងយថាភូតទៅអនុវត្ត ដោយមិនចាំបាច់ភ្ជាប់រូបមន្តអនុវត្តទេ ។ ការដាក់ពាក្យសុំនេះម្ចាស់បំណុលត្រូវដាក់ចូលទៅតុលាការមានសមត្ថកិច្ចអនុវត្តរក្សាការពារ ហើយវាក៏អាស្រ័យទៅតាមកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ ដែលមានកម្មវត្ថុដាច់ដោយឡែកពីគ្នា ពោលគឺ មានស្ថាប័នអនុវត្តរក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្នទៅតាមកម្មវត្ថុផ្សេងៗមានដូចជា ៖ ចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល សិទ្ធិទ្រព្យសម្បត្តិ ឬ នាវា ។

[36] មាត្រា៥៦២-៣ ក្រមនីតិវិធីរដ្ឋប្បវេណី

[37] មាត្រា២១៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## កថាភាគទី១ ស្ថាប័នអនុវត្តការរឹបអូសជាបណ្តោះអាសន្ន

ក្រោយពីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវដាក់ពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្នទៅស្ថាប័នដែលត្រូវអនុវត្ត ។ ស្ថាប័នអនុវត្តមានពីរប្រភេទ គឺតុលាការអនុវត្តរក្សាការពារ និងអាជ្ញាសាលា ។ តុលាការអនុវត្តរក្សាការពារ គឺអនុវត្តដោយបង្គំដែលផ្តោតសំខាន់លើការវិនិច្ឆ័យរបស់ច្បាប់ រីឯអាជ្ញាសាលា គឺអនុវត្តដោយបង្គំដែលត្រូវធ្វើសកម្មភាពជាក់ស្តែងតាមទីតាំង ។

### ១. ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត គឺធ្វើដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ[38] ។

### ២. ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺជាតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[39] ហៅថាតុលាការអនុវត្តរក្សាការពារ ។

### ៣. ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ឬ លើទ្រព្យសម្បត្តិផ្សេងទៀត តុលាការដែលមានសមត្ថកិច្ចអនុវត្តរឹបអូសជាបណ្តោះអាសន្ន គឺជាតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ[40] ។

### ៤. ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា គឺមានស្ថាប័នដែលមានសមត្ថកិច្ចចំនួនពីរដែលអាចអនុវត្តបានរឹបអូសជាបណ្តោះអាសន្ន ។ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។រីឯការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

## កថាភាគទី២. ការដាក់ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន អាចអនុវត្តទៅបានលុះត្រាតែមានពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្នរបស់ម្ចាស់បំណុល និងត្រូវមានការចំណាយសោហ៊ុយសម្រាប់អនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

---

[38] សូមមើលត្រា ៥៦៥-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[39] សូមមើលត្រា ៥៦៧-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[40] មាត្រា ៥៦៦-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

**១.ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន**

ម្ចាស់បំណុលដែលដាក់ពាក្យសុំអនុវត្តរឹបអូសជាបណ្ដោះអាសន្នត្រូវសរសេរតាមទម្រង់ខាងក្រោម ៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន
- ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្ដីសុំ និង ទំហំនៃសេចក្ដីសុំក្នុងពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[41]។

**២. សោហ៊ុយនៃការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន**

ដើម្បីអាចអនុវត្តការរឹបអូសជាបណ្ដោះអាសន្នបាន ម្ចាស់បំណុលត្រូវតែបង់ពន្ធដាក់ពាក្យសុំចំនួន ៥.០០០ រៀល ទៅស្ថាប័នអនុវត្តជាតុលាការ[42] ។ មិនត្រឹមតែមានការចំណាយក្នុងការបង់ពន្ធដាក់ពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្នប៉ុណ្ណោះទេ គឺត្រូវមានការចំណាយលើសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំអនុវត្តទៀតដែលម្ចាស់បំណុលត្រូវបង់សោហ៊ុយចាំបាច់ជាមុនដែលត្រូវបានកំណត់ដោយតុលាការអនុវត្តរក្សាការពារ[43] ។ ប្រសិនបើម្ចាស់បំណុលមិនបានបង់សោហ៊ុយក្នុងការចុះទៅអនុវត្តការរឹបអូសជាបណ្ដោះអាសន្នជាមុនទេនោះ នាំឱ្យតុលាការអនុវត្តរក្សាការពារ ឬ អាជ្ញាសាលាអាចលើកចោលពាក្យសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ អាចលុបចោលនូវនីតិវិធីអនុវត្តរក្សាការពារបាន[44] ។

**កថាភាគទី៣. លក្ខខណ្ឌចាំបាច់នៃការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន**

ដើម្បីអាចអនុវត្តការរឹបអូសជាបណ្ដោះអាសន្នបាន លុះត្រាតែម្ចាស់បំណុលដាក់សុំអនុវត្តបានបំពេញគ្រប់លក្ខខណ្ឌដែលច្បាប់តម្រូវ ពីព្រោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមានអានុភាពអាចអនុវត្តបានភ្លាមៗដោយសារតែកម្រិតនៃអំឡុងពេលនោះ ហេតុនេះនៅពេលដែលទទួលបានពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្នតុលាការអនុវត្តត្រូវពិនិត្យលើលក្ខខណ្ឌចាំបាច់នៃការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដែលត្រូវភ្ជាប់មកជាមួយពាក្យសុំ ដើម្បីជៀសវាងមានកំហុសត្រង់ចំណុចណាមួយ។ លក្ខខណ្ឌចាំបាច់នៃការអនុវត្តដូចខាងក្រោម ៖

[41] មាត្រា ៣៤៩ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[42] មាត្រា ៥៣៧-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[43] មាត្រា ៥៣៧ -២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[44] មាត្រា ៥៣៧-៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

**១.លិខិតយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

តុលាការអនុវត្ត ឬ អាជ្ញាសាលានឹងពិនិត្យឈ្មោះរបស់គូភាគីនៃលិខិតអនុវត្ត ថាដូចនឹងឈ្មោះគូភាគីនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែរ ឬ អត់ ។ ករណីប្រសិនជាឈ្មោះដូចគ្នា គឺការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវធ្វើឡើងដោយគ្រាន់តែពឹងផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះប៉ុណ្ណោះ ។ តែផ្ទុយមកវិញ ប្រសិនជាឈ្មោះមិនដូចគ្នា គឺការអនុវត្តត្រូវផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តផងដែរ[45] ។

**២.អំឡុងពេលនៃការអនុវត្ត**

នៅពេលដែលទទួលបានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នក្នុងរយៈពេល ០២ (ពីរ) សប្ដាហ៍ ដោយរាប់គិតចាប់ពីថ្ងៃដែលម្ចាស់បំណុលទទួលបានដីកាសម្រេចនោះ ហើយប្រសិនជាម្ចាស់បំណុលមានការយឺតយ៉ាវហួសរយៈពេល ០២ (ពីរ) សប្ដាហ៍ នាំឱ្យដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននឹងលែងមានអានុភាពអាចអនុវត្តតទៅទៀត ដោយហេតុថាភាពចាំបាច់នៃរក្សាការពារលែងមាន ។

**៣.ករណីដែលតុលាការឱ្យដាក់ប្រាតិភោគ**

តុលាការអនុវត្តនឹងពិនិត្យអំពីប្រាតិភោគ ថាតើម្ចាស់បំណុលបានដាក់ប្រាតិភោគរួចហើយ ឬនៅ ពីព្រោះប្រាតិភោគក៏ជាលក្ខខណ្ឌចាំបាច់នៃការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នដែរ ប៉ុន្តែប្រសិនជាដាក់ប្រាតិភោគហើយម្ចាស់បំណុលត្រូវធ្វើរបាយការណ៍ស្ដីពីការដាក់ប្រាតិភោគមកបញ្ជាក់ទៅតុលាការអនុវត្ត ។

**កថាភាគទី៤. របៀបនៃការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន**

ដូចដែលបានរៀបរាប់នៅខាងលើរួចមកហើយ កម្មវត្ថុដែលអាចធ្វើការរឹបអូសជាបណ្ដោះអាសន្នមានដូចជាសិទ្ធិលើបំណុល និងលើទ្រព្យសម្បត្តិផ្សេងទៀត ចលនវត្ថុ អចលនវត្ថុ និងនាវា ហេតុនេះការអនុវត្តការរឹបអូសជាបណ្ដោះ អាសន្នទាំងបួនប្រភេទនេះនឹងមានរបៀបអនុវត្តដូចខាងក្រោម៖

**១. ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ**

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ គឺធ្វើឡើងតាមរបៀបកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នដោយអាជ្ញាសាលាសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ[46] ។ ក្នុងករណីដែលចលនវត្ថុនោះជាប្រាក់វិញ អាជ្ញាសាលាមិនកាន់កាប់ប្រាក់នោះដោយផ្ទាល់ទេ ពោលគឺត្រូវផ្ញើប្រាក់ដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ននោះទៅតុលាការដែលខ្លួនស្ថិតនៅ ។ លើសពីនេះ ប្រសិនជាម្ចាស់បំណុល ឬ កូនបំណុលមានការបារម្ភថាចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ននោះ

[45] មាត្រា៥៦២ -១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[46] មាត្រា ៥៦៥-១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

នឹងមានការចុះថ្លៃយ៉ាងខ្លាំង និងត្រូវចំណាយសោហ៊ុយច្រើនហួសហេតុក្នុងការរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះតាមនីតិវិធីនៃការលក់ដោយបង្ខំបានផងដែរ[47] ។ ហើយនៅពេលដែលបានលក់ចលនវត្ថុនោះរួចហើយ ប្រាក់ដែលបានពីការលក់ដោយការដោយបង្ខំនូវចលនវត្ថុនោះ អាជ្ញាសាលាត្រូវយកប្រាក់នោះ ទៅផ្ញើនៅតុលាការដែលខ្លួនស្ថិតនៅ ។ ជាគោលការណ៍ ការចុះទៅអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុមានចលនវត្ថុមួយចំនួន ដែលច្បាប់ហាមឃាត់មិនអនុញ្ញាតឱ្យអាជ្ញាសាលារឹបអូសបានទេមានដូចខាងក្រោមៈ

- ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក តុ ទូ ប្រដាប់សម្រាប់ដាំស្ល និង ប្រដាប់សម្រាប់បិទឃាំងបន្ទប់ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។
- គ្រឿងបរិភោគ និង ទហានវត្ថុ ដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជីវិតក្នុងអំឡុង ពេល ២ (ពីរ) ខែ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុល នៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។
- របបឧបត្ថម្ភជីវភាព របបឧបត្ថម្ភផ្នែកអប់រំ របបឧបត្ថម្ភសុខភាព និង ប្រាក់ ឬ វត្ថុឧបត្ថម្ភផ្សេងទៀត ដែលផ្ដល់ពីរដ្ឋ ឬពីអាជ្ញាធរដែនដី ដើម្បីការពារដល់ជីវភាពរបស់កូនបំណុលនៃការអនុវត្ត ។
- ផ្នែកប្រាក់តិចជាង ឬ ស្មើនឹង ១.០០០.០០០ (មួយលាន) រៀល ក្រៅពីប្រាក់ខាងលើនេះ
- ឧបករណ៍ ជី សត្វពាហនៈដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និង ចំណីសត្វទាំងនេះ ព្រមទាំងគ្រាប់ពូជ ឬ កសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់បន្តការងារកសិកម្មហូតដល់រដូវបានផលបន្ទាប់ របស់កសិករក្នុងការប្រកប របរកសិកម្ម ។
- មង សំណាញ់ ឬ នេសាទុបករណ៍ផ្សេងៗចាំបាច់ ចំណី និង កូនត្រី ឬ ជលផល ប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់រកជលផល ឬ ចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ ។
- ឧបករណ៍ និង វត្ថុផ្សេងៗដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និង អ្នកផ្សេងទៀត ដែលប្រកបរបរវិជ្ជាជីវៈ ឬ សាជីវកម្ម ដោយប្រើកម្លាំងប្រាជ្ញា កម្លាំងកាយ ។ ប៉ុន្តែ បើជាវត្ថុដែលអ្នកនោះមាន ក្នុងគោលបំណងសម្រាប់លក់ ឬ ជួលវិញ អាច រឹបអូសយកបាន ។
- ព្រះពុទ្ធរូបក្បួនវិត័សាសនា និងវត្ថុផ្សេងៗដែលចាំបាច់សម្រាប់ពិធីក្នុងសាសនា ។
- ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និង ឯកសារប្រភេទដូចគ្នាដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត ។

[47] មាត្រា ៥៦៥-៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

- គ្រឿងឥស្សរិយយស និង ប័ណ្ណសរសើរផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត ឬ របស់ញាតិរបស់ជននោះ ។
- ឯកសារ និង ឧបករណ៍ ដែលចាំបាច់ក្នុងការសិក្សា នៅសាលា ឬ នៅស្ថាប័ន អប់រំផ្សេងទៀត របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុល ការអនុវត្ត ហើយមានជីវភាពរួមគ្នា ។
- វត្ថុដែលទាក់ទងនឹងតក្កកម្ម ឬ ស្នាដៃនិពន្ធ ដែលមិនទាន់បានផ្សាយជាសាធារណៈ ។
- អវយវៈសិប្បនិមិត្ត សរីរាង្គសិប្បនិមិត្តផ្សេងទៀត និង ឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀត ដែលចាំបាច់របស់កូនបំណុលនៃការអនុវត្តនិងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំ អ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។
- ម៉ាស៊ីន ឬ ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជន្លៀសខ្លួនពេលមានអាសន្ន ឬ ឧបករណ៍ផ្សេងទៀតសម្រាប់អាគារ ឬ សំណង់ផ្សេងទៀត ដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗតម្រូវឱ្យមានបរិក្ខារដើម្បីបង្ការមហន្តរាយ ឬ ការពារសន្តិសុខ[48] ។

ចំណែកឯ ការចាប់ផ្តើមអនុវត្តរឹបអូសចំពោះចលនវត្ថុ គឺត្រូវអនុវត្តដូចនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែលត្រូវធ្វើឡើងដោយវិធីរឹបអូសចលនវត្ថុដោយ៣ករណីដូចខាងក្រោម ៖

- ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដែលកូនបំណុលអនុវត្តកាន់កាប់
- ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដែលម្ចាស់បំណុលកាន់កាប់
- ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដែលតតិយជនកាន់កាប់

### ១.១. ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដែលកូនបំណុលអនុវត្តកាន់កាប់

ក្នុងករណីនេះអាជ្ញាសាលាអាចរឹបអូសបណ្តោះអាសន្នចំពោះចលនវត្ថុនោះ ដោយផ្អែកទៅលើរូបភាពខាងក្រៅនៃកាន់កាប់របស់កូនបំណុលតែប៉ុណ្ណោះ ដោយមិនចាំបាច់ស្រាវជ្រាវព័ត៌មានអំពីកម្មសិទ្ធិចលនវត្ថុនោះឡើយ។ ប៉ុន្តែប្រសិនជាចលនវត្ថុនោះមិនមែនជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត អាជ្ញាសាលាមិនអាចធ្វើបានការរឹបអូសចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃបានទេ។ ឧទាហរណ៍៖ សៀវភៅដែលមានបទស្លាករបស់បណ្ណាល័យសៀវភៅAB។

នៅពេលធ្វើការរឹបអូសចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តដែលកាន់កាប់នោះ អាជ្ញាសាលាអាចរឹបអូសចលនវត្ថុដោយធ្វើការកាន់កាប់ចលនវត្ថុនោះបាន។ ម្យ៉ាងវិញទៀត អាជ្ញាសាលាអាចចូលទៅក្នុងកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀត និងអាចធ្វើការឆែកឆេរស្វែងរកចលនវត្ថុដែលអាចរឹបអូសបាន ប្រសិនជាមានការចាំបាច់អាជ្ញាសាលាអាចចាត់ចែង បើកទ្វារដែលបិទ ទូដែក ឬ ប្រអប់ផ្សេងទៀតបាន ។

[48] មាត្រា ៣៨០ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

អំឡុងពេលជ្រើសរើសចលនវត្ថុដែលត្រូវនឹងរឹបអូស អាជ្ញាសាលាក៏ត្រូវគិតពិចារណាដល់ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ប៉ុន្តែក៏ត្រូវគិតពីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តដូចគ្នាដែរ[49] ។

ជាគោលការណ៍ អាជ្ញាសាលាជាអ្នកកាន់កាប់ចលនវត្ថុដែលបានរឹបអូសដោយផ្ទាល់ ប៉ុន្តែមានករណីលើកលែងគឺ អាជ្ញាសាលាអាចអនុញ្ញាតទុកចលនវត្ថុដែលបានរឹបអូសនៅកូនបំណុលនៃការអនុវត្ត ជាអ្នកថែរក្សាគ្រប់គ្រងនិងអាចប្រើប្រាស់បាន ប្រសិនជាចលនវត្ថុដែលបានរឹបអូសនោះពិបាកថែរក្សា ឬ មានបញ្ហាច្រើន ឬ ត្រូវចំណាយពេលច្រើនក្នុងការដឹក ជញ្ជូន ប៉ុន្តែចលនវត្ថុរឹបអូសនោះ ត្រូវបានបិទស្លាក ឬ ដាក់សញ្ញារឹបអូសដោយវិធីផ្សេងទៀត។ ម្យ៉ាងវិញទៀត ប្រសិនជាមានការចាំបាច់ត្រូវគ្រប់គ្រងថែរក្សាចលនវត្ថុវិញដោយអាជ្ញាសាលាខ្លួនឯងវិញ គឺអាជ្ញាសាលាអាចលុបចោលនូវការអនុញ្ញាតនោះបាន[50] ។

**១.២. ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុដែលម្ចាស់បំណុលកាន់កាប់**

ក្នុងករណីដែលម្ចាស់បំណុលខ្លួនឯងជាអ្នកកាន់កាប់ចលនវត្ថុរបស់កូនបំណុល ម្ចាស់បំណុលនៃការអនុវត្តដែលមានទ្រព្យសម្បត្តិរបស់កូនបំណុល ជាកម្មវត្ថុសិទ្ធិឃាត់ទុក និងកម្មវត្ថុនៃការបញ្ញើចលនវត្ថុ ម្ចាស់បំណុលអាចប្រគល់វត្ថុទាំងនោះដោយស្ម័គ្រចិត្តឱ្យទៅអាជ្ញាសាលាដើម្បីធ្វើការរឹបអូស ។

**១.៣. ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុដែលបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត ឬ តតិយជនកាន់កាប់**

ករណីដែលបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត ឬតតិយជនកាន់កាប់ចលនវត្ថុវិញ អាជ្ញាសាលាអាចរឹបអូសបណ្ដោះចលនវត្ថុបានតែក្នុងករណីតតិយជនអនុញ្ញាតឱ្យរឹបអូស ប្រសិនជាតតិយជនមិនអនុញ្ញាតនោះអាជ្ញាសាលាក៏មិនអាចអនុវត្តសមត្ថកិច្ចរបស់ខ្លួនដោយរឹបអូសដោយបង្ខំនូវចលនវត្ថុដែលកាន់កាប់ដោយអ្នកផ្សេងបានទេពីព្រោះនៅក្នុងលិខិតអនុវត្តមានតែឈ្មោះរបស់ម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តតែប៉ុណ្ណោះ ។ ផ្ទុយមកវិញ ម្ចាស់បំណុលអាចស្នើសុំទាមទារឱ្យប្រគល់ចលនវត្ថុដែលតតិយជនមានលើកូនបំណុលនៃការអនុវត្ត ហើយប្រសិនជាតតិយជនមិនព្រមប្រគល់ចលនវត្ថុដែលនឹងត្រូវរឹបអូសនោះ គឺគ្មានជម្រើសអ្វីក្រៅពីធ្វើការរឹបអូសសិទ្ធិទាមទារឱ្យសង ឬ សិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលកូនបំណុលមានចំពោះតតិយជនតាមរយៈការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ហើយម្ចាស់បំណុលត្រូវប្រមូលយកវត្ថុ ឬ ប្រគល់វត្ថុទាំងនោះទៅឱ្យអាជ្ញាសាលាជាអ្នកកាន់កាប់ ។

ម្យ៉ាងវិញទៀតក្រៅពីការរឹបអូសចលនវត្ថុដែលជា រថយន្ត ឬ ទោចក្រយានដែលត្រូវរឹបអូសមានចុះបញ្ជីក្នុងសៀវភៅចុះបញ្ជី អាជ្ញាសាលាត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចសរសេរហេតុការណ៍នៃការរឹបអូសចូលទៅក្នុងសៀវភៅចុះបញ្ជី [51]។

---

[49] មាត្រា ៣៨៥-៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[50]សូមមើលមាត្រា ៣៨៥-៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[51] មាត្រា ៣៨៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## ២. ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

នៅក្នុងន័យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលនឹងត្រូវជាកម្មវត្ថុនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន រួមមាន ដី អគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគ ឬ អគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម ។ សិទ្ធិរួមទាំងពីរនេះសំដៅដល់សិទ្ធិអវិភាគ[52] ។ ជាការពិតណាស់ ដើម្បីអាចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុណាមួយបានទាមទារឱ្យមានការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ ។ ចំណែកឯការអនុវត្តការរឹបអូសជាបណ្តោះ អាសន្នចំពោះអចលនវត្ថុ គឺត្រូវបានអនុវត្តដោយសាលាដំបូងដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ [53] ។ ការអនុវត្តនេះ មិនដូចគ្នាទៅការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុឡើយ ពោលគឺតុលាការអនុវត្តរក្សាការពារមិនចាំបាច់ចំណាយពេលចុះទៅដល់ទីកន្លែងនៃអចលនវត្ថុដែលត្រូវបានរឹបអូសដើម្បីធ្វើការអនុវត្តទេ គឺគ្រាន់តែអនុវត្តលើឯកសារដោយធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះចូលក្នុងសៀវភៅគោលបញ្ជីដីធ្លីប៉ុណ្ណោះ ។

ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុត្រូវបានបែងចែកជាពីររបៀប គឺ៖

- ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលបានចុះបញ្ជី
- ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមិនទាន់បានចុះបញ្ជី

### ២.១. ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលបានចុះបញ្ជី

ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុបានចុះបញ្ជីហើយ វាមានលក្ខណៈងាយស្រួល និងមានភាពរហ័សក្នុងការអនុវត្ត។ អចលនវត្ថុដែលបានចុះបញ្ជីហើយ ចង់សំដៅទៅលើអចលនវត្ថុទាំងឡាយណាដែលមានប័ណ្ណកម្មសិទ្ធិ ( ប្លង់រឹង ) ដែលមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុ ត្រូវបានចុះបញ្ជីត្រឹមត្រូវពីរដ្ឋបាលសុរិយោដី ។ ក្នុងករណីដែលអចលនវត្ថុបានចុះបញ្ជីរួច ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុត្រូវធ្វើឡើងតាមរបៀបការចុះបញ្ជីរឹបអូសអចលនវត្ថុដែលមានក្រឡាបញ្ជីជាអ្នកទទួលបន្ទុកចុះបញ្ជី។ ក្រឡាបញ្ជី គឺជាអ្នកធ្វើការផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ។ ចំពោះការធ្វើលិខិតផ្ទុកផ្តាក់នេះក្រឡាបញ្ជីត្រូវសរសេរមានទម្រង់ដូចខាងក្រោម ៖

កម្មវត្ថុ : ត្រូវសរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន

- អត្តសញ្ញាណនៃអចលនវត្ថុ : សរសេរលេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី
- ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ និងអាសយដ្ឋាន

[52] មាត្រា ៤១៧-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[53] មាត្រា ៥៦៧-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

- គោលបំណងនៃការ ចុះបញ្ជី : ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ ទៅលើអចលនវត្ថុចំណុច ក ឬ ខ
- មូលហេតុ : ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងឈ្មោះរបស់តុលាការ
- ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត និងអាសយដ្ឋាន
- ឈ្មោះកូនបំណុលនៃការអនុវត្ត និងអាសយដ្ឋាន

ឯកសារភ្ជាប់ជាមួយ : ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងឯកសារបញ្ជាក់អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត[54] ។

រីឯស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី សំដៅលើរដ្ឋបាលសុរិយោដី ថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ដែលអចលនវត្ថុដែលត្រូវចុះបញ្ជីតាំងនៅ ឬរដ្ឋបាលសុរិយោដីថ្នាក់កណ្ដាល ។ ក្រឡាបញ្ជីមានតួនាទីសំខាន់ក្នុងការបញ្ជូនលិខិតផ្ទុកផ្ដាក់ទៅរដ្ឋបាលសុរិយោដី ដើម្បីស្នើសុំឱ្យធ្វើនីតិវិធីចុះបញ្ជីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះបានយ៉ាងឆាប់រហ័ស ទើបអចលនវត្ថុដែលនឹងត្រូវបានរឹបអូសនោះអាចចុះបញ្ជីរឹបអូសតាមអំណាចបង្គំរបស់តុលាការបាន ។ នៅពេលដែលបានទទួលលិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជីរួចហើយ រដ្ឋបាលសុរិយោដីត្រូវទៅចុះបញ្ជីដែលការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន គឺធ្វើតាមប្រភេទនៃការរឹបអូសជាបណ្ដោះអាសន្នដោយសរសេរក្នុងសៀវភៅគោលបញ្ជីបញ្ជីដីធ្លីថា ត្រូវបានរឹបអូសជាបណ្ដោះអាសន្នកម្មសិទ្ធិ ។ ការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ ម្ចាស់បំណុលត្រូវបង់នូវការចំណាយក្នុងការចុះបញ្ជី ហើយត្រូវមកបង់ដោយខ្លួនឯងផ្ទាល់ តុលាការមិនមានទំនួលខុសត្រូវមកបង់ជំនួសឡើយ ។ ការបង់សេវាសាធារណៈនេះ ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ឱ្យរដ្ឋបាលថ្នាក់កណ្ដាលនៃក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងមន្ទីរដែនដីនគរូបនីយកម្ម និងសំណង់ ចំនួន ១២.០០០០រៀល មានរយៈពេលចុះបញ្ជីពីបីថ្ងៃ ទៅប្រាំបីថ្ងៃ[55] ។

នីតិវិធីបន្ទាប់មកទៀត រដ្ឋបាលសុរិយោដីត្រូវថតចម្លងចេញសៀវភៅចុះបញ្ជីអចលនវត្ថុ ដោយមានបញ្ជាក់របស់ប្រធានរដ្ឋបាលសុរិយោដី រាជធានី ខេត្ត ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម រួចត្រូវផ្ញើឯកសារចម្លងទៅក្រឡាបញ្ជីដែលបានផ្ញើលិខិតផ្ទុកផ្ដាក់នោះ ។ ប៉ុន្តែការអនុវត្តជាក់ស្ដែង មិនមានការចារឹកថាថតចម្លងតាមច្បាប់ដើម គឺមានតែឯកសារចម្លងធម្មតាផ្ញើមកវិញប៉ុណ្ណោះ ។ នៅពេលបានទទួលឯកសារចម្លងសៀវភៅចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ក្រឡាបញ្ជីត្រូវពិនិត្យលើឯកសារទាំងអស់នោះជៀសវាងមានខុសត្រង់ចំណុចណាមួយ ប្រសិនជាមានចំណុចខ្វះខាត ក្រឡាបញ្ជីត្រូវអាចស្នើទៅរដ្ឋបាលសុរិយោដីធ្វើការកែតម្រូវ ។

[54] សូមមើលទម្រង់ក្នុងឧបសម្ព័ន្ធ

[55] សូមមើលប្រកាសរួមស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ២០១២

### ២.២. ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី

ចំណែកឯអចលនវត្ថុដែលមិនទាន់ចុះបញ្ជី គឺសំដៅលើដី និងចំណែកឯកជននៃអគារសហកម្មសិទ្ធិមិនទាន់បានចុះបញ្ជី។ ហើយដីដែលមិនទាន់ចុះបញ្ជី ចង់សំដៅលើដីដែលមិនទាន់បានចុះបញ្ជីក្នុងសៀវភៅចុះបញ្ជីដែលម្ចាស់កម្មសិទ្ធិមានតែឯកសារដូចជា ពាក្យស្នើសុំកាន់កាប់ដីធ្លី និងផ្ទះសម្បែង លិខិតផ្ទេរសិទ្ធិប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង លិខិតផ្ទេរសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី ឬចុងសន្លឹក ជាអាទិ៍ ដែលត្រូវបានចេញដោយ មេភូមិ មេឃុំ/ចៅសង្កាត់ អភិបាលស្រុកខណ្ឌនៃអចលនវត្ថុតាំងនៅ ។ រីឯ ឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជីសំដៅលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជី ហើយត្រូវបានតុលាការសន្មតថាជាកូនបំណុលនៃការអនុវត្ត ឬ ជាកូនបំណុលជាកម្មសិទ្ធិករ ឬ ភោគីនៃដីនោះ[56] ។ ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមិនទាន់បានចុះបញ្ជីវាអាចលក្ខណៈស្មុគស្មាញ និងយឺតយ៉ាវពិបាកក្នុងការអនុវត្ត ។ ថ្វីបើអចលនវត្ថុមិនទាន់បានចុះបញ្ជីក៏ដោយ ក្នុងករណីនេះក្រឡាបញ្ជីក៏ត្រូវអាចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នបានដែរ ។ ដោយក្រឡាបញ្ជីត្រូវធ្វើលិខិតផ្តុកផ្តាក់ឱ្យចុះបញ្ជី ដី និងចំណែកឯកជនអគារនៃអគារសហកម្មសិទ្ធិទៅស្ថាប័នដែលមានសមត្ថកិច្ច ឱ្យចាប់ផ្តើមក្នុងនីតិវិធីចុះបញ្ជីលើកដំបូង។ ចំពោះការធ្វើលិខិតផ្តុកផ្តាក់ដែលអចលនវត្ថុមិនទាន់ចុះបញ្ជីមានទម្រង់ដូចខាងក្រោម ៖

កម្មវត្ថុ : ចាប់ផ្តើមនីតិវិធីចុះបញ្ជីដីលើកដំបូង និង ឬ ចំណែកឯកជនអាគារសហកម្មសិទ្ធិលើកដំបូង និងត្រូវសរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន

- អត្តសញ្ញាណនៃអចលនវត្ថុ : សរសេរលេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី
- ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ និងអាសយដ្ឋាន
- គោលបំណងនៃការ ចុះបញ្ជី : ចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននូវកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ ទៅលើអចលនវត្ថុចំណុច ក ឬ ខ
- មូលហេតុ : ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងឈ្មោះរបស់តុលាការ
- ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត និងអាសយដ្ឋាន
- ឈ្មោះកូនបំណុលនៃការអនុវត្ត និងអាសយដ្ឋាន

ឯកសារភ្ជាប់ជាមួយ : ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងឯកសារបញ្ជាក់ដីនោះកម្មសិទ្ធិរបស់កូនបំណុលអនុវត្ត[57] ។

---

[56] ប្រការ៤-១,២,៣ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ២០១៤

[57] មាត្រា ៤១៧-៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

បន្ទាប់ពីទទួលបានលិខិតផ្អកផ្អាក់ឱ្យចុះបញ្ជី ផ្អែកលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ និងទទួលបានលិខិតអនុញ្ញាតឱ្យចាប់ផ្តើមនីតិវិធីនៃការចុះបញ្ជី ដី និងចំណែកឯកជននអគារនៃអគារសហកម្មសិទ្ធិលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ គឺត្រូវចាប់ផ្តើមនីតិវិធីការចុះបញ្ជីលើកដំបូងដោយគ្មានការយឺតយ៉ាវហើយត្រូវធ្វើការអនុវត្តតាមបទដ្ឋានគតិយុត្តជាធរមានដែលទាក់ទងទៅនឹងនីតិវិធីនៃការចុះបញ្ជីដី និងចំណែកឯកជនអាគារនៃអគារសហកម្មសិទ្ធិ[58] ។ នៅពេលចាប់ផ្តើមការអនុវត្តលិខិតផ្អកផ្អាក់ឱ្យចុះបញ្ជីនេះ ម្ចាស់បំណុលនៃការអនុវត្ត មានកាតព្វកិច្ចបង់នូវការចំណាយក្នុងការចុះបញ្ជីដីលើកដំបូង ជៀសវាងការលើកចោលការចុះបញ្ជីលិខិតផ្អកផ្អាក់ពីរដ្ឋបាលសុរិយោដី ។ បន្ទាប់ពីការចុះបញ្ជីលើកដំបូងចប់រួចរាល់រដ្ឋបាលសុរិយោដីត្រូវធ្វើផ្ញើឯកសារចម្លងទៅក្រឡាបញ្ជីដែលបានផ្ញើលិខិតផ្អកផ្អាក់នោះ ។ ជាការពិតណាស់របបនៃការចុះបញ្ជីអចលនវត្ថុនេះ បានផ្តល់សារៈសំខាន់សម្រាប់ម្ចាស់បំណុល ដើម្បីអាចធ្វើការពារសិទ្ធិដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះឱ្យមានសុវត្ថិភាព និងរក្សាស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិនោះឱ្យនៅដដែលដោយម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួននាពេលក្រោយបាន ។

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុមិនបានបង្កការលំបាកទៅឱ្យកូនបំណុលទេពីព្រោះកូនបំណុលនៅតែមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុនោះបាន ប្រសិនជាយើងប្រៀបធៀបជាមួយការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុវិញ គឺកូនបំណុលមិនអាចមានសិទ្ធិកាន់កាប់ និងប្រើប្រាស់នូវចលនវត្ថុរបស់ខ្លួនបានទៀតទេដោយសារការកាន់កាប់នូវទ្រព្យទាំងនោះគឺចាំបាច់កាន់កាប់ដោយអាជ្ញាសាលា ។

លើសពីនេះទៅទៀត កូនបំណុលដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុរបស់ខ្លួនរួចហើយ នៅក្នុងករណីដែលកូនបំណុលបានជួលអចលនវត្ថុនោះ ទៅឱ្យតតិយជននៅមុនពេលដែលអចលនវត្ថុនោះត្រូវបានរឹបអូសការជួលបន្តនេះមិនមានអានុភាពប៉ះពាល់ដល់ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នឡើយ ហេតុនេះការជួលនេះអាចអនុវត្តបានធម្មតា ។ ប៉ុន្តែលើកលែងតែការជួលសាជាថ្មីរវាងកូនបំណុល និងតតិយជន ការធ្វើដូចនេះកូនបំណុលមិនអាចធ្វើបានទេ បើទោះបីជាធ្វើដោយការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរក៏ដោយ ។ ក្រោយពីបានចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្នរួច កូនបំណុល នឹងត្រូវបានកម្រិតនូវសកម្មភាពអនុប្បទានដូចជា លក់ទិញ ប្រទានកម្ម ជាអាទិ៍ ឬ សកម្មភាពបង្កើតសិទ្ធិប្រាតិភោគ ដូចជា ការបញ្ចាំ ហ៊ីប៉ូតែក ជាអាទិ៍ និងការចាត់ចែងផ្សេងទៀតទាំងអស់។

[58] សូមមើលប្រការ៧ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ២០១៤

## ៣. ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នលើសិទ្ធិលើបំណុល និងលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល និងសិទ្ធីលើទ្រព្យសម្បត្តិផ្សេងទៀត គឺត្រូវធ្វើឡើងតាមរបៀបដែលតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេច ហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើការប្រមូលសិទ្ធិលើបំណុល ឬការចាត់ចែងផ្សេងទៀត ហើយហាមឃាត់មិនឱ្យកូនបំណុលទី៣ សងបំណុលឱ្យកូនបំណុលនៃការអនុវត្តនោះ [59] ។ ហើយក្នុងករណីដែលបំណុលទី៣ ធ្វើការសងបំណុលទៅកូនបំណុលនៃការអនុវត្តក្នុងអំឡុងពេលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើលើសិទ្ធិលើបំណុលនៅមានអានុភាព នោះនាំឱ្យកូនបំណុលជាអ្នកទទួលខុសត្រូវចំពោះបំណុលទាំងនោះម្តងទៀត ប្រសិនជាម្ចាស់បំណុលនៃការអនុវត្តធ្វើការទាមទារនៅពេលក្រោយ ដើម្បីប្រមូលសិទ្ធិលើបំណុលដែលបានរឹបអូសនោះ ។ មុនពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលអនុវត្តសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត តុលាការអនុវត្តមិនចាំបាច់សួរកូនបំណុល និងកូនបំណុលទី៣ ទេ ដោយហេតុថា កូនបំណុលនៃការអនុវត្ត និងកូនបំណុលទី៣ នៅពេលបានដឹងមុនពីការចេញដីកាសម្រេចរឹបអូសលើបំណុល កូនបំណុលនឹងអាចធ្វើការប្រមូលសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូសនោះ ដូចជាការធ្វើអនុប្បទានជាអាទិ៍ ដែលធ្វើឱ្យបានការលំបាកអនុវត្តដោយបង្ខំ ដូច្នេះ ជាគោលការណ៍ តុលាការអនុវត្តមិនសួរកូនបំណុលទេ ។ ប៉ុន្តែ នៅក្នុងករណីដែលពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ឬ ទ្រព្យសម្បត្តិផ្សេងទៀតត្រូវ បានដកវិញ ឬ ត្រូវបានលុបចោលវិញ ក្រឡាបញ្ជីត្រូវតែធ្វើការជូនដំណឹងទៅកូនបំណុលទី៣ ។ អានុភាពនៃការរឹបអូសជាបណ្តោះអាសន្ន ត្រូវកើតឡើងនៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅដល់កូនបំណុលទី៣ ។ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិលើប្រាតិភោគផ្សេងទៀតដែល បានចុះបញ្ជីហើយត្រូវបានរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីថាសិទ្ធិលើបំណុលនោះ ត្រូវបានរឹបអូសហើយ [60]។ នៅក្នុងករណីដែលធ្វើការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណង ឱ្យសងជាប្រាក់ប្រសិនបើកូនបំណុលទី៣ បានផ្ញើប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់ទាំងអស់ ឬ មួយផ្នែកនៃសិទ្ធិលើបំណុលទៅតុលាការនោះនៅក្នុងចំនួនទឹកប្រាក់ទាំងអស់ដែលបានផ្ញើ ឬ ភាគដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ននេះ ដោយត្រូវចាត់ទុកថាប្រាក់ដែលកូនបំណុលបានផ្ញើ គឺជាប្រាក់រំដោះ [61]។ រីឯក្នុងករណីការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវអនុវត្តដូចករណីការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែរ ។

[59] មាត្រា ៤០៣-៥ ក្រមនីតិវិធីរដ្ឋប្បវេណី

[60] សូមមើលមាត្រា ៤០៣-១០ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[61] សូមមើលមាត្រា ៥៦៦-៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## ៤. ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា គឺត្រូវឡើងតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ហើយអាជ្ញាសាលាត្រូវផ្ដល់លិខិតបញ្ជាក់នាវានោះទៅតុលាការអនុវត្តរក្សាការពារ។ ការអនុវត្តតាមរបៀបទាំងពីរនេះ គឺអាចអនុវត្តរួមបាន មានន័យថា ម្ចាស់បំណុលនៃការអនុវត្តអាចស្នើសុំឱ្យតុលាការធ្វើការអនុវត្តដោយចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន និងតាមរបៀបបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវានោះក្នុងពេលរួមគ្នាបាន ។ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា មានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។ ចំណែកឯការអនុវត្តតាមរបៀបបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ នៅពេលចេញដីកាសម្រេចអនុវត្តការរឹបអូសជាបណ្ដោះអាសន្នមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ។ ការដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា គឺជាវិធីដែលថែរក្សាទុកយ៉ាងជាក់ស្ដែងនូវនាវានៅកន្លែងរឹបអូសបោះ។ តាមរយៈការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ធ្វើឡើងតាមរបៀបចុះបញ្ជី ក្រឡាបញ្ជីទទួលបន្ទុក ក្នុងសំណុំរឿងរក្សាការពារត្រូវធ្វើលិខិតផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ហេតុនេះ ជាគោលការណ៍ អានុភាពនៃការរឹបអូសកើតឡើងនៅពេលដែលបានចុះបញ្ជី ហើយចំពោះការដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា អានុភាពនឹងកើតឡើងនៅពេលដែលបានដកហូត ។ នៅពេលដែលនាវាត្រូវបានរឹបអូស និងបានដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ម្ចាស់បំណុលនៃការអនុវត្តអាចស្នើសុំឱ្យមានអ្នកមើលថែរក្សានាវាឱ្យបានត្រឹមត្រូវ ក្នុងករណីមានការចាំបាច់ក្នុងដកហូតការកាន់កាប់នាវារបស់កូនបំណុលនៃការអនុវត្ត តុលាការអនុវត្តរក្សាការពារអាចជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រងនាវានោះតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ប៉ុន្តែក៏មានករណីលើកលែងដែរ ប្រសិនជាកូនបំណុលនៃការអនុវត្តមានមូលហេតុចាំបាច់សម្រាប់អាជីវកម្ម និងមូលហេតុសមរម្យផ្សេងទៀត អាចដាក់ពាក្យសុំទៅតុលាការអនុវត្តរក្សាការពារ ហើយប្រសិនជាម្ចាស់បំណុលនៃការអនុវត្តអនុញ្ញាត តុលាការអនុវត្តរក្សាការពារអាចឱ្យនាវានោះធ្វើដំណើរបាន ។

# ជំពូកទី៣
# ឧបាស្រ័យចំពោះដីកាសម្រេច និងការ
# អនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

# ជំពូកទី៣
# ឧបាស្រ័យចំពោះដីកាសម្រេច និងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

ជាគោលការណ៍ រាល់ការសម្រេចសេចក្ដីរបស់តុលាការមិនមែនរឹតបន្តឹងបិទផ្លូវក្នុងប្ដឹងការតវ៉ា ឬ ប្ដឹងជំទាស់ពីសំណាក់អ្នកចាញ់ក្ដី ឬ កូនបំណុលនៃការអនុវត្តឡើយ។ តួយ៉ាងច្បាប់នៅក្នុងប្រទេសកម្ពុជារបស់យើងសម្រាប់គូជម្លោះ ឬ តតិយជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ណាមួយដែលមិនសុខចិត្តយល់ថាខ្លួនទទួលរងភាពអយុត្តិធម៌នៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចធ្វើការតវ៉ាប្ដឹងជំទាស់បាន ពីព្រោះវាជាឱកាសដ៏ល្អសម្រាប់ភាគីណាមួយអាចស្វែងរកភស្តុតាង ដើម្បីបញ្ជាក់ថាខ្លួនគ្មានកំហុស ឬ ពុំបានជាប់កាតព្វកិច្ចណាមួយតាមការអះអាងរបស់ភាគីអ្នកប្ដឹង ឬ អ្នកឈ្នះក្ដី ប៉ុន្តែមិនមែនសុទ្ធតែរាល់ការសម្រេចសេចក្ដីទាំងអស់នោះ អាចបើកផ្លូវប្ដឹងតវ៉ា ឬ ប្ដឹងជំទាស់បានទេ គឺមានករណីមួយចំនួនប៉ុណ្ណោះដែលច្បាប់អនុញ្ញាតអាចប្ដឹងតវ៉ា ឬ ជំទាស់បាន ។

## ផ្នែកទី១ ការតវ៉ាដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

នៅពេលដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបានចេញ ហើយត្រូវបានបញ្ជូនទៅកូនបំណុលឱ្យដើម្បីបានដឹងឮដំណឹងអំពីការរឹបអូសជាបណ្ដោះអាសន្នលើទ្រព្យ ឬ សិទ្ធិរបស់ខ្លួន កូនបំណុលមានសិទ្ធិអាចប្ដឹងការតវ៉ាទៅនឹងសេចក្ដីសម្រេចនោះ ដែលបានផ្ដល់ពេលឱ្យកូនបំណុលដែលពុំមានឱកាសចូលរួមក្នុងនីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នក្នុងការសុំឱ្យមានការវិនិច្ឆ័យដើម្បីឱ្យខ្លួនអាចអះអាងបញ្ជាក់ពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយសារតែដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមិនអាចប្ដឹងជំទាស់បានភ្លាមៗនោះទេ ពោលគឺកូនបំណុលដែលមិនឯកភាពនឹងដីកាសម្រេចនោះ អាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបាន ប៉ុន្តែពាក្យសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរដាក់ទៅតុលាការដែលបានចេញដីកាសម្រេចនោះ[62] ។

អំឡុងពេលនៃការដាក់ពាក្យសុំតវ៉ានៅក្នុងនីតិវិធីក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានបញ្ញត្តិណាមួយចែងអំពីអំឡុងពេលផុតកំណត់ឡើយ ។ ហេតុដូច្នេះ កូនបំណុលអាចដាក់ពាក្យសុំតវ៉ាទៅនឹងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននៅពេលណាក៏បានឱ្យតែដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននៅមានសុពលភាព ពីព្រោះការតវ៉ានេះ គឺជាវិវាទបញ្ជាក់អំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវចំពោះការដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តែវាពុំជាប់ពាក់ព័ន្ធទៅនឹងការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នទេ ។ ម៉្យាងវិញទៀត បន្ទាប់ពីតុលាការទទួលបានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នរបស់កូនបំណុលរួចហើយ មុនពេលដែលចេញដីកាសម្រេចទៅនឹងពាក្យសុំតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់កូនបំណុល តុលាការត្រូវតែគោរពទៅតាមនីតិវិធីដែលច្បាប់បានកំណត់មានដូចខាងក្រោម៖

[62] សូមមើលមាត្រា ៥៥០ ក្រមនីតិវិធីរដ្ឋប្បវេណី

**កថាភាគី១. ការទាញហេតុផលដោយផ្ទាល់មាត់**

នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចចំពោះការតវ៉ា នៅពេលតុលាការទទួលបានពាក្យសុំតវ៉ារបស់កូនបំណុល តុលាការមិនអាចចេញដីកាសម្រេចអំពីការតវ៉ានឹងដីកាសម្រេចដោយមិនឆ្លងកាត់នីតិវិធីតាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបានទេ[63]។ ពីព្រោះគោលបំណងនៃការកំណត់បែបនេះ គឺដើម្បីផ្តល់ឱកាសឱ្យភាគី ជាពិសេសកូនបំណុលអាចចូលរួមក្នុងនីតិវិធីនេះ។ ប៉ុន្តែមិនចាំទាល់តែនៅក្នុងគ្រប់កាលបរិច្ឆេទទាំងអស់ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះទេ ពោលគឺគ្រាន់តែធានាឱ្យបាននូវកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបានតែម្តងជាការគ្រប់គ្រាន់ដែរ ។

ដូច្នេះ ក្រោយពីបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងចូលរួម តុលាការអាចចេញសេចក្តីសម្រេចណាមួយដែលជាសេចក្តីបញ្ជាក់នៃការបង្ហាញរបស់គូភាគីនៅចំពោះមុខតុលាការ ។

**កថាភាគទី២. ការបញ្ចប់ការវិនិច្ឆ័យចំពោះការតវ៉ា**

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាគោលការណ៍តុលាការត្រូវសម្រេចអំពីថ្ងៃបញ្ចប់ការវិនិច្ឆ័យដោយកំណត់អំឡុងពេលសមរម្យ[64] ។ នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យនៃការចេញដីកាសម្រេចចំពោះការតវ៉ា តុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បានដោយគ្រាន់តែជូនដំណឹងទៅភាគីអំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យ ក៏ប៉ុន្តែប្រសិនបើការវិនិច្ឆ័យត្រូវបានបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យបាន ព្រោះការធានានៅក្នុងនីតិវិធីត្រូវបានផ្តល់ឱ្យគ្រប់គ្រាន់ហើយជៀសវាងការមិនបានដឹងឮពីគូភាគីជាមុន [65] ។

**កថាភាគទី៣. ការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[66] ។ ក្នុងករណីបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានភាពត្រឹមត្រូវតុលាការអាចចេញដីកាសម្រេចទទួលស្គាល់ដីកាសម្រេចនោះបាន ។ មួយវិញទៀត ប្រសិនតុលាការចេញដីកាសម្រេចផ្លាស់ប្តូរ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានផ្ទុកនូវចំណុចដែលត្រូវផ្លាស់ប្តូរដែលអាចមកពីករណី

[63] មាត្រា ៥៥២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[64] មាត្រា ៥៥៣-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[65] មាត្រា ៥៥៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[66] មាត្រា ៥៥៤-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

មានការដាក់លក្ខខណ្ឌនៃការដាក់ប្រាតិភោគ ឬ បន្ថែមនូវប្រាតិភោគ របស់ម្ចាស់បំណុលនៅក្នុងអំឡុងពេលកំណត់ណាមួយជាអាទិ៍ ។

ក្រោយពីចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នរួចហើយ តុលាការត្រូវបញ្ជូនដីកាសម្រេចនោះទៅភាគី ម្ចាស់បំណុល និងកូនបំណុល [67] ។

## ផ្នែកទី២ ការតវ៉ាចំពោះការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ការតវ៉ា គឺជាវិធីនៃបណ្តឹងមួយប្រភេទដែលផ្តល់សិទ្ធិដល់កូនបំណុលអាចតវ៉ាចំពោះអត្ថិភាព ឬ អត្ថន័យនៃសិទ្ធិទាមទារដែលត្រូវបានកំណត់ក្នុងលិខិតអនុវត្ត[68] ។ លិខិតអនុវត្តនេះ ចង់សំដៅដល់ឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ។ ដូច្នេះ កូនបំណុលនៃការអនុវត្តអាចដាក់ពាក្យបណ្តឹងតវ៉ាបាន ដើម្បីកុំឱ្យការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ។

### កថាភាគទី១. បណ្តឹងតវ៉ារបស់តតិយជន

រាល់ការចេញសេចក្តីសម្រេចអ្វីមួយពីតុលាការ វាជៀសមិនផុតតែងតែមានការប្តឹងតវ៉ាពីកូនបំណុលដែលកើតទុក្ខមិនសុខចិត្តទៅលើសេចក្តីសម្រេចនោះ តួយ៉ាងនៅក្នុងនីតិវិធីនៃការធ្វើបណ្តឹងមិនមែនមានតែគូភាគីនៃវិវាទប៉ុណ្ណោះទេ ដែលមានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងតវ៉ា គឺអាចមានតតិយជន ឬ អ្នកប៉ះពាល់ដល់ប្រយោជន៍ផងដែរ ។ អត្ថន័យតតិយជននៅក្នុងក្រមរដ្ឋប្បវេណីមិនបានចែងនោះទេ ប៉ុន្តែនៅសន្ធានុក្រមរដ្ឋប្បវេណីបានពន្យល់ថា តតិយជន គឺជាជនទីបី ឬបុគ្គលដែលមិនមែនជាភាគីនៅក្នុងទំនាក់ទំនងគតិយុត្ត ឬបុគ្គលមិនមែនជាភាគីនៅក្នុងរឿងក្តីរដ្ឋប្បវេណី។ ការធ្វើបណ្តឹងតវ៉ារបស់តតិយជននេះ គឺត្រូវបានធ្វើឡើងក្នុងករណីប្រឆាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ដោយអះអាងថាកម្មវត្ថុនៃការអនុវត្ត មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំពុលនៃការអនុវត្តឡើយ ប៉ុន្តែជាទ្រព្យសម្បត្តិរបស់តតិយជនហើយទាមទារឱ្យតុលាការអនុវត្តដកចេញនៅការអនុវត្តនោះ ។ ផលប្រយោជន៍ដែលតតិយជនមាន គឺកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត ។ សិទ្ធិផ្សេងទៀត ដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់ទ្រព្យសម្បត្តិជាសិទ្ធិដែលអាចអះអាងចំពោះម្ចាស់បំណុលនៃការអនុវត្ត មានដូចជាសិទ្ធិកាន់កាប់ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព ភតិសន្យា សិទ្ធិឃាត់ទុក ឬសិទ្ធិលើការបញ្ចាំ។ នៅក្នុងបណ្តឹងតវ៉ារបស់តតិយជននេះ បុគ្គលដែលក្លាយជាដើមចោទ គឺជាតតិយជនដែលមានកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ទ្រព្យសម្បត្តិ រីឯបុគ្គលដែលត្រូវបានហៅថាចុងចម្លើយ គឺជាម្ចាស់បំណុលនៃការអនុវត្ត ។ ចំពោះកូនបំណុលនៃការអនុវត្តនៅក្នុងដីកាសម្រេចនោះ ពុំមានលក្ខណៈសម្បត្តិជាដើមចោទ ឬចុងចម្លើយក្នុងបណ្តឹងតវ៉ារបស់តតិជននោះទេ ព្រោះកម្មវត្ថុនៃការដកចេញការប្រគល់ទ្រព្យរបស់តតិយជនកូនបំណុលនៃការអនុវត្តពុំមានផលប្រយោជន៍ និងចាំបាច់ក្នុងនីតិវិធីនេះឡើយ ។

[67] សូមមើលមាត្រា ៥៥៤-៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[68] មាត្រា ៣៦៣-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ហេតុដូច្នេះនៅពេលមានការប៉ះពាល់ដល់ កម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត របស់តតិយជនដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់ទ្រព្យសម្បត្តិ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ហេតុនេះតតិយជនអាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលចេញដីកាសម្រេចនោះ ។

ឧទាហរណ៍ លោក A បានលក់ម៉ូតូ ទៅឱ្យលោក B ក្នុងតម្លៃ ២០០០ ដុល្លារអាមេរិក កំណត់ថ្ងៃប្រគល់ម៉ូតូនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ដោយលោក B បានប្រគល់ថ្លៃលក់ទិញម៉ូតូគ្រប់ចំនួនអស់ហើយ រង់ចាំថ្ងៃទៅយកម៉ូតូទៅផ្ទះរបស់លោក A ។ លុះដល់ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២២ លោក C បានរឹបអូសយកម៉ូតូនោះបាត់ ។ ក្នុងករណីនេះ លោក B បានដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជនដើម្បីប្រឆាំងនឹងលោក C ផ្អែកលើកម្មសិទ្ធិរបស់លោក B ។

**កថាភាគទី២. សមត្ថកិច្ច**

ការតវ៉ា គឺជាវិធីនៃបណ្ដឹងឧបាស្រ័យមួយប្រភេទដែលក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិក្នុងធ្វើការប្តឹងទៅតុលាការថ្នាក់ដដែល មានន័យថាអ្នកដាក់ពាក្យបណ្ដឹងតវ៉ានឹងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវដាក់ពាក្យនោះចូលទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះហើយការតវ៉ានេះទៀតសោត មិនមានការកំណត់អំឡុងពេលឡើយឱ្យតែដីកាសម្រេចនៅមានសុពលភាពមិនដូចជាការប្ដឹងជំទាស់ទេ ពោលគឺនៅពេលដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលត្រូវបានចេញដោយសាលាឧទ្ធរណ៍ ក្នុងនាមជាតុលាការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នវិញ គឺត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន[៦៩] ។

**ផ្នែកទី៣. ការលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចត្រូវបានលុបចោលដោយមានពីរករណីផ្សេងទៀត ក្រៅពីការលុបចោលដោយសារការតវ៉ា គឺការលុបចោលដោយសារការមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដីជាអាទិ៍[70] និងការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព[71] ដែលមាននីតិវិធីដាច់ដោយឡែកពីគ្នាតាមពាក្យសុំរបស់កូនបំណុល ។

១.ចំពោះការលុបចោលដោយសារការមិនបានដាក់ពាក្យបណ្ដឹងអង្គសេចក្ដី នៅពេលដែលតុលាការចេញនូវដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវបង្គាប់ឱ្យម្ចាស់បំណុល ឬ អ្នកដាក់ពាក្យសុំ ដាក់ពាក្យបណ្ដឹងអង្គសេចក្ដី និងដាក់ឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យតាមពាក្យសុំរបស់កូនបំណុល។ ការបង្គាប់ឱ្យដាក់ពាក្យនេះមានគោលបំណងបង្ខំឱ្យម្ចាស់បំណុលទៅទទួលលិខិតអនុវត្ត សម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ដែលគុណប្រយោជន៍នៃការបង្គាប់នេះគឺដើម្បីការពារការខូចខាតរបស់កូនបំណុលដែលបណ្ដាលមកពីការទុកនូវដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

[៦៩] មាត្រា ៥៦៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[70] សូមមើលមាត្រា ៥៥៧-១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[71] សូមមើលមាត្រា ៥៥៨ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

រយៈចោលយូរ ។ កូនបំណុលខ្លួនឯងផ្ទាល់អាចដាក់ពាក្យសុំឱ្យម្ចាស់បំណុលដាក់បណ្តឹងអង្គសេចក្តីបាន ដោយមិនតម្រូវមានលក្ខខណ្ឌទាមទារអ្វីទេក្នុងការដាក់ពាក្យសុំនោះ ។ ម្ចាស់បំណុលមានពេលមិនតិចជាង ០២ (ពីរ) សប្តាហ៍ក្នុងការដាក់ពាក្យបណ្តឹងអង្គសេចក្តី [72] ។

ហេតុនេះ ម្ចាស់បំណុលបន្ទាប់ពីទទួលបានការបង្គាប់ឱ្យដាក់បណ្តឹងអង្គសេចក្តីហើយត្រូវដាក់ឯកសារបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមកាលកំណត់ក្នុងពាក្យបង្គាប់។ បើពុំដូច្នេះទេ តុលាការនឹងសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតាមការស្នើសុំរបស់កូនបំណុល ហើយប្រសិនជាពាក្យបណ្តឹងអង្គសេចក្តីត្រូវបានដកវិញ ឬ ត្រូវបានលុបចោលក្រោយពីម្ចាស់បំណុលដាក់ឯកសារបញ្ជាក់ហើយ ឯកសារនោះនឹងត្រូវចាត់ទុកថាមិនបានដាក់ទេ ។

២.ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព ក្នុងករណីដែលមានការរលត់នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរស្ថានភាពផ្សេងនៃស្ថានភាព តុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ តុលាការបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចោលបានតាមពាក្យស្នើសុំរបស់កូនបំណុល ។

ចំពោះការផ្លាស់ប្តូរស្ថានភាពផ្សេងនៃស្ថានភាពត្រូវបានចែកចេញជាពីរប្រភេទទៀតមានដូចខាងក្រោម៖

+ប្រភេទទី១ គឺក្រោយពេលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានចេញហើយ តែមានលេចឡើងនូវអង្គហេតុថ្មី ដែលនាំឱ្យដីកាសម្រេចនោះមានភាពមិនត្រឹមត្រូវ ។

ឧទាហរណ៍ទី១. ករណីសិទ្ធិដែលត្រូវបានរក្សាការពារត្រូវបានសងគ្រប់ចំនួន

លោក សំណាង ជាកូនបំណុល និងលោក វិបុល ជាម្ចាស់បំណុល បានដាក់ពាក្យសុំដីកាសម្រេចទៅតុលាការក្នុងគោលបំណងទាមទារឱ្យ លោក សំណាង សងប្រាក់ដែលបានកម្ចីនោះមកវិញ។ នៅពេលដែលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើផ្ទះរបស់លោក សំណាង បន្ទាប់ពីទទួលបានដីកាសម្រេច លោកសំណាង បានយកប្រាក់ដែលខ្លួនបានកម្ចីទាំងប៉ុន្មាន ទៅសងលោក វិបុល វិញ។

ឧទាហរណ៍ទី២. ករណីដែលមានសាលក្រមនៃការជំនុំជម្រះលើកទី១ សម្រេចឱ្យម្ចាស់បំណុលចាញ់ក្តី នៅក្នុងបណ្តឹងអង្គសេចក្តី

កញ្ញា ជីវ៉ា ជាដើមចោទ និងលោក សុចិត្រ ជាចុងចម្លើយ នៅក្នុងនីតិវិធីនៃបណ្តឹងអង្គសេចក្តី ក្រោយពីស្តាប់តាមការអះអាង និងភស្តុតាង តុលាការបានរកឃើញថា កញ្ញា ជីវ៉ា ពុំមានសិទ្ធិក្នុងការទាមទារឱ្យ លោក សុចិត្រ សងប្រាក់វិញនោះទេ ដោយសារតែលោក សុចិត្រ បានបំពេញកាតព្វកិច្ចសងប្រាក់ទៅកញ្ញា ជីវ៉ា រួចសព្វគ្រប់អស់ហើយ ដូច្នេះ កញ្ញា ជីវ៉ា ជាម្ចាស់បំណុលត្រូវបានតុលាការចេញសាលក្រមជាអ្នកចាញ់ក្តី។

ឧទាហរណ៍ទី៣. ករណីដែលមានកូនបំណុលក្លាយជាអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីសង

[72] មាត្រា ៥៩៧-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

តុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើដីរបស់លោក A តាមពាក្យសុំរបស់លោកស្រី B ក្រោយពីពិនិត្យឃើញថា លោក A ពិតជាមិនបានគោរពកាតព្វកិច្ចសងប្រាក់ទៅលោកស្រី B វិញ បើទោះជាបីមានការជូនដំណឹងយ៉ាងណាក៏ដោយ ដោយហេតុ លោក A ចង់រួចផុតពីការអនុវត្តដីកាសម្រេចលើដីរបស់ខ្លួន លោក A បានដាក់រំដោះស្មើនឹងចំនួនសិទ្ធិលើដែលម្ចាស់បំណុលធ្វើការទាមទារ ទៅតុលាការចេញដីកាសម្រេចដដែលនោះ ។

ឧទាហរណ៍ទី៤.ករណីដែលម្ចាស់បំណុលមិនធ្វើការអនុវត្តដោយបង្ខំ បើទោះបីជាបានបំពេញគ្រប់លក្ខខណ្ឌទាមទារដែលអាចអនុវត្តដោយបង្ខំបានហើយក៏ដោយជាអាទិ៍

លោក X បានឈ្នះក្តី បន្ទាប់ពីការប្រកាសសាលក្រមរបស់តុលាការ ដែលលោក X អាចធ្វើការប្រកាសលក់ផ្ទះរបស់លោក Y បាន ក្នុងការទទួលបានចំណែកនៃសិទ្ធិលើបំណុលរបស់ខ្លួន ប៉ុន្តែលោក X មិនបានពាក្យសុំអនុវត្តដោយបង្ខំឡើយ ដែលជាហេតុនាំឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោលតាមការស្នើសុំរបស់កូនបំណុល ។

+ប្រភេទទី២ គឺនៅពេលដែលកូនបំណុលបានដឹងអំពីអង្គហេតុដែលនាំឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះមានភាពមិនត្រឹមត្រូវ ឬ អាចធ្វើសេចក្តីបញ្ជាក់ដំបូងអំពីហេតុនោះ នៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទោះបីជាអង្គហេតុនោះបានកើតឡើងនៅពេលដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នក៏ដោយ ។ នៅក្នុងករណីនេះកូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង អំពីការផ្លាស់ប្តូរស្ថានភាពនោះ [73] ។

ដូច្នេះ ប្រសិនជាម្ចាស់បំណុលមិនបានដាក់បណ្តឹងអង្គសេចក្តី និងឯកសារបញ្ជាក់អំពីពាក្យបណ្តឹងអង្គសេចក្តីតាមការបង្គាប់របស់តុលាការឱ្យទាន់ពេលកំណត់នោះទេ និងមានការផ្លាស់ប្តូរស្ថានភាព ករណីទាំងអស់នេះហើយ ជាហេតុនាំឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោលតាមពាក្យសុំរបស់កូនបំណុល ។

**កថាភាគទី១. ការទាញហេតុផលដោយផ្ទាល់មាត់**

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាដំណាក់កាលនៃនីតិវិធីដែលផ្តល់ឱកាសដល់គូភាគីចូលរួមក្នុងនីតិវិធីក្នុងការសម្រេចសេចក្តីនោះ ដើម្បីអាចអះអាង និងធ្វើការថ្លែងការណ៍ចំពោះការស្នើសុំឱ្យតុលាការលុបចោលដីកាសម្រេច ។

ដូច្នេះ នៅក្នុងការស្នើសុំឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នពីកូនបំណុល គឺត្រូវឆ្លងកាត់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមការសួរនៃកាលបរិច្ឆេទដែលភាគីអាចចូលរួមបានផងដែរ ។

**កថាភាគទី ២. ការផ្អាកលើការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

ការផ្អាកលើការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចត្រូវផ្អាកក្នុងលក្ខណៈជាផ្អាកការអនុវត្តដីកាសម្រេចដោយសារមានពាក្យសុំប្តឹងតវ៉ាចំពោះសេចក្តីសម្រេច ឬ ពាក្យសុំលុបចោលនូវដីកាសម្រេចរឹបអូសជា

[73] មាត្រា ៥៥៨-២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

បណ្ដោះអាសន្នដោយឱ្យដាក់ប្រាតិភោគហូតបាន ឬ មិនដាក់ប្រាតិភោគហូតដល់ពេលធ្វើសេចក្ដីសម្រេចថាតើដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបានទទួលស្គាល់ ឬ ផ្លាស់ប្ដូរ ឬ លុបចោលនូវដីកាសម្រេចជាមុនសិន [74] ។

លើសពីនេះ ការផ្អាកក្រោយការអនុវត្តដីកាសម្រេចពុំប្រសិទ្ធភាពទេ ដោយសារតែការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបានបញ្ចប់នៅត្រឹមដំណាក់កាលនៃការអនុវត្តដីកាសម្រេចតែប៉ុណ្ណោះ ។

[74] សូមមើលមាត្រា ៥៥១ -១,២,៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវនូវប្រធានបទ "នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះទ្រព្យ" រួចមក នាងខ្ញុំអាចសន្និដ្ឋានបានថា វាជានីតិវិធីមួយដែលមានលក្ខណៈបន្ទាន់បង្ខំ បណ្តោះអាសន្ន និងសម្ងាត់ ដែលច្បាប់បានបង្កើតឡើង ក្នុងគោលបំណងការពារសិទ្ធិរបស់ម្ចាស់បំណុល នៅពេលដែលបុគ្គលណាមួយដែលមានសិទ្ធិលើបំណុលមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ដែលបង្កឱ្យមានការលំបាកដល់ម្ចាស់បំណុលក្នុងការអនុវត្តសិទ្ធិនាពេលអនាគត ដោយធ្វើការរក្សាទ្រព្យទទួលខុសត្រូវឱ្យនៅក្នុងស្ថានភាពដដែល ដើម្បីបង្ការកុំឱ្យកូនបំណុលផ្ទេរកម្មសិទ្ធិនៃទ្រព្យសម្បត្តិក្នុងរូបភាពណាមួយទៅឱ្យតតិយជនបាត់ ។ ហេតុនេះម្ចាស់បំណុលដែលមានគោលបំណងទាមទារឱ្យសងជាប្រាក់អាចអនុវត្តដោយបង្ខំបាន តាមរយៈការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននេះមានដូចជា សិទ្ធិលើបំណុល និងលើទ្រព្យសម្បត្តិ ចលនវត្ថុ អចលនវត្ថុ និងនាវា ។ ក្នុងករណីម្ចាស់បំណុលចង់រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺចាំបាច់ត្រូវតែកំណត់កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នឱ្យបានច្បាស់លាស់ និងត្រូវបញ្ជាក់អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ និងភាពចាំបាច់ត្រូវរក្សាការពារ ពីព្រោះវាជាលក្ខខណ្ឌចាំបាច់នៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ។ នៅពេលដែលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បានបំពេញគ្រប់លក្ខខណ្ឌនៃនីតិវិធីច្បាប់ តុលាការនឹងចេញដីកាសម្រេចតាមពាក្យស្នើសុំនោះ។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន នឹងលែងមានអានុភាព នៅពេលតុលាការអនុវត្តរក្សាការពារមិនបានទទួលពាក្យសុំឱ្យអនុវត្តដីកាសម្រេច ពីម្ចាស់បំណុល ក្នុងរយៈពេលពីរ សប្តាហ៍ ដែលនេះជាមូលហេតុនូវនៃការលុបចោលដីកាសម្រេច។ លើសពីនេះទៀត ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើឡើងតាមការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នលើអចលនវត្ថុ ដែលមានក្រឡាបញ្ជីជាអ្នកធ្វើលិខិតផ្ញើផ្ទាក់ និងបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីរឹបអូសអចលនវត្ថុនោះ។ ក្រោយពីការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នរួចហើយ ច្បាប់ក៏អនុញ្ញាតដល់ភាគីកូនបំណុល តតិយជន ឬ ជនដែលជាប់ពាក់ព័ន្ធផលប្រយោជន៍ ដែលមិនសុខចិត្តនឹងការរឹបអូសជាបណ្តោះអាសន្ន អាចដាក់ពាក្យប្តឹងតវ៉ា និងលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះបាន។ ត្បិតតែនីតិវិធីនេះ វាបានផ្តល់ផលប្រយោជន៍ក្នុងការការពារសិទ្ធិចំពោះម្ចាស់បំណុលក៏ពិតមែន ប៉ុន្តែក្នុងករណីដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការមិនបានបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគដែលជាប្រាក់ធានាសំណងនៃការខូចខាត នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន នៅពេលមានសាលក្រមជាស្ថាពរសម្រេចឱ្យម្ចាស់បំណុលចាញ់បណ្តឹងអង្គសេចក្តី កូនបំណុលនឹងពិបាកអនុវត្តសិទ្ធិរបស់ខ្លួន បើទោះបីជាខ្លួនមានសិទ្ធិទាមទារសំណងនៃការខូចខាតក៏ដោយផ្អែកលើអំពើអនីត្យានុកូលក៏ដោយ។

យ៉ាងណាមិញ ច្បាប់ក៏មិនតឹងរ៉ឹងដាច់ខាតដែរ មានន័យថាកូនបំណុលដែលចង់រួចផុតពីការរឹបអូសជាបណ្តោះអាសន្នអាចដាក់ប្រាក់រំដោះបាន នៅពេលដែលការប៉ះពាល់ដល់ប្រយោជន៍របស់ខ្លួនពីការអនុវត្តដីកាសម្រេចនោះ ប៉ុន្តែកូនបំណុលមិនសុខចិត្តនឹងដីកាសម្រេចនោះ ច្បាប់ផ្តល់សិទ្ធិក្នុងការប្តឹងជំទាស់ទៅសេចក្តីសម្រេចរបស់តុលាការ ហើយកូនបំណុលអាចចូលរួមនៅក្នុងនីតិវិធីនេះបាន ដែលវាបង្ហាញយើងឱ្យឃើញអំពីអំណាចតុលាការក្នុងការធានារក្សាអនាគត និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ដោយទទួលបានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។

សរុបសេចក្តីជារួមមក នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន គឺជានីតិវិធីមួយដែលបង្កកនូវទ្រព្យសម្បត្តិរបស់កូនបំណុលដោយមិនអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិទៅឱ្យតតិយជនបាន ក្នុងគោលបំណងដើម្បីអនុវត្តដោយបង្ខំផ្អែកលើសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ។ ហើយនីតិវិធីនេះពិតជាសារៈប្រយោជន៍ណាស់ សម្រាប់ម្ចាស់បំណុលដែលចង់ទាមទារសិទ្ធិរបស់ខ្លួន ពីព្រោះវាមានប្រើពេលឆាប់រហ័សដែលអាចទប់ស្កាត់ជាបណ្តោះអាសន្ននៅមុនពេលមានសេចក្តីសម្រេចពីបណ្តឹងអង្គសេចក្តី។ ដូចនេះ ម្ចាស់បំណុលដែលមានគោលបំណងទាមទារឱ្យសងជាប្រាក់អាចជ្រើសរើសយកវិធីនេះ បានដើម្បីអាចអនុវត្តសិទ្ធិលើបំណុលបាន ។

# អនុសាសន៍

# អនុសាសន៍

ការរឹបអូសជាបណ្តោះអាសន្នចំពោះទ្រព្យ នេះវាពិតជាបានការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុលក៏មិនមែន ប៉ុន្តែនៅពេលដែលទម្រាំតែមានការវិនិច្ឆ័យពីតុលាការ ធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ភាគីដែលខាតបង់ពេលវេលា និងប្រាក់កក់ ជាពិសេសតាមការអនុវត្តជាក់ស្តែងនៅក្នុងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ពុំសូវឃើញមានតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគទេ និងមិនមានច្បាប់សម្រាប់កំណត់អំពីចំនួនច្បាប់ គឺអាស្រ័យលើតុលាការជាអ្នកកំណត់ ដែលត្រង់ចំណុចនេះវាពិតជាមានហានិភ័យសម្រាប់កូនបំណុល ក្នុងការទាមទារសំណងនៃការខូចខាតពីការអនុវត្តដីកាសម្រេចនោះ ប្រសិនជាកម្មវត្ថុនៃការរឹបអូសត្រូវបានធ្លាក់ថ្លៃ ឬបរិមាណ ដែលបណ្តាលឱ្យកូនបំណុលខាតបង់ផលប្រយោជន៍ ហេតុនេះអ្នកច្បាប់ត្រូវធ្វើបញ្ញត្តិបន្ថែមស្តីពីការកំណត់ចំនួនប្រាតិភោគឱ្យបានច្បាស់លាស់ និងលក្ខខណ្ឌតម្រូវឱ្យដាក់ប្រាតិភោគគ្រប់ដីកាសម្រេចទាំងអស់ ។ មួយវិញទៀត នីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ វាប្រើរយៈពេលលឿនសម្រាប់ការចេញដីកាសម្រេចក៏មិនមែនប៉ុន្តែជួនកាលប្រសិនជាកូនបំណុលជាជនសុចរិត កំពុងជួបវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ ហើយត្រូវការប្រាក់សម្រាប់ដោះស្រាយបញ្ហាជាការចាំបាច់ និងលំបាកក្នុងករណីអចលនវត្ថុរបស់ខ្លួនត្រូវបានម្ចាស់បំណុលរឹបអូសដែលធ្វើឱ្យកូនបំណុលស្ថិតនៅក្នុងស្ថានភាពរឹតតែទល់ច្រក ដោយមិនអាចឱកាសសុំឱ្យម្ចាស់បំណុលទុកពេលពន្យារសង ឬ ដោះស្រាយបំណុលដោយវិធីផ្សេងទៀត ដោយហេតុថាចរិតលក្ខណៈនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានការសម្ងាត់ ហើយប្រសិនជាឯកសារភស្តុតាងដែលម្ចាស់បំណុលបានដាក់ជាឯកសារក្លែងក្លាយវិញវាធ្វើឱ្យខូចខាតប្រយោជន៍របស់កូនបំណុល ដោយសារនៅក្នុងនីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នភាគច្រើនតុលាការមិនហៅកូនបំណុលសាកសួរទេ ពោលគឺចេញដីកាសម្រេចដោយផ្អែកតាមសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល ជាហេតុនាំឱ្យកូនបំណុលខាតបង់ពេលវេលា ប្រាក់សម្រាប់ចំណាយក្នុងនីតិវិធី និងកិត្តិយស ទម្រាំតែតុលាការរកការពិតឃើញ ដូច្នេះ តុលាការគប្បីសិក្សាទៅលើឯកសារភស្តុតាងឱ្យបានស៊ីជម្រៅជាមុនសិន ព្រោះករណីក្លែងឯកសារត្រូវបានអនុវត្តយ៉ាងទូលំទូលាយក្នុងសង្គមសព្វថ្ងៃ ។ លើសពីនេះ ក្នុងករណីកម្មវត្ថុដែលរឹបអូសជាកម្មសិទ្ធិអវិភាគ នឹងមានការលំបាកនៅក្នុងករណីដែលសហកម្មសិទ្ធិម្ចាស់អវិភាគដទៃទៀតត្រូវការលក់អចលនវត្ថុរបស់ខ្លួនជាបន្ទាន់ ហើយអ្នកទិញមានលក្ខខណ្ឌចាំបាច់ប្រមូលទិញយកដី ឬ ផ្ទះទាំងមូលដែលកម្មសិទ្ធិមួយផ្នែកត្រូវបានរឹបអូស ដូច្នេះវាពិបាកដល់សហកម្មសិទ្ធិផ្សេងក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ។

ម្យ៉ាងវិញទៀត ចំពោះការអនុវត្តការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុវិញ វាក៏មានផលលំបាកដែរដោយសារកង្វះខាតអាជ្ញាសាលា ដែលអាជ្ញាសាលានៅតាមសាលាដំបូងរាជធានីខេត្តនៅមានចំនួនតិចនៅឡើយ ហើយប្រសិនជាមានករណីការអនុវត្តរឹបអូសជាច្រើនករណីក្នុងពេលតែមួយដែលត្រូវធ្វើការអនុវត្ត វានឹងបង្កការយឺតយ៉ាវក្នុងការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល ដែលផ្ទុយពីចរិតលក្ខណៈរបស់ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នគឺ

មានភាពបន្ទាន់បង្ខំ ហេតុនេះស្ថាប័នមានសមត្ថកិច្ចគួរពិចារណាជ្រើសរើសអាជ្ញាសាលាបន្ថែម និងផ្តល់ប្រាក់អត្ថប្រយោជន៍ផ្សេងៗ ។

នៅក្នុងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ននេះ គួរណាតែមានផ្សព្វផ្សាយឱ្យបានទូលំទូលាយពីអត្ថប្រយោជន៍ដែលទទួលបានពីការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងជាពិសេសជម្រុញឱ្យមានការចុះបញ្ជីអចលនវត្ថុដែលខ្លួនកាន់កាប់ឱ្យស្របតាមច្បាប់ និងទទួលបានការពារពីច្បាប់ ។

ស្ថាប័នដែលមានសមត្ថកិច្ច គប្បីពង្រឹងនូវសមត្ថភាពរបស់មន្ត្រីរបស់ខ្លួនក្នុងការបំពេញមុខងារឱ្យបានឆាប់រហ័ស និងប្រកបដោយសុក្រឹតភាព សម្រាប់ជាប្រយោជន៍ជាតិទាំងមូល ។

ការរឹបអូសជាបណ្តោះអាសន្ននេះ វាមានការលំបាកក្នុងស្វែងយល់ និងមានភាពស្មុគស្មាញ ដែលតម្រូវឱ្យនិស្សិត ប្រជាពលរដ្ឋ ឬ អ្នកច្បាប់ទាំងឡាយ គួរណាតែសិក្សាឱ្យបានល្អិតល្អន់ជាមុន និងត្រូវពង្រឹងសមត្ថភាពជាពិសេសអ្នកអនុវត្តច្បាប់ ។

# ឯកសារយោង

# ឯកសារយោង

ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- ប្រកាសអន្តរក្រសួងលេខ៥៩ ស្តីពីនីតិវីធីនៃការចុះអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១១

សៀវភៅនានា ៖

- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ ឆ្នាំ២០០៩ ។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ។
- សំណួរទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៨
- សៀវភៅស្តីពីនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ឆ្នាំ២០០៩ ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១
# កម្រងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ គន្លឹទី៧ ស្ដីពីការចាត់ចែងក្សាការពារ

# គន្ថីទី ៧
# ការចាត់ចែងរក្សាការពារ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៣០.–** គោលគំនិត

ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៥៣១.–** ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗ ខាងក្រោមនេះ :

ក-ការរឹបអូសជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

ខ-ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ : ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

គ-ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូល

ជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

**មាត្រា ៥៣២.-** ស្ថាប័នចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន

១-ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។

២-ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ ។

៣-តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ ត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៣.-** សមត្ថកិច្ចផ្ដាច់មុខ

សមត្ថកិច្ចរបស់តុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ ។

**មាត្រា ៥៣៤.-** របៀបដាក់ពាក្យសុំ

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ :

ក-ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

ខ-ពាក្យបណ្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

គ-ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ។

ឃ-ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ង-ពាក្យបណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (បណ្ដឹងជំទាស់) នៃក្រមនេះ ។

ច-ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៥.–** ការសម្រេចសេចក្ដីចំពោះនីតិវិធីនៃការរក្សាការពារ ជាអាទិ៍

១-ការសម្រេចសេចក្ដីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ និងនីតិ-វិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សាការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬជនដែលពាក់ព័ន្ធផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូងត្រូវសម្រេចសេចក្ដីអំពីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្ត ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៦.–** ការផ្ដល់នូវប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីធ្វើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៧.–** សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅតុលាការ ។

២-ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារទៅតុលាការអនុវត្តការរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការអនុវត្តការរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តការរក្សាការពារ ។

៣-ប្រសិនបើអ្នកដែលដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលា-ការអនុវត្តការរក្សាការពារ អាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារ ឬ អាចលុបចោលនូវនីតិវិធីអនុវត្តការរក្សាការពារបាន ។

៤-ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ អាចប្ដឹងជំទាស់បាន ។

៥-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

**មាត្រា ៥៣៨.-** ការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះនីតិវិធីទាក់ទងនឹងដីកាសម្រេចរក្សាការពារ ឬ នីតិវិធីដែលតុលាការធ្វើឡើងចំពោះការអនុវត្តរក្សាការពារ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តរក្សាការពារដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

**មាត្រា ៥៣៩.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្លីទី ២ ដល់គន្លីទី ៤

បញ្ញត្តិពីគន្លីទី ២ ដល់គន្លីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស ។

## ជំពូកទី ២
## ដីកាសម្រេចរក្សាការពារ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៤០.-** តុលាការដែលមានសមត្ថកិច្ច

១-រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ ។

២-តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើក ទី ១ ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការ ក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែល មានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៣-បើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិ លើបំណុល ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះ ស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែល បានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់នាវា ឬ ចលនវត្ថុ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះស្ថិតនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ ។

៤-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នា ផងដែរ ចំពោះករណីដែលកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃ វិវាទ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ហើយមានកូនបំណុលទី ៣ ឬ បុគ្គល ដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ។

**មាត្រា ៥៤១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្តីបញ្ជាក់ដំបូង

១-ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់នូវចំណុចដូច បានកំណត់ខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ ។

២-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ គប្បី សរសេរឱ្យបានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

៣-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

**មាត្រា ៥៤២.-** ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

**មាត្រា ៥៤៣.-** ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

**មាត្រា ៥៤៤.-** បណ្ដឹងជំទាស់ចំពោះសេចក្ដីសម្រេចលើកចោល

១-ចំពោះសេចក្ដីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្ដឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

**មាត្រា ៥៤៥.-** ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

១-ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

**មាត្រា ៥៤៦.-** កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្ដោះអាសន្ន អាចចេញបាន

ដោយមិនចាំបាច់កំណត់កម្មវត្ថុ។

**មាត្រា ៥៤៧.–** ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

១-ក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះ-អាសន្ន។

២-ការផ្ញើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ។

## ផ្នែកទី ៣

## ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

**មាត្រា ៥៤៨.–** ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នជាអាទិ៍

១-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។

២-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន។

៤-តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការ

ទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានស្ថានភាពពិសេស ដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ ។

**មាត្រា ៥៤៩.-** វិធីចាត់ចែងជាបណ្ដោះអាសន្ន

តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្ដល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

## ផ្នែកទី ៤
## ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥០.-** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលបានចេញដីកាសម្រេចនោះ ។

**មាត្រា ៥៥១.-** ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំដោយឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងក្រោមនេះ ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ លុះត្រាតែមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ ។

២-ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់បានចេញដីកាសម្រេចរក្សាការពារ បើមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្ដី តាម

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។

៣-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥២.-** ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

**មាត្រា ៥៥៣.-** ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ។

**មាត្រា ៥៥៤.-** ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

១-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ ។

២-ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ។

**មាត្រា ៥៥៥.-** ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន

បើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់

ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងបាន តាមពាក្យសុំរបស់កូនបំណុល នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៥៥៦.-** អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ

ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ ។

## ផ្នែកទី ៥
## ការលុបចោលដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥៧.-** ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍

១-តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្ដាហ៍ ។

៣-បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។

៤-ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែល

បានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនោះ ត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ។

៥-ចំពោះការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៣ ខាងលើនេះ បើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកជាការដាក់ពាក្យបណ្តឹងអង្គសេចក្តី ។

៦-បើនីតិវិធីមជ្ឈត្តកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ បានចប់មិនមែនដោយសេចក្តីសម្រេចមជ្ឈត្តករ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តី ក្នុងអំឡុងពេលដូចគ្នានឹងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចាប់ពីថ្ងៃដែលនីតិវិធីមជ្ឈត្តកម្មនោះបានចប់ ។

៧-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ហើយបញ្ញត្តិនៃកថាខណ្ឌទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបណ្តឹងអង្គសេចក្តីត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ៦ តែក្រោយមកត្រូវបានដកវិញ ឬ ត្រូវបានលើកចោល ។

៨-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចតាមកថាខណ្ឌទី ៣ និង ទី ៧ ។

**មាត្រា ៥៥៨.-** ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព

១-បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន ។

២-ចំពោះការផ្លាស់ប្តូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកា

សម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥៩.–** ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេស

១-ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដីអាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់កូនបំណុល ។

២-ចំពោះស្ថានភាពពិសេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៦០.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍

១-បញ្ញត្តិពីមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីអំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) ។

២-ចំពោះការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្ត

ដូចគ្នា នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្តឹងអង្គសេចក្តី ផ្សេងពីតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ តុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ផ្នែកទី ៦
## បណ្តឹងជំទាស់

**មាត្រា ៥៦១.-** បណ្តឹងជំទាស់

១-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ អាចប្តឹងជំទាស់ក្នុងអំឡុងពេល២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូននោះ :

ក-ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ខ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ។

គ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥៦០ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍) ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្តីសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលបានធ្វើឡើងដោយតុលាការនៃបណ្តឹងជំទាស់ ។

២-អំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានទេ ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៥២ (ការវិនិច្ឆ័យអំពីការតវ៉ា

ចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) និង មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីដែលពាក់ព័ន្ធនឹងបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសេចក្តីសម្រេចដែលអាចប្តឹងជំទាស់បាន បានចូលជាស្ថាពរ ។

៤-ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងករណីដែលមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ជំពូកទី ៣
## ការអនុវត្តរក្សាការពារ

**មាត្រា ៥៦២.-** លក្ខខណ្ឌនៃការអនុវត្តរក្សាការពារ

១-ការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ។ ប៉ុន្តែ ការអនុវត្តរក្សាការពារចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត ។

២-ការអនុវត្តរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ (ពីរ) សប្តាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល ។

៣-ទោះបីនៅមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារ អាចធ្វើបានដែរ ។

**មាត្រា ៥៦៣.-** ករណីពិសេសនៃតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងតវ៉ារបស់តតិយជន

ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) នៃក្រមនេះក៏ដោយ ក៏បណ្តឹងតវ៉ារបស់តតិយជន ចំពោះដីកាសម្រេចរក្សាការពារដែលសាលាឧទ្ធរណ៍បានធ្វើ ក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ ។

**មាត្រា ៥៦៤.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦

លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងជំពូកនេះ បញ្ញត្តិពីមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) ដល់មាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៤៨ (អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ) បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ នៃមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) កថាខណ្ឌទី ២ នៃមាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) កថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ៣៥៥ (ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត) ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ពីមាត្រា ៣៥៧ (ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត) ដល់មាត្រា ៣៥៩ (ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត) មាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត) និង មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) និង បញ្ញត្តិពីមាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ដល់មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះការអនុវត្តរក្សាការពារ ។

**មាត្រា ៥៦៥.-** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ ។

២-អាជ្ញាសាលាត្រូវធ្វើប្រាក់ដែលបានមកពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ ។

៣-បើមានការបារម្ភថា ចលនវត្ថុដែលការរឹបអូសជាបណ្តោះអាសន្នត្រូវបានអនុវត្តនឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងផ្នែកទី ២ ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន ឬ កូនបំណុល ហើយធ្វើប្រាក់ដែលបានមកពីការលក់នោះ នៅតុលាការដែលខ្លួនស្ថិតនៅ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) ពីមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) ដល់មាត្រា ៣៩២ (ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ។

**មាត្រា ៥៦៦.-** ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុល ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចរឹបអូសបណ្តោះអាសន្ន ត្រូវមានសមត្ថ-

កិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្នុងករណីដែលការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ បើកូនបំណុលទី៣បានធ្វើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា កូនបំណុលបានធ្វើប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះភាគដែលលើសពីចំនួនប្រាក់នោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ ទី ៣ ទី ៦ ទី៧ ទី ៨ ទី ១០ និង កថាខណ្ឌទី ១១ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) បញ្ញត្តិពីមាត្រា ៤០៤ (ទំហំនៃការរឹបអូស) ដល់មាត្រា ៤០៨ (ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍) មាត្រា ៤១១ (ការធ្វើប្រាក់ទុកដោយកូនបំណុលទី ៣) និងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះ-អាសន្នចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

**មាត្រា ៥៦៧.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) នៃក្រមនេះ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤២០ (ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស

ជាអាទិ៍) វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ នៃមាត្រា ៤២១ (អានុភាពនៃការរឹបអូស) កថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) មាត្រា ៤២៥ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) និង មាត្រា ៤២៨ (ការផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ។

**មាត្រា ៥៦៨.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្ដល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ។ របៀបទាំងនេះ អាចអនុវត្តរួមគ្នាបាន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) មាត្រា ៤៦៥ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍) និង មាត្រា ៤៦៦ (ការផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះ-អាសន្នតាមរបៀបចុះបញ្ជី ហើយបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) កថាខណ្ឌទី ៧ នៃមាត្រា ៤៥៧ (ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍) មាត្រា ៤៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) និង

មាត្រា ៤៦២ (ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ ។

**មាត្រា ៥៦៩.-** ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

១-បើកូនបំណុលបានធ្វើប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ នៅតុលាការ តុលាការអនុវត្តរក្សាការពារ ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវលុបចោលនូវការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកអនុវត្តដូចគ្នា នៅក្នុងមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) ក៏ដោយ ក៏ដីកាសម្រេចដែលធ្វើឡើង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមៗដែរ ។

**មាត្រា ៥៧០.-** ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្តោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ ។

**មាត្រា ៥៧១.-** អានុភាពនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

១-បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាប់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាប់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត ។

២-បើការចាត់ចែងជាបណ្តោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្តី ។ ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននោះត្រូវបានធ្វើហើយ ។

៣-ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធក្រោយពេលការអនុវត្តចាត់ចែងជាបណ្តោះ-អាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ននោះ ត្រូវបានធ្វើហើយ ។

# ឧបសម្ព័ន្ធទី២
# ពាក្យសុំដីកាសម្រេចរក្សាការពារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៣៣*៣៣៣

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃទី06 ខែ05 ឆ្នាំ2022

## ពាក្យស្នើសុំចេញដីកាសម្រេចរក្សាការពារ

**ម្ចាស់បំណុល:**

ឈ្មោះ ភេទប្រុស អាយុ៤៣ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦៤E₀ ភូមិក្រាំងអង្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ លេខទូរស័ព្ទទំនាក់ទំនង០១៦ ៣០៤ ៤៤៤។

**សហកូនបំណុល:**

១.ឈ្មោះ ភេទស្រី កើតនៅឆ្នាំ១៩៦៩ និងប្តីឈ្មោះ សញ្ជាតិខ្មែរទីលំនៅបច្ចុប្បន្នផ្ទះលេខ ១០៨ ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

២.ឈ្មោះ ភេទប្រុស កើតនៅឆ្នាំ១៩៦៥ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៣.ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិពងទឹក ឃុំរការពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

សាលាដំបូងរាជធានីភ្នំពេញ
បង្កាន់ដៃលេខ 00197409
ថ្ងៃទី 06 ខែ 05 ឆ្នាំ 2022

**សូមគោរពជូន**
**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ:** ១.សុំឲ្យតុលាការចេញដីកាសម្រេចចាត់ចែងរឹបអូសជាបណ្តោះអាសន្នលើរថយន្តម៉ាក TOYOTA LANCRUISER ពាក់ស្លាកលេខ ភ្នំពេញ2K-៤២៤២ ផលិតឆ្នាំ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 ពណ៌ខ្មៅ។

២.ប្រាក់ប្រដាប់ក្តីទទួលបន្ទុកលើសហកូនបំណុល។

**យោង:** -មាត្រា ៥៣០, ៥៤៨, ៥៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-លិខិតលក់រថយន្ត ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨

-កិច្ចសន្យាប្រគល់ដី ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨

តមតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំជាមេធាវីតំណាងដោយអាណត្តិឲ្យម្ចាស់បំណុល សូមជម្រាបជូន ឯកឧត្តមប្រធាន អំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវរក្សាការពារភាពចាំបាច់នៃការរក្សាការពារដូចខាងក្រោម:

### ក. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តជាអង្គហេតុចាំបាច់បញ្ជាក់នូវការទាមទារ

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ម្ចាស់បំណុលឈ្មោះ និង កូនបំណុលឈ្មោះ បានបង្កើតកិច្ចសន្យាលក់-ទិញ រថយន្តម៉ាក TOYOTA LANCRUISER ពាក់ស្លាកលេខ ភ្នំពេញ2K-៤២៤២ ផលិតឆ្នាំ ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 ពណ៌ខ្មៅ ដែលតម្លៃនៃការលក់រថយន្តនេះជាថ្នូរ ទិញលក់ដីចំការទំហំ ១២ ហិកតា តម្លៃ ៦៥០០០$ ស្ថិតនៅភូមិអន្លង់ស្វែង ឃុំស្វាយចចិប ស្រុកបសេដ្ឋ

ខេត្តកំពង់ស្ពឺ។ ប៉ុន្តែកូនបំណុលឈ្មោះ មិនគោរព និងអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យានោះទេ កិច្ចសន្យាបានមកដល់ក្នុងកាលបរិច្ឆេទសម្រាប់ការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យានេះ។

នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ម្ចាស់បំណុល និងសហកូនបំណុល និងប្តីឈ្មោះ បានជួបពិភាក្សាគ្នា ហើយសហកូនបំណុលបានព្រមព្រៀងប្រគល់ដីមួយកន្លែងផ្សេងទៀត មានទំហំចំនួន ២០ ហិកតា ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៨ ដែលមានទីតាំងស្ថិតនៅភូមិស្រែជើងវៈ ឃុំក្រញូវ ស្រុកត្រាំងកក់ ខេត្តតាកែវ ជំនួសឱ្យដីលក់-ទិញ ១២ ហិកតា ដែលពីមុខគ្មានដីលក់។ ក្រោយពីចុះដល់ទីតាំងដីទំហំ ២០ ហិកតា ម្ចាស់បំណុលបានរកឃើញថាសហកូនបំណុល បានប្រើសកម្មភាពទុច្ចរិតយកដីសម្បទាន របស់ក្រុមហ៊ុន JUHEF LIMITED ហើយសហកូនបំណុល បានឆ្លើយតបបានត្រឹមតែពន្យាពេលចូលមកបង្ហាញឆន្ទៈក្នុងការទិញ-លក់ម្តងហើយម្តងទៀតតែប៉ុណ្ណោះ និងសហាចុងចម្លើយ បានគេចវេសមិនព្រមអនុវត្តកាតព្វកិច្ចលក់-ទិញដីនោះឱ្យបានពេញលេញ ធ្វើឱ្យបាត់ទំនុកចិត្ត និងគ្មានដំណោះស្រាយ ហើយមិនសង្ឃឹមថាអនាគតមិនអាចអនុវត្តបានទើបសុំរំលាយកិច្ចសន្យានេះ និងឱ្យប្រគល់វត្ថុមកវិញ រួមទាំងសំណងខូចខាត។

កាលបរិច្ឆេទការអនុវត្តកាតព្វកិច្ចបានកន្លងហួស ម្ចាស់បំណុលបានធ្វើការទំនាក់ទំនងទៅសហកូនបំណុលឈ្មោះ និងប្តីឈ្មោះ តាមរយៈទូរស័ព្ទ និងការណាត់ជួបផ្ទាល់យ៉ាងណាក៏ដោយ កូនបំណុលឈ្មោះ និងប្តីឈ្មោះ ពុំបានចូលមកបង្ហាញឆន្ទៈក្នុងការអនុវត្តការទិញ-លក់ដី ដែលមានការដាក់កាលបរិច្ឆេទច្បាស់លាស់ អំពីការចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅអង្គភាពសុរិយោដីមិនឱ្យលើសពីមួយសប្តាហ៍ តែកូនបំណុលឈ្មោះ មិនបានអនុវត្តបានម្តងណាសោះ គឺបានត្រឹមតែពន្យាពេលគ្មានកាលកំណត់ច្បាស់លាស់ ទើបសុំទាមទាររំលាយកិច្ចសន្យានេះ ហើយឱ្យប្រគល់វត្ថុរថយន្ត និងការសងការខូចខាត។

## ខ.ភាពចាំបាច់នៃការរក្សាការពារ

កូនបំណុលឈ្មោះ បានចាត់ចែងដោយលក់រថយន្តម៉ាក TOYOTA LANCRUISER ខាងលើនេះទៅឱ្យឈ្មោះ ហើយក៏បានលក់បន្តទៅឈ្មោះ តាមអំពើចិត្តរបស់ពួកគេ។ បើសិនជាសហកូនបំណុលអាចចាត់ចែងបន្តផ្សេងៗ និងធ្វើសកម្មភាពបង្កឱ្យមានភាពស្មុគស្មាញបន្ថែមទៀតលើរថយន្តខាងលើនេះបានមុនការសម្រេចសេចក្តីណាមួយដោយសមត្ថកិច្ចតុលាការ នោះវានឹងអាចធ្វើកូនក្តីនាងខ្ញុំ ជាម្ចាស់បំណុលមានការខាតបង់រឹតតែធ្ងន់ធ្ងរចំពោះផលប្រយោជន៍នេះ។ ម្យ៉ាងទៀតបើមានការលក់ដូរផ្ទេរកម្មសិទ្ធិធ្វើប្រទានកម្មដាក់ប្រាតិភោគជួល និងការប្រើសិទ្ធិផ្សេងៗទៀតចំពោះចលនវត្ថុជារថយន្តនេះ ទៅឱ្យតតិយជនណាមួយនោះមែនក៏រឹតធ្វើឱ្យលំបាកកាន់តែធ្ងន់ធ្ងរចំពោះអត្ថិភាពសិទ្ធិ នៃកម្មសិទ្ធិតាមផ្លូវច្បាប់របស់កូនក្តីនាងខ្ញុំ។

បច្ចុប្បន្នចលនវត្ថុ(រថយន្ត) ខាងលើនេះ ស្ថិតក្នុងស្ថានភាពដែលកូនបំណុល ឬតតិយជន អាចចាត់ចែងបានគ្រប់ពេលដែលនឹងនាំឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍ស្របច្បាប់របស់កូនក្តីនាងខ្ញុំ។ ប្រសិនបើពុំមានវិធានការរក្សាការពារ ដូចដែលកូនក្តីនាងខ្ញុំបានស្នើសុំក្នុងកម្មវត្ថុខាងលើទេ នោះនឹងធ្វើឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរនូវផលប្រយោជន៍ស្របច្បាប់របស់កូនក្តីនាងខ្ញុំ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមប្រធាន មេត្តាពិនិត្យ និងសម្រេចតាមការស្នើសុំរបស់កូនក្តីនាងខ្ញុំតាមនីតិវិធី និងច្បាប់ដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តមប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ៕

ថ្ងៃព្រហស្បតិ៍ ១២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២*

ស្នាមមេដៃស្តាំ

**បានឃើញនិង ឯកភាព**

ហត្ថលេខានិង ត្រា

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី [illegible]

**ឯកសារភ្ជាប់**

-លិខិតលក់រថយន្ត ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ (ថតចម្លង ១ច្បាប់)

-កិច្ចសន្យាប្រគល់ដី ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ (ថតចម្លង ១ច្បាប់)

-បណ្ណសម្គាល់យានយន្តរថយន្តម៉ាក TOYOTA LANCRUISER
ពាក់ស្លាកលេខ ភ្នំពេញ២K-៤២៤២ របស់ឈ្មោះ [illegible] (ថតចម្លង ១ច្បាប់)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [illegible] (ថតចម្លង ១ច្បាប់)

-រូបភាពនៃរថយន្ត (ថតចម្លង ១ច្បាប់)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ





# លិខិតលក់រថយន្ត

ខ្ញុំបាទឈ្មោះ........................................ ភេទ ប្រុស............ អាយុ 40 ......ឆ្នាំ

មុខងាររបស់ខ្ញុំ............[illegible]....................................................

អាសយដ្ឋាន [illegible]..................................................

អត្តសញ្ញាណប័ណ្ណលេខ.....010 855 9 54.......................................

បានលក់រថយន្ត.....1......គ្រឿង ម៉ាក [illegible]........ ពណ៌ [illegible]......... ដែលមាន

ឆ្នាំផលិត [illegible] 2008......... ចំនួន [illegible]

លេខតួ.........................................................

លេខម៉ាស៊ីន......................................................

ស្លាកសំគាល់.......2K 4242 ភ្នំពេញ...........................

លិខិតបត្រ..................................................

ទៅអោយឈ្មោះ........................................ ភេទ ប្រុស...... អាយុ 41 ឆ្នាំ

មុខងាររបស់ខ្ញុំ......[illegible]..................................................

អាសយដ្ឋាន [illegible]

.........................អត្តសញ្ញាណប័ណ្ណលេខ....010 91 6424............

តំលៃ......[illegible]......................................

កក់មុន......[illegible]......................................

នៅខ្វះ [illegible]......... សន្យាសងគ្រប់នៅថ្ងៃទី............ ខែ.......... ឆ្នាំ២០......

ថ្ងៃក្រោយបើមានជនណាមកអះអាងថារថយន្តខាងលើនេះជារបស់ខ្លួន

ខ្ញុំបាទ / នាងខ្ញុំឈ្មោះ..................................... សូមទទួលខុសត្រូវចំពោះមុខច្បាប់ ។

បញ្ជាក់ ធានាថាមានពន្ធត្រឹមត្រូវ របស់ទិញហើយមិនអាចប្តូរវិញបាន ។

ភ្នំពេញ ថ្ងៃទី 25 ខែ 10 ឆ្នាំ២០18

អ្នកលក់ សាក្សីអ្នកលក់ សាក្សីអ្នកទិញ អ្នកទិញ

- កិច្ចសន្យាប្រគល់ដី

- ខាងខ្ញុំឈ្មោះ ... អាយុ 43 ឆ្នាំ មានទីលំនៅ
ភូមិ [illegible] ឃុំ [illegible] ស្រុក [illegible] ខេត្ត [illegible]
[illegible] ចំនួន 20 ហិកតា [illegible]
[illegible] ឃុំ [illegible] ស្រុក [illegible]
[illegible] ឈ្មោះ
[illegible] អាយុ 40 ឆ្នាំ [illegible] ឆ្នាំ [illegible] 1.6.4 [illegible]
60 [illegible]
[illegible] ឈ្មោះ [illegible] អាយុ 33
ឆ្នាំ [illegible]
[illegible] ចំនួន 65000 [illegible]
[illegible]
[illegible]
[illegible] ឈ្មោះ [illegible]
[illegible] 1×2 [illegible]

- [illegible] ឈ្មោះ
[illegible]
ថ្ងៃទី 24 ខែ [illegible] 201[illegible]
[illegible]

[illegible]

[illegible]


2K-4242
LAND CRUISER

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមមេធាវី [redacted]

សាលាដំបូងរាជធានីភ្នំពេញ
ចូល
លេខ.....
ថ្ងៃទី.....ខែ.....ឆ្នាំ២០២២
ម៉ោង.....នាទី.....

## <u>សេចក្តីបញ្ជាក់ដំបូង</u>

នាងខ្ញុំមេធាវី [redacted] អត្តលេខ [redacted] ជាមេធាវីនៃ ក្រុមមេធាវី [redacted] ([redacted]) ដែលមានការិយាល័យផ្ទះលេខ៣៦E០ ផ្លូវលេខ៩៩ ក្រុម៦ ភូមិ៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] ក្នុងសំណុំរឿងរក្សាការពារលេខ២០៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**<u>សូមគោរពជូន</u>**
**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ ស្នើសុំជូននូវសេចក្តីបញ្ជាក់ដំបូង ក្នុងសំណុំរឿងរក្សាការពារលេខ២០៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ៖ ហាមឃាត់កូនបំណុលមិនឱ្យធ្វើការ **ផ្ទេរកម្មសិទ្ធិ លក់ ធ្វើអំណោយ ដាក់បញ្ចាំ ដាក់ប្រាតិភោគ ជួល ការដូរ ធ្វើអច្ច័យទាន និងស្នើសុំសិទ្ធិឃាត់ទុក** នូវរថយន្តម៉ាក TOYOTA LANCRUISER ពាក់ស្លាកលេខ ភ្នំពេញ២K-៤២៤២ ផលិតឆ្នាំ ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 ពណ៌ខ្មៅ ។

**យោង** ៖ -ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៥៤១
-សំណុំរឿងរក្សាការពារលេខ២០៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ

តបតាមកម្មវត្ថុ និងយោងខាងលើក្នុងនាមនាងខ្ញុំជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] សូមធ្វើសេចក្តីបញ្ជាក់ដំបូងជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបទំនាក់ទំនងគតិយុត្តដូចខាងក្រោម ៖

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ កូនក្តីនាងខ្ញុំ [redacted] និង កូនបំណុលឈ្មោះ [redacted] បានបង្កើតកិច្ចសន្យាលក់-ទិញ រថយន្តម៉ាក TOYOTA LANCRUISER ពាក់ស្លាកលេខ ភ្នំពេញ២K-៤២៤២ ផលិតឆ្នាំ ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 ពណ៌ខ្មៅ ដែលតម្លៃនៃការលក់ រថយន្តនេះជាថ្នូរ ទិញលក់ដីចំការទំហំ ១២ ហិកតា តម្លៃ ៦៥០០០$ ស្ថិតនៅភូមិអន្លង់ស្លែង ឃុំស្វាយចចិប ស្រុក បសេដ្ឋ ខេត្តកំពង់ស្ពឺ។ ប៉ុន្តែនៅពេលដល់កាលបរិច្ឆេទកំណត់ សហកូនបំណុលពុំបានអនុវត្តកាតព្វកិច្ចប្រគល់ដីមក ឱ្យ កូនក្តីរបស់នាងខ្ញុំនោះទេ ។ កូនក្តីរបស់នាងខ្ញុំតែងតែខិតខំជូនដំណឹងស្នើឱ្យសហកូនបំណុល អនុវត្តកាតព្វកិ របស់ពួកគេ ទើបនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ សហកូនបំណុល [redacted] និងប្តីឈ្មោះ [redacted] បានព្រមព្រៀ ប្រគល់ដីមួយកន្លែងផ្សេងទៀត មានទំហំចំនួន ២០ ហិកតា ដែលមានទីតាំងស្ថិតនៅភូមិស្រែជើងរ៉ះ ឃុំក្រញូវ ស្រុ ត្រាំងកក់ ខេត្តតាកែវ ជំនួសវិញ ។ ក្រោយពីចុះដល់ទីតាំងដីទំហំ ២០ ហិកតា តាមកិច្ចព្រមព្រៀងរបស់សហកូ បំណុល កូនក្តីនាងខ្ញុំបានរកឃើញថា ដីនោះជាដីសម្បទានរបស់ក្រុមហ៊ុន JUHEF LIMITED ពោលគឺមិនមែនដី

អាសយដ្ឋាន៖ ផ្ទះលេខ 36Eo ផ្លូវលេខ 99 សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
Address : 36Eo, St. 99, Boeung Trabek Commune, Chamkarmorn District, Phnom Penh. Mobile : 010 29 29 30 / 012 83 60 18 - Email: [redacted]-95@gmail.con

កម្មសិទ្ធិរបស់សហកូនបំណុលឡើយ ។ បន្ទាប់មកកូនក្តីនាងខ្ញុំ បានព្យាយាមជូនដំណឹងទៅសហកូនបំណុលដើម្បីមកដោះស្រាយពីបញ្ហាខាងលើ ប៉ុន្តែសហកូនបំណុលពុំមានឆន្ទៈក្នុងការក្នុងការចូលរួមដោះស្រាយ និងអនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើង គឺតែងតែ រកលេស គេចវេះ ពីកាតព្វកិច្ច ។

ដោយហេតុថា កូនបំណុលឈ្មោះ [illegible] បានចាត់ចែងលក់រថយន្តម៉ាក TOYOTA LANCRUISER ខាងលើនេះទៅឲ្យឈ្មោះ [illegible] ហើយឈ្មោះ [illegible] បានលក់បន្តទៅឈ្មោះ [illegible] ។

ដូច្នេះការចាត់ចែងរក្សាការពារដោយធ្វើការហាមឃាត់សហកូនបំណុលមិនឱ្យធ្វើការ ផ្ទេរកម្មសិទ្ធិ លក់ ធ្វើអំណោយ ដាក់បញ្ចាំ ដាក់ប្រាតិភោគ ជួល ការដូរ ការធ្វើអច្ច័យទាន និងស្នើសុំសិទ្ធិឃាត់ទុក វាពិតជាមានភាពចាំបាច់ណាស់ ដោយមានការបារម្ភថា កូនក្តីនាងខ្ញុំដែលជាម្ចាស់បំណុល នឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ដោយការចាត់ចែងក្នុងរូបភាពផ្សេងៗ របស់សហកូនបំណុល និងតតិយជន ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យលទ្ធភាពសម្រេចទទួល ការស្នើសុំតបតាមកម្មវត្ថុនៃសេចក្តីបញ្ជាក់ដំបូងនេះដោយក្តីអនុគ្រោះបំផុត ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ **មេធាវី** [illegible] ៕

ថ្ងៃអង្គារ ១០ ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២

**ហត្ថលេខា និងត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF

**មេធាវី** [illegible]

គំរូលេខ 09 សហវ/ចមព

260-1- 00197409

MEF20882604121

ក្រសួងយុត្តិធម៌

អង្គភាព........................................

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

ទទួលពី ........................ ........................................ អង្គភាព........................................................................

ចំនួនទឹកប្រាក់ជាលេខ ..........................................................................................................

ជាអក្សរ ..........................................................................................................

អត្ថន័យចំណូល.......................................................................... មាតិកាថវិកា ........................

.........ថ្ងៃទី.........ខែ.........ឆ្នាំ..........

អ្នកប្រមូលចំណូល

អេង សេចណ្ណារី

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨

សាលាដំបូង ខេត្តកណ្ដាល
សំណុំរឿងលេខ ... ការ
លេខ: 113
ថ្ងៃទី 08 ខែ 05 ឆ្នាំ២០19

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

# **ពាក្យបណ្ដឹងសុំដីកាសម្រេចរក្សាការពារ**

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តកណ្ដាល**

**ម្ចាស់បំណុល:** ឈ្មោះ ភេទប្រុស អាយុ ឆ្នាំជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**កូនបំណុល:** ឈ្មោះ ភេទ ស្រីកើតឆ្នាំ១៩៦៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរអាសយដ្ឋាន ភូមិ ឃុំ ស្រុក ខេត្តកណ្ដាល។

**កម្មវត្ថុនៃការទាមទារ:** ស្នើសុំអោយលោកប្រធានមេត្តាសំរេច:

១-ចេញដីការក្សាការពារហាមឃាត់កូនបំណុល ឈ្មោះ មិនអោយធ្វើការលក់ ដូរ ជួល ដាក់បញ្ចាំ ផ្ទេរសិទ្ធិ ធ្វើអំណោយ ធ្វើអច្ច័យទាន ធ្វើមរតកទៅអោយ ទាយាទ សាងសង់សំណង់គ្រប់ប្រភេទ និងដាំដំណាំគ្រប់ប្រភេទលើដីទំហំ១៤២១ម៉ែត្រការ៉េ ដែលក្បាលដីមានលេខ៣១០ ដែលមានព្រំខាងជើងជាប់និងក្បាលដីលេខ៣១៤ ខាងត្បូងជាប់និង ក្បាលដីលេខ៣០៥ ខាងលិចនិង ក្បាលដីលេខ៣០៩ ខាងកើតជាប់និងក្បាលដីលេខ៣០៤ ដែលមានទីតាំងស្ថិតនៅ ភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ជាបណ្ដោះអាសន្ន។

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

**មូលហេតុចាំបាច់នៃការទាមទារ:** ខ្ញុំបាទបានទិញដីទំហំ១៤២១ម៉ែត្រការ៉េដែល មានទីតាំងស្ថិតនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលក្បាលដីមានលេខ៣១០ ដែលមានព្រំខាងជើង ជាប់និងក្បាលដីលេខ៣១៤ ខាងត្បូងជាប់និង ក្បាលដីលេខ៣០៥ ខាងលិចនិង ក្បាលដីលេខ៣០៩ ខាងកើតជាប់និងក្បាលដីលេខ៣០៤ ដីនេះកូនបំណុលបានលក់ដីនេះអោយខ្ញុំដោយកូនបំណុលបានទទួលប្រាក់កក់ទ្រនាប់ដៃពីខ្ញុំចំនួន២ពាន់ដុល្លាអាមេរិក ហើយកូនបំណុលត្រូវធ្វើការផ្ទេរសិទ្ធិនិងផ្ដិតមេដៃលើអក្សរព្រមទាំងប្រគល់ឯកសារកាន់កាប់ច្បាប់ដើមអោយមកខ្ញុំ ប៉ុន្តែក្រោយពេលខ្ញុំបាទប្រគល់ប្រាក់កក់២ពាន់ដុល្លាអាមេរិករួចហើយ កូនបំណុលបែជាមកទាមទារអោយខ្ញុំបាទអោយដីគាត់ឡើងថ្លៃជាងនៅក្នុងកិច្ចសន្យាទើបគាត់ព្រម ក្រោយពីការចរចាភ្លាមិនបានហើយខ្ញុំបានយកប្រាក់ទៅប្រគល់អោយកូនបំណុល ក៏កូនបំណុលមិន

ព្រមហើយកូនបំណុលថាឈប់លក់ដីនេះអោយខ្ញុំទៀតហើយ បើខ្ញុំមិនអោយតំលៃលើសពីការកំណត់ក្នុងកិច្ចសន្យាទ្រនាប់ដៃកក់ប្រាក់ទិញលក់ដីចុះថ្ងៃទី២៩ខែមេសាឆ្នាំ២១០៨ដោយកាលនោះកូនបំណុលលក់អោយខ្ញុំតំលៃ១ម៉ែត្រការ៉េ១៥ដុល្លាអាមេរិកដោយមិនមានធ្វើការដោះស្រាយគ្នាជាមួយកូនបំណុលតទៅទៀតបាន និងបារម្ភ ថាកូនបំណុលយកដីនេះទៅលក់បន្តទៀតទើបខ្ញុំបាទស្នើសុំអោយលោកប្រធានចេញដីការសម្រេចរក្សាការពារដីនេះជាបណ្តោះអាសន្នសិនរង់ចាំការសម្រេចដល់រឿងអង្គសេចក្តី ។

អាស្រ័យហេតុនេះសូមលោកប្រធាន ចេញដីកាសម្រេចរក្សាការពារហាមឃាត់កូនបំណុល ឈ្មោះ មិនអោយធ្វើការលក់ ដូរ ជួល ដាក់ បញ្ចាំ ផ្ទេរសិទ្ធិ ធ្វើអំណោយ ធ្វើអច្ច័យទាន ធ្វើមរតកទៅអោយទាយាទ សាងសង់សំណង់គ្រប់ប្រភេទ និងដាំដំណាំគ្រប់ប្រភេទលើដីទំហំ១៤២១ម៉ែត្រ ការ៉េ ដែលក្បាលដីមានលេខ៣១០ ដែលមានព្រំខាងជើង ជាប់និងក្បាលដីលេខ៣១៤ ខាងត្បូងជាប់និងក្បាលដីលេខ៣០៥ ខាងលិចនិងក្បាលដីលេខ៣០៩ ខាងកើត ជាប់និងក្បាលដីលេខ៣០៤ ដែលមានទីតាំង ស្ថិតនៅភូមិព្រៃកស្លែង ឃុំព្រៃកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ជាបណ្តោះអាសន្ន ដោយក្តីអានុគ្រោះ ។

សូមលោកប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ ឧសភាឆ្នាំ ២០១៩



# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យាទ្រនាប់ដៃ កក់ប្រាក់ទិញលក់ដី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.[illegible].....ភេទ...ស្រី...កើតឆ្នាំ.1967 សញ្ជាតិខ្មែរ ជនជាតិខ្មែរ ប្តី/ប្រពន្ធឈ្មោះ........................ ......មានទីលំនៅបច្ចុប្បន្នផ្ទះលេខ..........ផ្លូវ..........ភូមិ.[illegible] ឃុំ/សង្កាត់.[illegible].......ស្រុក/ខណ្ឌ.[illegible].....ខេត្ត/រាជធានី..[illegible]..................។ កាន់អត្តសញ្ញាណប័ណ្ណលេខ.020061353.ចុះថ្ងៃទី.07.ខែ.01...ឆ្នាំ.2015....។(ភាគីអ្នកលក់) បានទទួលប្រាក់ទ្រនាប់ដៃចំនួន..2000——$ (....ពីរពាន់.........................ដុល្លាអាមេរិក) ដោយ [illegible] ..........ដីក្រុង....................កន្លែងដោយមិនកែប្រែ ។ ដែលមានទីតាំងដីស្ថិតនៅក្នុង ភូមិ.ព្រែក.ស្លែង.ព្រែក.ស្លែង......... ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ទំហំ....1421..........ម៉ែ [illegible]ដីលេខ..310...............ក្នុងតំលៃ១ម៉ែ..15.....$(.ដប់.ប្រាំ....ដុល្លាអាមេរិកក្នុងមួយម៉ែត្រក្រឡា) ទូរស័ព្ទលេខ..................................។

**ដែលមានព្រំប្រទល់៖**

ខាងជើងទល់នឹង...314................ខាងត្បូងទល់នឹង..306.................

ខាងកើតទល់នឹង....304..............ខាងលិចទល់នឹង..309.................

ជូនទៅឈ្មោះ [illegible] ភេទ ប្រុស កើតឆ្នាំ ១៩៧៦ សញ្ជាតិ ខ្មែរ ជនជាតិ ខ្មែរ មានទីលំនៅបច្ចុប្បន្ន [illegible]លេខ ៦៣ ផ្លូវ បេតុង ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ កាន់អត្តសញ្ញាណប័ណ្ណលេខ១០៨៨២៨៨៥ ចុះថ្ងៃទី១០ ខែមេសាឆ្នាំ.២០១៥ ។(ភាគីអ្នកទិញ)

## ភាគីទាំងពីរបានសន្យាគ្នាដូចខាងក្រោម៖

-រយៈពេល.១០០...ថ្ងៃ ក្រោយថ្ងៃប្រគល់ប្រាក់ទ្រនាប់ដៃ ហើយភាគីអ្នកលក់ក៏បានផ្ទេរសិទ្ធិជូនភាគីអ្នកទិញដោយបានផ្តិតមេដៃលើអក្សរ ព្រមទាំងប្រគល់ឯកសារកាន់កាប់ដីច្បាប់ដើម ជាមួយមន្ត្រីស្ទីឃោលដី [illegible]ពល់ នោះភាគីអ្នកទិញនឹងបន្ថែមប្រាក់បង្គ្រប់១០០%ជូនភាគីអ្នកលក់ ដើម្បីជាកិច្ចបញ្ចប់នៃកិច្ចសន្យាទិញ [illegible]ក់ដីនេះ។តែបើភាគីទិញពុំព្រមយកប្រាក់មកបង្គ្រប់តាមកាលកំណត់ នោះប្រាក់ទ្រនាប់ដៃខាងលើត្រូវបាន [illegible]ប្រយោជន៍ ទៅភាគីអ្នកលក់ តែបើដល់ថ្ងៃកំណត់បែរជាភាគីអ្នកលក់កែប្រែពុំលក់ដីខាងលើនេះវិញ នោះ [illegible]គីអ្នកលក់ ត្រូវសងប្រាក់គុណានឹងពីរដងនៃតំលៃដីសរុបមកភាគីអ្នកទិញវិញ។

[illegible]ពុំប្រាកដយើងខ្ញុំទាំងអស់គ្នាសូមផ្តិតមេដៃស្តាំទុកជាភស្តុតាងនិងសូមទទួលខុសត្រូវចំពោះមុខច្បាប់ ។

ថ្ងៃទី 24 ខែ 04 ឆ្នាំ២០១៨

**ស្នាមមេដៃអ្នកទិញ** **ស្នាមមេដៃសាក្សី** **ស្នាមមេដៃអ្នកលក់**





........................................................

សាលាដំបូងខេត្តកណ្ដាល
បាន លេខ: 873
ថ្ងៃទី 11 ខែ 05 ឆ្នាំ 20 22
ម៉ោង 3 និង 30 នាទី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>លិខិតតំណាងដោយអាណត្តិ</u>**

នាងខ្ញុំមេធាវី សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ៨៣១ ការិយាល័យ ផ្ទះលេខ ២០៥ ផ្លូវលេខ៣៥៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។ ទូរសព្ទ័លេខ:

**<u>សូមគោរពជូន</u>**
**លោកចៅក្រមទទួលបន្ទុករឿងក្ដីសាលាដំបូងខេត្តកណ្ដាល**

**<u>កម្មវត្ថុ</u>:**ស្ដីពីមេធាវីតំណាងដោយអាណត្តិ នៅក្នុងសំណុំរឿងរក្សាការពារលេខ១១៣រកពចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០១៩របស់សាលាដំបូងខេត្តកណ្ដាល។
យោង ៖-ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី
-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់អាណត្តិទាយក ឈ្មោះ ចុះថ្ងៃទី០៣ខែឧសភាឆ្នាំ២០២២។

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមជំរាបជូនលោកចៅក្រមមេត្តាជ្រាបថា: អាណត្តិទាយកឈ្មោះ បានប្រគល់សិទ្ធិអោយនាងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរក្សាការពារលេខ១១៣រកពចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០១៩របស់សាលាដំបូងខេត្តកណ្ដាល។

អាស្រ័យហេតុនេះសូមលោកចៅក្រមមេត្តាជ្រាប និងទទួលស្គាល់តាមនីតិវិធីច្បាប់។

សូមលោកចៅក្រមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៤ខែឧសភាឆ្នាំ២០២២

មេធាវី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*********

## <u>លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ</u>

ខ្ញុំអាណត្តិទាយកឈ្មោះ ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

## <u>សូមប្រគល់សិទ្ធិជូន</u>

លោកស្រីមេធាវី ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ការិយាល័យផ្ទះលេខ ២០៥ ផ្លូវលេខ៣៥៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌ បឹងកេងកង រាជធានីភ្នំពេញ ឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិរបស់យើងខ្ញុំដើម្បីការពារក្តីនៅ សាលាដំបូងខេត្តកណ្តាល នៅក្នុងសំណុំរឿងរក្សាការពារលេខ ១១៣ រកព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តកណ្តាល តាមនីតិវិធីច្បាប់ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ។

បញ្ជាក់ៈសោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗនៅក្នុងបណ្តឹងនេះ ជាបន្ទុករបស់ខ្ញុំជាអាណត្តិទាយក។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ ខ្ញុំសុខចិត្តទទួលខុសត្រូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់។

ធ្វើនៅថ្ងៃទី [illegible]...ខែ..[illegible]ឆ្នាំ២០២២

**អាណត្តិទាយក**

បានឃើញ និង យល់ព្រម
ធ្វើជាមេធាវីតំណាងដោយអាណត្តិអោយ
អាណត្តិទាយកឈ្មោះ
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible]...ខែ..[illegible]ឆ្នាំ២០២២

**មេធាវី**

មេធាវី

(1)

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ

ខ្ញុំ P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអាគារ ..... ជាន់ទី.... បន្ទប់ ......... ផ្លូវលេខ............ សង្កាត់........ ខណ្ឌ......... រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ ..............។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**ក.ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ**

១.រឹបអូសជាបណ្ដោះអាសន្ននូវសិទ្ធិលើបំណុលដែលជាប្រាក់នៅក្នុងគណនីធនាគាររបស់កូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុ

២.កូនបំណុលត្រូវផ្ញើប្រាក់រំដោះចំនួន 130,000 USD (មួយសែនបីម៉ឺន) ដុល្លារអាមេរិក ដើម្បីទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

៣.ហាមឃាត់កូនបំណុលទី៣មិនឲ្យបើកប្រាក់ក្នុងគណនីធនាគាររបស់កូនបំណុលឲ្យទៅកូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុ

៤.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

**ខ.សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ**

កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១៥ ឈ្មោះ Y (កូនបំណុល) បានមកខ្ចីប្រាក់ពីឈ្មោះ X (ម្ចាស់បំណុល) ដែលមានខ្លឹមសារថា ប្រាក់ដើមចំនួន 100,000 USD (មួយសែន) ដុល្លារអាមេរិក ការប្រាក់ 10%ក្នុងមួយឆ្នាំ ដោយមានហត្ថលេខារបស់កូនបំណុល បានព្រមព្រៀងការប្រាក់យឺតយ៉ាវ 20%ក្នុងមួយឆ្នាំ និងកំណត់ពេលសងគឺថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦។

ទោះបីជាម្ចាស់បំណុលបានដាស់តឿនជាច្រើនលើកច្រើនសារក៏ដោយ ក៏កូនបំណុលមិនបានសងប្រាក់នោះទេ។

ទោះបីកាលកំណត់សងបានមកដល់ក៏ដោយ ក៏កូនបំណុលនៅតែមិនសងប្រាក់ដើម និងការប្រាក់ (ការប្រាក់ធម្មតា និងការប្រាក់យឺតយ៉ាវ) ហេតុនេះសិទ្ធិលើបំណុលសរុបរបស់ម្ចាស់បំណុល គិតមកដល់ថ្ងៃដាក់ពាក្យសុំនេះ គឺ130,000USD(មួយសែនបីម៉ឺន)ដុល្លារអាមេរិក។



24.08.2019

## គ.ភាពចាំបាច់នៃការរក្សាការពារ

កូនបំណុលបានអះអាងថានៅថ្ងៃទី០១ ខែមិនា ឆ្នាំ២០១៧ បានសងប្រាក់ចំនួន 100,000 USD ទៅឲ្យម្ចាស់បំណុលរួចរាល់ ហើយម្ចាស់បំណុលបានបង្ហាញឆន្ទៈលើកលែងបំណុលចំពោះការប្រាក់ដែលនៅសល់ឲ្យកូនបំណុលទៅវិញ។

ម្ចាស់បំណុលស្គាល់តែគណនីធនាគារចំនួន០៣របស់កូនបំណុលប៉ុណ្ណោះ ក្រៅពីនេះមិនដឹងថាកូនបំណុលមានទ្រព្យដែលមានតម្លៃផ្សេងទៀតនៅឯណានោះទេ បើមិនចាត់វិធានការបន្ទាន់ជាបណ្តោះអាសន្ននោះទេ កូនបំណុលអាចដកប្រាក់ចេញពីគណនីធនាគារចេញអស់ ដែលអាចនាំឲ្យកូនបំណុលក្លាយជាគ្មានទ្រព្យសម្បត្តិសម្រាប់ទទួលខុសត្រូវទៅលើសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល នាំឲ្យម្ចាស់បំណុលមានការបារម្ភថា អាចនឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ ឬមិនអាចអនុវត្តដោយបង្ខំបាន (ទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលត្រូវបានបាត់បង់) ហេតុនេះ មានភាពចាំបាច់ក្នុងការរឹបអូសជាបណ្តោះអាសន្ននូវសិទ្ធិលើបំណុលជាប្រាក់ក្នុងគណនីធនាគារទាំងបីកន្លែងរបស់កូនបំណុលដើម្បីធានាសិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឲ្យសងប្រាក់។

## ឃ.សេចក្តីបញ្ជាក់ដំបូង

១.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥។ (ភស្តុតាង $X_1$)

២.លិខិតប្រគល់ទទួលប្រាក់ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥។ (ភស្តុតាង $X_2$)

៣.សៀវភៅគណនីធនាគាររបស់ Y ។ (ភស្តុតាង $X_3$)

៤.លិខិតដាស់តឿនរបស់ X ។ (ភស្តុតាង $X_4$)

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

<u>ឯកសារភ្ជាប់</u>

១.លិខិតតំណាងដោយអាណត្តិ "ច្បាប់ដើម"

២.លិខិតថតចម្លងនៃសេចក្តីបញ្ជាក់ដំបូងនីមួយៗ ចំនួន ០២ (ពីរ) ច្បាប់

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧

**អ្នកតំណាងដោយអាណត្តិ**

## បញ្ជីភាគី

**ម្ចាស់បំណុល ៖**

ឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល ៖**

មេធាវី P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអាគារ ..... ជាន់ទី.... បន្ទប់ ......... ផ្លូវលេខ............ សង្កាត់........ ខណ្ឌ......... រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ ...................................។

ទីកន្លែងបញ្ជូន ៖ ការិយាល័យមេធាវី ...........។

**កូនបំណុល ៖**

ឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

## បញ្ជីសិទ្ធិលើបំណុល

១.ប្រាក់ដើមចំនួន ៖ **100,000 USD**

សិទ្ធិលើបំណុលដែលទាមទារឲ្យសងគឺប្រាក់ដើមចំនួន 100,000 USD (មួយសែន) ដុល្លារអាមេរិកដែល Y បានខ្ចីពី X ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥។

២.ការប្រាក់ ៖ **10%**ក្នុងមួយឆ្នាំ

នៅពេលចុះកិច្ចសន្យាខ្ចីប្រាក់ Y និង X បានព្រមព្រៀងអំពីអត្រាការប្រាក់ ដែលមានចំនួន10%ក្នុងមួយឆ្នាំ ធៀបនឹងប្រាក់ដើម (100,000 USD) ហើយការព្រមព្រៀងនេះបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខារបស់ Y ផងដែរ ហេតុនេះសិទ្ធិលើបំណុលជាការប្រាក់មានចំនួន 10,000 USD (មួយម៉ឺន) ដុល្លារអាមេរិក។

៣.ការប្រាក់យឺតយ៉ាវ ៖ **20%**ក្នុងមួយឆ្នាំ

នៅពេលចុះកិច្ចសន្យាខ្ចីប្រាក់ Y និង X បានព្រមព្រៀងអំពីអត្រាការប្រាក់យឺតយ៉ាវ ដែលមានចំនួន20%ក្នុងមួយឆ្នាំ ធៀបនឹងប្រាក់ដើម (100,000 USD) ដោយបានកំណត់សងនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ប៉ុន្តែ Y មិនបានសងប្រាក់ ហេតុនេះសិទ្ធិលើបំណុលជាការប្រាក់យឺតយ៉ាវមានចំនួន 20,000 USD (ពីរម៉ឺន) ដុល្លារអាមេរិក (គិតចាប់ពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ដល់ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧)។

៤.កំណត់ពេលសង ៖ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦

នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៥ បានកំណត់ពេលសងនៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៦។

## បញ្ជីសារពើភណ្ឌនៃវត្ថុ

### គណនីធនាគារ ABA (ADVANCED BANK OF ASIA LIMITED)

១.ទីតាំងធនាគារ ៖ អគារលេខ១៤៨ មហាវិថីនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

២.លេខគណនីធនាគារ ៖ 0000000000

៣.ម្ចាស់គណនីធនាគារ ៖ Y

៤.ប្រភេទរូបិយវត្ថុ ៖ ដុល្លារអាមេរិក (USD)

### គណនីធនាគារ ACELEDA BANK PLC

១.ទីតាំងធនាគារ ៖ អាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

២.លេខគណនីធនាគារ ៖ 000000000

៣.ម្ចាស់គណនីធនាគារ ៖ Y

៤.ប្រភេទរូបិយវត្ថុ ៖ ដុល្លារអាមេរិក (USD)

### គណនីធនាគារ SHINHAN

១.ទីតាំងធនាគារ ៖ អាគារលេខ៧៩ (អាគារវ៉ាន់ដាថោវើ) មហាវិថីកម្ពុជាក្រោម សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

២.លេខគណនីធនាគារ ៖ 000000000

៣.ម្ចាស់គណនីធនាគារ ៖ Y

៤.ប្រភេទរូបិយវត្ថុ ៖ ដុល្លារអាមេរិក (USD)

# ឧបសម្ព័ន្ធទី៣
# ពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ចូល ថ្ងៃទី 28 ខែ 07 ឆ្នាំ 2022

**ម្ចាស់បំណុល:**

ឈ្មោះ ភេទប្រុស អាយុ៤៣ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦៤E₀ ភូមិក្រាំងអង្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ លេខទូរស័ព្ទទំនាក់ទំនង០១៦ ៣០៤ ៤៤៤។

លេខ 001 99734 ចុះថ្ងៃទី 28 ខែ 07 ឆ្នាំ 2022

**សហកូនបំណុល:**

១.ឈ្មោះ ភេទស្រី កើតនៅឆ្នាំ១៩៦៩ និងប្ដីឈ្មោះ សញ្ជាតិខ្មែរទីលំនៅបច្ចុប្បន្នផ្ទះលេខ១០៨ ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

២.ឈ្មោះ ភេទប្រុស កើតនៅឆ្នាំ១៩៦៥ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៣.ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិពងទឹក ឃុំរការប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

**<u>សូមគោរពជូន</u>**
**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ:** ស្នើសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដោយផ្អែកលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ៣២៨ "រ" ដ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង:**-មាត្រា ៣៤៩, ៣៥០, ៥៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា

-សំណុំរឿងរក្សាការពារលេខ២០៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របសសាលាដំបូងរាជធានីភ្នំពេញ។

-ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ៣២៨ "រ" ដ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ (ថតចម្លង០១ ច្បាប់) ។

-បណ្ណសម្គាល់យានយន្តរថយន្តម៉ាក TOYOTA LANCRUISER ពាក់ស្លាកលេខ **ភ្នំពេញ២K-៤២៤២** របស់ឈ្មោះ (ថតចម្លង០១ ច្បាប់) ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ៣២៨ "រ" ដ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ គឺជាលិខិតអនុវត្ត ដែលមានភាគីម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ភេទប្រុស អាយុ៤៣ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦៤E₀ ភូមិក្រាំងអង្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ អាចស្នើសុំឱ្យអនុវត្តដោយបង្ខំតាមនីតិវិធី។

អាស្រ័យហេតុនេះ ខ្ញុំបាទស្នើសុំឱ្យតុលាការអនុវត្តឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននូវលិខិតអនុវត្ត ដូចបានចែងក្នុងកម្មវត្ថុខាងលើ តាមខ្លឹមសារខាងក្រោមៈ

**១-សហាគូនបំណុល**

១.ឈ្មោះ ភេទស្រី កើតនៅឆ្នាំ១៩៦៩ និងប្ដីឈ្មោះ សញ្ជាតិខ្មែរទីលំនៅបច្ចុប្បន្នផ្ទះលេខ១០៨ ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

២.ឈ្មោះ ភេទប្រុស កើតនៅឆ្នាំ១៩៦៥ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៣.ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិពងទឹក ឃុំរការប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

**២-លិខិតអនុវត្ត**

-ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ៣២៨ "រ" ដ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បណ្ណសម្គាល់យានយន្តរថយន្តម៉ាក TOYOTA LANCRUISER ពាក់ស្លាកលេខ **ភ្នំពេញ២K-៤២៤២** របស់ឈ្មោះ

**៣-សេចក្ដីស្នើសុំឱ្យអនុវត្ត**

ម្ចាស់បំណុលនៃការអនុវត្ត ស្នើសុំឱ្យអនុវត្តដោយបង្ខំតាមការបង្ខំដោយផ្ទាល់លើកូនបំណុលនៃការអនុវត្ត។

**៤-សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុ នៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន**

រថយន្តម៉ាក TOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ២K-៤២៤២ ផលិតឆ្នាំ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074។

**៥-វិធីនៃការអនុវត្តដោយបង្ខំ**

ម្ចាស់បំណុលនៃការអនុវត្តបានស្នើសុំឱ្យ តុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន នូវរថយន្តម៉ាក TOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ២K-៤២៤២ ផលិតឆ្នាំ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 មានឃាត់សហកូនបំណុលធ្វើការ ផ្ទេរកម្មសិទ្ធិ លក់ ដូរ ជួល ដាក់បញ្ចាំ ដាក់ប្រាតិភោគ ធ្វើអំណោយ ធ្វើអច្ច័យទាន និងស្នើសុំសិទ្ធិឃាត់ទុក ដោយហេតុថាការស្នើសុំនេះមានលក្ខខណ្ឌត្រឹមត្រូវតាមផ្លូវច្បាប់ តុលាការក៏បានសម្រេចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ៣២៨ "រ" ដ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ មានខ្លឹមសារសម្រេចឱ្យ រឹបអូសជាបណ្ដោះអាសន្ន នូវចលនវត្ថុដែលជារថយន្តម៉ាក ម៉ាក TOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ២K-៤២៤២ ផលិតឆ្នាំ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 មានឃាត់សហកូនបំណុលធ្វើការ ផ្ទេរកម្មសិទ្ធិ លក់ ដូរ ជួល ដាក់បញ្ចាំ ដាក់ប្រាតិភោគ ធ្វើអំណោយ ធ្វើអច្ច័យទាន និងផ្ដល់សិទ្ធិឃាត់ទុកជាបណ្ដោះអាសន្ន និងប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហកូនបំណុល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

ថ្ងៃអង្គារ ១៣រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០២២
**ស្នាមមេដៃស្តាំ**

បានឃើញ និងឯកភាព
**ហត្ថលេខា និងត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**មេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

# ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

លេខ: ...៣២៨....."រ" ដ.រ

**យើង លិ សុខា ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញ មាត្រា ៥៤១ និងមាត្រា ៥៤៥ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី។

បានឃើញ សំណុំរឿងរក្សាការពារលេខ ២០៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ដែលមាន៖

***ម្ចាស់បំណុល៖*** ឈ្មោះ ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះលេខ ភូមិក្រាំងអង្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

***អ្នកតំណាងដោយអាណត្តិ៖*** លោកស្រីមេធាវី អត្តលេខ មានការិយាល័យផ្ទះលេខ ផ្លូវលេខ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងលោកស្រីមេធាវី អត្តលេខ មានការិយាល័យផ្ទះលេខ ផ្លូវលេខ ក្រុមទី៦ ភូមិ៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

***សហកូនបំណុល៖***

១.ឈ្មោះ កើតនៅឆ្នាំ១៩៦៨ និងប្ដីឈ្មោះ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែន រាជធានីភ្នំពេញ ។

២.ឈ្មោះ ភេទប្រុស កើតនៅឆ្នាំ១៩៦៥ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៣.ឈ្មោះ ភេទប្រុស អាយុ៣៤ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិពងទឹក ឃុំការប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

***ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ៖***

សុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន នូវរថយន្តម៉ាក TOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2K-4242 ផលិតឆ្នាំ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084 009074 ហាមឃាត់កូនបំណុលធ្វើការ **ផ្ទេរកម្មសិទ្ធិ លក់ ដូរ ជួល ដាក់បញ្ចាំ ដាក់ប្រាតិភោគ ធ្វើអំណោយ ធ្វើអច្ច័យទាន និងស្នើសុំសិទ្ធិឃាត់ទុក**។

## សំអាងហេតុ

១.តាមពាក្យសុំដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ បានសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខរថយន្តម៉ាក TOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2K-4242 ផលិតឆ្នាំ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 ហាមឃាត់កូនបំណុលធ្វើការ

**ផ្ទេរកម្មសិទ្ធិ លក់ដូរ ជួល ដាក់បញ្ចាំ ដាក់ប្រាតិភោគ ធ្វើអំណោយ ធ្វើអច្ច័យទាន និងស្នើសុំសិទ្ធិឃាត់ទុក** មានលក្ខណៈសមស្របតាមមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូច្នេះតុលាការគប្បីយកពាក្យសុំនេះមកធ្វើការពិចារណា និងសម្រេច។

២.តាមសេចក្តីបញ្ជាក់ដំបូង ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២ របស់លោកស្រីមេធាវី បានបញ្ជាក់ថា៖ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ កូនក្តីខ្លួនឈ្មោះ និងកូនបំណុលឈ្មោះ បានបង្កើតកិច្ចសន្យាលក់ទិញរថយន្តម៉ាក TOYOTA LANDCRUISER ពាក់ផ្លាកលេខភ្នំពេញ 2K-4242 ផលិតឆ្នាំ២០០៨ ពណ៌ខ្មៅ ដែលតម្លៃនៃការលក់រថយន្តនេះ គឺជាថ្នូរទិញលក់ដីចំការមួយកន្លែងទំហំ ១២ ហិកតា តម្លៃ ៦៥០០០ (ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក ស្ថិតនៅភូមិអន្លង់ស្វែង ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ ប៉ុន្តែនៅពេលដល់កាលបរិច្ឆេទកំណត់ សហកូនបំណុលពុំបានអនុវត្តកាតព្វកិច្ចប្រគល់ដីមកឱ្យកូនក្តីខ្លួននោះទេ។ កូនក្តីរបស់ខ្លួនតែងតែខិតខំជូនដំណឹងស្នើឱ្យសហកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ពួកគេ ទើបនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ សហកូនបំណុលឈ្មោះ និងប្តីឈ្មោះ បានព្រមព្រៀងប្រគល់ដីមួយកន្លែងផ្សេងទៀតមានទំហំចំនួន២០ហិកតា ដែលមានទីតាំងស្ថិតនៅភូមិស្រែជើងរះ ឃុំក្រញូវ ស្រុកត្រាំកក់ ខេត្តតាកែវ ជំនួសវិញ។ ក្រោយពីចុះដល់ទីតាំងដីទំហំ ២០ ហិកតា តាមកិច្ចព្រមព្រៀងរបស់សហកូនបំណុល កូនក្តីរបស់ខ្លួនបានរកឃើញថា ដីនោះជាដីសម្បទានរបស់ក្រុមហ៊ុន JUHEF LIMITED ពោលគឺមិនមែនជាដីដែលជាកម្មសិទ្ធិរបស់សហកូនបំណុលឡើយ។ បន្ទាប់មកកូនក្តីរបស់ខ្លួនបានព្យាយាមជូនដំណឹងទៅសហកូនបំណុលដើម្បីមកដោះស្រាយពីបញ្ហានេះ ប៉ុន្តែសហកូនបំណុលពុំមានឆន្ទៈក្នុងការចូលរួមដោះស្រាយ និងអនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើយ គឺតែងតែរកលេស គេចវេះ មិនចេះចប់ មិនចេះហើយ។ ដោយហេតុថា កូនបំណុលឈ្មោះ បានចាត់ចែងលក់រថយន្តម៉ាក TOYOTA LANCRUISER ខាងលើទៅឱ្យកូនបំណុលម្នាក់ទៀតឈ្មោះ ហើយឈ្មោះ បានលក់បន្តទៅឱ្យឈ្មោះ ។ ដូច្នេះការចេញដីកាសម្រេចរក្សាការពារដោយធ្វើការហាមឃាត់សហកូនបំណុលធ្វើការ **ផ្ទេរកម្មសិទ្ធិ លក់ ដូរ ជួល ដាក់បញ្ចាំ ដាក់ប្រាតិភោគ ធ្វើអំណោយ ធ្វើអច្ច័យទាន និងស្នើសុំសិទ្ធិឃាត់ទុក** វាពិតជាមានភាពចាំបាច់ណាស់ ម្យ៉ាងទៀតកូនក្តីរបស់ខ្លួនមានការបារម្ភលើសហកូនបំណុលយកចលនវត្ថុ (រថយន្ត) នោះយកទៅលក់ ឬ ប្រគល់ឱ្យតតិយជនផ្សេង។ ដោយមានការបារម្ភបែបនេះហើយ កូនក្តីខ្លួនដែលជាម្ចាស់បំណុល នឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ដោយការចាត់ចែងក្នុងរូបភាពផ្សេងៗរបស់សហកូនបំណុល។

៣.តាមការពិនិត្យលើបណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៨ឃើញថា រថយន្តម៉ាក TOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2K-4242 ផលិតឆ្នាំ២០០៨ ពិតជាកម្មសិទ្ធិរបស់ម្ចាស់បំណុលឈ្មោះ ប្រាកដមែន។

៤.តាមការពិនិត្យលើភស្តុតាងរបស់ម្ចាស់បំណុលដាក់ជូនតុលាការរួមមាន៖ លិខិតលក់រថយន្ត ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ និងកិច្ចសន្យាប្រគល់ដី ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ដែលម្ចាស់បំណុលបានធ្វើជាមួយកូនបំណុលឃើញថា ម្ចាស់បំណុលពិតជាបានយករថយន្តរបស់ខ្លួនទៅដូរជាមួយនឹងដីទំហំ ២០ ហិកតា ដែលស្ថិតនៅភូមិស្រែជើងរះ ឃុំត្រពាំងក្រញូវ ស្រុកត្រាំកក់ ខេត្តតាកែវ ប្រាកដមែន។

៥.តាមលិខិតលក់រថយន្ត ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ឃើញថា ម្ចាស់បំណុលឈ្មោះ បានលក់រថយន្តរបស់ខ្លួនម៉ាក TOYOTA LANDCRUISER ពាក់ផ្លាកលេខភ្នំពេញ 2K-4242 ផលិតឆ្នាំ២០០៨ ពណ៌ខ្មៅ ក្នុងតម្លៃជាថ្នូនឹងដីចំការមួយកន្លែងទំហំ ១២ ហិកតា តម្លៃ ៦៥០០០ (ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក ស្ថិតនៅភូមិជ័យថ្មី ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ជាមួយនឹងកូនបំណុលឈ្មោះ តែក្រោយមកកូនបំណុលមិនបានអនុវត្តតាម

កិច្ចសន្យានោះទេ ទើបនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ កូនបំណុលបានធ្វើកិច្ចសន្យាប្រគល់ដីមួយកន្លែងផ្សេងទៀតទំហំ ២០ ហិកតា ស្ថិតនៅភូមិស្រែជើងវះ ឃុំត្រពាំងក្រញូវ ស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីទូទាត់ថ្លៃឡានតម្លៃ ៦៥០០០ (ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។ ប៉ុន្តែនៅពេលដែលម្ចាស់បំណុលបានចុះទៅដល់ទីតាំងរបស់ដីនោះឃើញថា ដីនោះជាដីសម្បទានរបស់ក្រុមហ៊ុន JUHEF LIMITED ទៅវិញ ហើយបច្ចុប្បន្ន រថយន្តនោះគឺត្រូវបានកាន់កាប់ដោយសហកូនបំណុល។ នេះអាចឱ្យតុលាការជឿបានថា ចលនវត្ថុ (រថយន្ត) ដែលម្ចាស់បំណុលបានយកទៅដូរជាមួយនឹងដីទំហំ២០ហិកតានោះ គឺនៅតែជាកម្មសិទ្ធិរបស់ម្ចាស់បំណុលឈ្មោះ ។

៦.ផ្អែកតាមហេតុផលដូចមានក្នុងសំអាងហេតុខាងលើឃើញថា ម្ចាស់បំណុលមានការបារម្ភថាសហកូនបំណុលអាចយករថយន្តនោះទៅលក់ ឬ ប្រគល់ឱ្យទៅតតិយជនផ្សេងទៀត ដែលធ្វើឱ្យខ្លួននឹងមិនអាចអនុវត្តសិទ្ធិបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ទើបខ្លួនសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននូវចលនវត្ថុនោះ។ ដើម្បីការពារផលប្រយោជន៍របស់ភាគី តុលាការគប្បីសម្រេចតាមពាក្យសុំរបស់ម្ចាស់បំណុល យោងតាមមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៧.ប្រាក់ប្រដាប់ក្តី ត្រូវអនុវត្តតាមមាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>ហេតុដូច្នេះសម្រេច</u>

១.រឹបអូសជាបណ្តោះអាសន្ននូវចលនវត្ថុដែលជារថយន្តម៉ាក **TOYOTA LANCRUISER** ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2K-4242 ផលិតឆ្នាំ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 ដោយហាមឃាត់សហកូនបំណុលធ្វើការ **ផ្ទេរកម្មសិទ្ធិលក់ ដូរ ជួល ដាក់បញ្ចាំ ដាក់ប្រាតិភោគ ធ្វើអំណោយ ធ្វើអច្ច័យទាន និងផ្តល់សិទ្ធិឃាត់ទុក** ជាបណ្តោះអាសន្ន។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហកូនបំណុល។

ដីកាសម្រេចនេះ អាចប្តឹងតវ៉ាបានតាមមាត្រា៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា៖ លិ សុខា

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៨រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

អ៊ុំ_មេីងហួន

**បានឃើញ**

**ចៅក្រម**

លិ សុខា

គំរូលេខ ០១ សហវ/ចមព

260-1- 00199737

MEF20882604121

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

អង្គភាព..........................................

(ប្រគល់ជូនអ្នកបង់ប្រាក់)

ទទួលពី ......... ..................................................អង្គភាព..................................................................

ចំនួនទឹកប្រាក់ជាលេខ 5,000...........................................................................................................

ជាអក្សរ ...........................................................................................................

អត្ថន័យចំណូល....................................................................................មាតិកាថវិកា.....................

.........ថ្ងៃទី...........ខែ.........ឆ្នាំ..........

អ្នកប្រមូលចំណូល

ទេព សុវណ្ណារ៉ា

MINISTRY OF ECONOMY AND FINANCE

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
ចូល
សំណុំរឿងអនុវត្តរក្សាការពារ
លេខ: 104
ថ្ងៃទី 10 ខែ 05 ឆ្នាំ 2019

## ពាក្យស្នើសុំអនុវត្តដីកាសរក្សាការពារ

-ខ្ញុំបាទ ឈ្មោះ ភេទប្រុស អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ជាម្ចាស់បំណុលនៅក្នុងសំណុំរឿងរក្សាការពារ លេខ ១១៣ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ។

**គោរពជូន**

**លោកប្រធានសាលាដំបូងខេត្តកណ្ដាល**

**កម្មវត្ថុ** ៖ ស្នើសុំអនុវត្តដីការក្សាការពារ លេខ ០២៤ "ង" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល ត្រង់សេចក្ដីសម្រេចទាំងមូល ។

**យោង** ៖ -សំណុំរឿងរក្សាការពារលេខ: ១១៣ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ។

-ដីការក្សាការពារ លេខ ០២៤ "ង" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជំរាបជូន **លោកប្រធានសាលាដំបូងខេត្តកណ្ដាល** មេត្តាជ្រាបថា ៖ សាលាដំបូងខេត្តកណ្ដាលបានចេញដីកាសម្រេចរក្សាការពារ លេខ ដីការក្សាការពារ លេខ ០២៤ "ង" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ដែលបង្គាប់ឲ្យ ៖ រឹបអូសអចលនវត្ថុ (ដី) ដែលស្ថិតនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលមានក្បាលដី លេខ ៣៧០ ដែលមានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣៧៤ ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៤ មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១១៦០១-០៣៧០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល ជាបណ្ដោះអាសន្ន ដើម្បីរក្សាស្ថានភាពដើមនៃអចលនវត្ថុនោះ និងរងចាំតុលាការសម្រេចដល់អង្គសេចក្ដីចប់ជាស្ថាពរ និងដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ ។ ហេតុដូច្នេះ ទើបខ្ញុំបាទស្នើសុំមកកាន់តុលាការឲ្យធ្វើការអនុវត្តលើដីកាសម្រេចរក្សាការពារ ខាងលើ ។

អាស្រ័យហេតុនេះសូម **លោកប្រធាន** មេត្តាសំរេចតាមការស្នើសុំដោយក្ដីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

កណ្ដាល ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩

ស្នាមមេដៃស្ដាំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរក្សាការពារ
លេខ: ១១៣ រកព
ចុះថ្ងៃទី០៨-០៥-២០១៩
ដីកាលេខៈ [illegible] ជកសរ
ចុះថ្ងៃទី១០-ឧសភា-២០១៩

## ដីកាសម្រេចរក្សាការពារ

យើង **អ៊ី សុមណ្ណា** ចៅក្រមសាលាដំបូងខេត្តកណ្តាល

-បានឃើញក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមនស/រកម/០៧០៦/០២១/ចុះថ្ងៃទី០៦-០៧-២០០៦។

-បានឃើញសំណុំរឿងរក្សាការពារលេខ: ១១៣ ចុះថ្ងៃទី០៨-០៥-២០១៩ ។

-រវាងម្ចាស់បំណុលឈ្មោះ ភេទប្រុស អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

-និងកូនបំណុលឈ្មោះ ភេទស្រី កើតឆ្នាំ១៩៦៧ មានអាសយដ្ឋានបច្ចុប្បន្ន ភូមិ ឃុំ ស្រុក ខេត្តកណ្តាល ។

**<u>កម្មវត្ថុ</u>** ប្តឹងសុំដីកាសម្រេចរក្សាការពារ:

១.ហាមឃាត់កូនបំណុល ឈ្មោះ មិនឲ្យធ្វើការ លក់ ដូរ ជួល ដាក់បញ្ចាំ ផ្ទេរកម្មសិទ្ធិ ធ្វើអំណោយ ធ្វើអច្ច័យទាន ធ្វើមរតកទៅឲ្យទាយាទ សាងសង់សំណង់គ្រប់ប្រភេទ និងដាំដំណាំគ្រប់ប្រភេទ លើដីទំហំ១៤២១ ម៉ែត្រការ៉េ ដែលក្បាលដីមានលេខ ៣១០ ដែលមានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣១៤ ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៤ ដែលមានទីតាំងស្ថិតនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

២. ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់កូនបំណុល ។

-បានឃើញ ពាក្យសុំដីការក្សាការពារចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ របស់ម្ចាស់បំណុលឈ្មោះ ។

- បានឃើញ កិច្ចសន្យាផ្ទេរនាប់ដៃ កក់ប្រាក់ទិញលក់ដី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ រវាងឈ្មោះ និងឈ្មោះ ។

- បានឃើញ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ០៨០១១៦០១-០៣១០ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៩ ។

### <u>សំអាងហេតុ</u>

១- តាមសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលឈ្មោះ បានបញ្ជាក់ថា ខ្លួនបានទិញដីទំហំ ១៤២១ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានក្បាលដី លេខ ៣១០ ដែលមានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣១៤ ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៤ ដីនេះកូនបំណុលបានលក់ឲ្យខ្លួន ដោយកូនបំណុលបានទទួលប្រាក់កក់ផ្ទេរនាប់ដៃពីខ្លួនចំនួន ២,០០០ (ពីរពាន់) ដុល្លារអាមេរិក ហើយកូនបំណុលត្រូវធ្វើការផ្ទេរសិទ្ធិ និងផ្តិតមេដៃលើអក្សរ ព្រមទាំងប្រគល់ឯកសារកាន់កាប់ច្បាប់ដើមមកឲ្យខ្លួន ប៉ុន្តែក្រោយពេលខ្លួនប្រគល់ប្រាក់កក់ ២,០០០ (ពីរពាន់) ដុល្លារអាមេរិករួចហើយ កូនបំណុលបែរជាមកទាមទារឲ្យខ្លួនតំឡើងថ្លៃដីឲ្យគាត់ ច្រើនជាងថ្លៃដីដែលមាននៅក្នុងកិច្ចសន្យា ទើបគាត់ព្រមលក់ដីឲ្យ ។ ក្រោយពីចចារខ្មា មិនបាន ខ្លួនបានយកប្រាក់ទៅប្រគល់ឲ្យកូនបំណុល ក៏កូនបំណុលមិនព្រម ហើយកូនបំណុលបានអះអាងថា ឈប់លក់ដីនេះ ឲ្យខ្លួនហើយ បើខ្លួនមិនព្រមឲ្យតម្លៃដីតាមការទាមទារលើសពីការកំណត់នៅក្នុងកិច្ចសន្យាផ្ទេរនាប់ដៃកក់ប្រាក់លក់ដី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ ដោយកាលនោះកូនបំណុលលក់ដីឲ្យខ្លួនក្នុងតម្លៃ ១៥ ដុល្លារអាមេរិក ក្នុង១ម៉ែត្រការ៉េ ដោយមិនមានធ្វើការដោះ

ក្រឡាបញ្ជី និង ចុងកៃ

ស្រាយគ្នាជាមួយកូនបំណុលគទៅទៀតបាន និងបារម្ភ ថាកូនបំណុលយកដីនេះទៅលក់បន្ត ទើបខ្លួនដាក់ពាក្យសុំរក្សាការពារដីនេះ មកកាន់តុលាការតែម្តង ។

២-តាមសេចក្តីបញ្ជាក់ដំបូង ដែលភាគីម្ចាស់បំណុលផ្តល់មកសាលាដំបូងខេត្តកណ្តាលគឺម្ចាស់បំណុល និងកូនបំណុល បានធ្វើកិច្ចសន្យាទ្រនាប់ដៃ កក់ប្រាក់ទិញលក់ដី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ រវាងឈ្មោះ និងឈ្មោះ អាចបង្ហាញឲ្យឃើញពីអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិ ដែលគ្មានគោលបំណងឲ្យសងជាប្រាក់ ។

៣-តាមរយៈវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ០៨០១១៦០១-០៣១០ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល បញ្ជាក់អំពីទំនាក់ទំនងកម្មសិទ្ធិរបស់ម្ចាស់បំណុលប្រាកដមែន ។

៤- ដើម្បីជៀសវាងការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ហើយនិងមានការលំបាកក្នុងការអនុវត្តដោយបង្ខំ ដែលនឹងអាចកើតមានឡើងដល់ម្ចាស់បំណុល តាមមាត្រា ៥៤៨ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការគប្បីចេញដីកាសម្រេចចាត់វិធានការបណ្តោះអាសន្ន ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងដើម្បីរក្សាស្ថានភាពដើមនៃអចលនវត្ថុនោះ ។

**<u>ហេតុដូច្នេះសម្រេច:</u>**

១-រឹបអូស អចលនវត្ថុ (ដី) ដែលស្ថិតនៅភូមិព្រែកស្តែង ឃុំព្រែកស្តែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានក្បាលដី លេខ ៣១០ ដែលមានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣១៤ ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៤ មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១១៦០១-០៣១០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ជាបណ្តោះអាសន្ន ដើម្បីរក្សាស្ថានភាពដើមនៃអចលនវត្ថុនោះ និងរង់ចាំតុលាការសម្រេចដល់អង្គសេចក្តីចប់ជាស្ថាពរ។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

ភាគីដែលមិនសុខចិត្តនឹងដីកាសម្រេចនេះ មានសិទ្ធិប្តឹងតវ៉ាតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី៕

ថ្ងៃសុក្រ ៧កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២
កណ្តាល, ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩
**ចៅក្រម**

ឌី–សុវណ្ណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងអនុវត្តរក្សាការពារ
លេខ: ១០២ អវរ
ចុះថ្ងៃទី១០.០៥.២០១៩
លេខ: ...1045...

# ដីកាបញ្ជូន

**ផ្ញើជូន:** លោកប្រធានមន្ទីររៀបចំដែន នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១. | -លិខិតផ្អកផ្អាក់ឲ្យចុះបញ្ជី លេខ៖ .066. ចុះថ្ងៃទី.21.. ខែឧសភា ឆ្នាំ២០១៩ | ២ ច្បាប់ | "ដើម្បីជាសមត្ថកិច្ច" |
| | | | |
| | | | |
| | **សរុប ចំនួន** | ២ ច្បាប់ | |

ថ្ងៃ..ចន្ទ..[illegible] ខែ.ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
កណ្តាល,ថ្ងៃទី.27 ខែឧសភា ឆ្នាំ២០១៩
**ប្រធានសាលាដំបូង**

ក្រឡាបញ្ជី និង ថ្នងកៃរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ: 066

## លិខិតផ្ទុកផ្តាក់អោយចុះបញ្ជី
## យើង នឹង ដួងកែម ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល
## គោរពជូន
## លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តកណ្តាល

**កម្មវត្ថុ:** សំណើរសុំធ្វើការចុះបញ្ជីរឹបអូស

**សញ្ញាណនៃអចលនវត្ថុ:** អចលនវត្ថុ(ដី)ទំហំ១៤២១ ម៉ែត្រការ៉េ ក្បាលដីមានលេខ ៣១០ មានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣១៤ ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៤ ដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ០៨០១១៦០១-០៣១០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

**គោលបំណងនៃការចុះបញ្ជី:** ចុះបញ្ជីរឹបអូសអចលនវត្ថុ (ដី) ទំហំ១៤២១ ម៉ែត្រការ៉េ ក្បាលដីមានលេខ ៣១០ មានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣១៤ ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៤ ដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ០៨០១១៦០១-០៣១០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

**មូលហេតុ:** ដីកាសម្រេចរក្សាការពារ លេខ: ០២៤ ដកសរក/១៩ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្ត កណ្តាល ។

**អ្នកមានសិទ្ធិចុះបញ្ជី (ម្ចាស់បំណុលនៃការអនុវត្ត)÷** ឈ្មោះ ភេទប្រុស អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

**អ្នកមានភារកិច្ចចុះបញ្ជី (កូនបំណុលនៃការអនុវត្ត)÷** ឈ្មោះ ភេទស្រី កើតឆ្នាំ១៩៦៧ មានអាស័យដ្ឋានបច្ចុប្បន្នភូមិ ឃុំ ស្រុក ខេត្តកណ្តាល ។

អាស្រ័យហេតុនេះ សូមលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ចាត់ឱ្យចុះបញ្ជីអចលនវត្ថុខាងលើនេះ ដើម្បីធ្វើការរឹបអូស ក្រោយពីធ្វើការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើការផ្ទុកផ្តាក់ខាងលើរួចហើយ សូមលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល មេត្តាចាត់ផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី ព្រមទាំងសោហ៊ុយចាត់ចែងការចុះបញ្ជី មកការិយាល័យក្រឡាបញ្ជីតុលាការអនុវត្ត នៃសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការបន្តតាមនីតិវិធី។

សូមលោកប្រធានមន្ទីរ ទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃអង្គារ ៣រោច-ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
កណ្តាល ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩
ក្រឡាបញ្ជី

នឹង_ដួងកែម

បានឃើញ
តុលាការអនុវត្ត

អ៊ុំ_សុខណ្ណា

**ឯកសារភ្ជាប់ជាមួយ:**

- ដីកាសម្រេចរក្សាការពារ លេខ: ០២៤ ដកសរក/១៩ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ។
- វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ០៨០១១៦០១-០៣១០ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៩ ។

| | | | | | |
|---|---|---|---|---|---|
| ភ[illegible]និ[illegible]ខត្ត | ក្រុង/ស្រុក/ខណ្ឌ | | ឃុំ/សង្កាត់ | ភូមិ | ផ្លូវ |
| លេខក្បាលដី | សន្លឹកផែនទី | | មធ្យោបាយធ្វើអត្តសញ្ញាណកម្មក្បាលដី | | ទំហំដី |
| ប្រភេទដី | រូបភាពប្រើប្រាស់ដី | | លក្ខណៈនៃការប្រើប្រាស់ដី | | អក្ខរសញ្ញា |
| ឈ្មោះកម្មសិទ្ធិករ | | | | | |

| **អត្រានុកូលដ្ឋានម្ចាស់អចលនវត្ថុ** | | | **ការផ្លាស់ប្តូរ** | | **សេចក្តីផ្សេងៗ** |
|---|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត | សាវតា | លេខាធិការដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| | | | | ១.ត្រូវបានរឹបអូសជាបណ្តោះអាសន្នដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible] របស់សាលាដំបូង [redacted]<br>២. | |

POLY

(3)

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឲ្យអនុវត្តរក្សាការពារ

ខ្ញុំ P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអាគារ .... ជាន់ទី.... បន្ទប់ ........ ផ្លូវលេខ............ សង្កាត់........ ខណ្ឌ......... រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ ................។

## សូមគោរពជូន
## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ** ៖សំណើសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២០ "ខ" ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ

**យោង** ៖-សំណុំរឿងរក្សាការពារលេខ១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩

-មាត្រា ៥៦៤ មាត្រា ៥៦៦ មាត្រា ៩០៣ និងមាត្រា ៩០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

សេចក្តីដូចមានកំណត់នៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ សាលាដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នតាមការស្នើសុំរបស់ម្ចាស់បំណុល ហេតុនេះស្នើសុំអនុវត្តដូចខ្លឹមសារខាងក្រោម

### ក.សញ្ញាណនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២០ "ខ" ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ។

### ខ.សេចក្តីស្នើសុំឲ្យអនុវត្ត

វិធានអនុវត្តបង្ខំដោយផ្ទាល់ ដោយហាមឃាត់កូនបំណុលទី៣មិនឲ្យបើកប្រាក់នៅក្នុងគណនីធនាគាររបស់កូនបំណុលទៅឲ្យកូនបំណុល និងស្នើសុំតុលាការដាស់តឿនឲ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍ អំពី ៖

ទី១ អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ប្រភេទប្រាក់ ចំនួនទឹកប្រាក់ និងខ្លឹមសារនៃសិទ្ធិលើបំណុល

ទី២ អត្ថិភាព ឬនត្ថិភាពនៃឆន្ទៈសង និងទំហំនៃការសង ឬមូលហេតុដែលមិនសង

ទី៣ បើមានសញ្ញាណនៃបុគ្គលដែលមានអាទិភាពជាងម្ចាស់បំណុលនៃការអនុវត្ត ចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ ប្រភេទនៃសិទ្ធិរបស់បុគ្គលនោះ និងទំហំនៃអាទិភាព

ទី៤ អត្ថិភាព ឬនត្ថិភាពនៃការរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ ដោយម្ចាស់បំណុលផ្សេងទៀត

**គ.សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តរក្សាការពារ**

កំណត់នៅក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុដែលភ្ជាប់ជាមួយនឹងពាក្យសុំនេះ។

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧

**អ្នកតំណាងដោយអាណត្តិ**

<u>ឯកសារភ្ជាប់</u>

១.លិខិតតំណាងដោយអាណត្តិ "ច្បាប់ដើម"

២.ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២០ "ខ" ដ.រ ចុះថ្ងៃទី០៩-០៣-២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ "ច្បាប់ដើម"

**បញ្ជីភាគី**

**ម្ចាស់បំណុល ៖**

ឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល ៖**

មេធាវី P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអាគារ ..... ជាន់ទី.... បន្ទប់ ......... ផ្លូវលេខ............ សង្កាត់........ ខណ្ឌ......... រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ ...................................។

ទីកន្លែងបញ្ជូន ៖ ការិយាល័យមេធាវី ...........។

**កូនបំណុល ៖**

ឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**កូនបំណុលទី៣ ៖**

ទី១ **ធនាគារ** ABA (ADVANCED BANK OF ASIA LIMITED) ដែលមានអាសយដ្ឋានស្ថិតនៅអគារលេខ១៤៨ មហាវិថីនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

ទី២ **ធនាគារ** ACELEDA BANK PLC ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ទី៣ **ធនាគារ** SHINHAN ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ៧៩ (អាគារវ៉ាន់ដាថោវើ) មហាវិថីកម្ពុជាក្រោម សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

# បញ្ជីសិទ្ធិលើបំណុល

១.ប្រាក់ដើមចំនួន ៖ **100,000 USD**

សិទ្ធិលើបំណុលដែលទាមទារឲ្យសងគឺប្រាក់ដើមចំនួន **100,000 USD** (មួយសែន) ដុល្លារអាមេរិកដែល **Y** បានខ្ចីពី **X** ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥។

២.ការប្រាក់ ៖ **10%**ក្នុងមួយឆ្នាំ

នៅពេលចុះកិច្ចសន្យាខ្ចីប្រាក់ **Y** និង **X** បានព្រមព្រៀងអំពីអត្រាការប្រាក់ ដែលមានចំនួន**10%**ក្នុងមួយឆ្នាំ ធៀបនឹងប្រាក់ដើម (**100,000 USD**) ហើយការព្រមព្រៀងនេះបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខារបស់ **Y** ផងដែរ ហេតុនេះសិទ្ធិលើបំណុលជាការប្រាក់មានចំនួន **10,000 USD** (មួយម៉ឺន) ដុល្លារអាមេរិក។

៣.ការប្រាក់យឺតយ៉ាវ ៖ **20%**ក្នុងមួយឆ្នាំ

នៅពេលចុះកិច្ចសន្យាខ្ចីប្រាក់ **Y** និង **X** បានព្រមព្រៀងអំពីអត្រាការប្រាក់យឺតយ៉ាវដែលមានចំនួន**20%**ក្នុងមួយឆ្នាំ ធៀបនឹងប្រាក់ដើម (**100,000 USD**) ដោយបានកំណត់សងនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ប៉ុន្តែ **Y** មិនបានសងប្រាក់ ហេតុនេះសិទ្ធិលើបំណុលជាការប្រាក់យឺតយ៉ាវមានចំនួន **20,000 USD** (ពីរម៉ឺន) ដុល្លារអាមេរិក (គិតចាប់ពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ដល់ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧)។

៤.កំណត់ពេលសង ៖ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦

នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៥ បានកំណត់ពេលសងនៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៦។

# បញ្ជីសារពើភណ្ឌនៃទ្រព្យ

## គណនីធនាគារ ABA (ADVANCED BANK OF ASIA LIMITED)

១.ទីតាំងធនាគារ ៖ អគារលេខ១៤៨ មហាវិថីនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

២.លេខគណនីធនាគារ ៖ 0000000000

៣.ម្ចាស់គណនីធនាគារ ៖ Y

៤.ប្រភេទរូបិយវត្ថុ ៖ ដុល្លារអាមេរិក (USD)

## គណនីធនាគារ ACELEDA BANK PLC

១.ទីតាំងធនាគារ ៖ អាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

២.លេខគណនីធនាគារ ៖ 000000000

៣.ម្ចាស់គណនីធនាគារ ៖ Y

៤.ប្រភេទរូបិយវត្ថុ ៖ ដុល្លារអាមេរិក (USD)

## គណនីធនាគារ SHINHAN

១.ទីតាំងធនាគារ ៖ អាគារលេខ៧៩ (អាគារវ៉ាន់ដាថោវើ) មហាវិថីកម្ពុជាក្រោម សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

២.លេខគណនីធនាគារ ៖ 000000000

៣.ម្ចាស់គណនីធនាគារ ៖ Y

៤.ប្រភេទរូបិយវត្ថុ ៖ ដុល្លារអាមេរិក (USD)

(2)

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧
ដីកាសម្រេចលេខ ២០ "ខ" ដ.រ
ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧

## ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

## យើង J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា៥៤១ មាត្រា៥៤៥ និងមាត្រា៥០៣នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានឃើញពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារចុះថ្ងៃទី០២-០៣-២០១៧

-បានឃើញសំណុំរឿងរក្សាការពារលេខ១០ចុះថ្ងៃទី០២-០៣-២០១៧

**ម្ចាស់បំណុល** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** ៖ឈ្មោះ P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអាគារ .... ជាន់ទី.... បន្ទប់ ........ផ្លូវលេខ............ សង្កាត់........ ខណ្ឌ.................. រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ .............។

**កូនបំណុល** ៖ ឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ១០ ផ្លូវលេខ៣១០ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៥ រាជធានីភ្នំពេញ។

**កូនបំណុលទី៣** ៖

ទី១ **ធនាគារ** ABA (ADVANCED BANK OF ASIA LIMITED) ដែលមានអាសយដ្ឋានស្ថិតនៅអគារលេខ១៤៨ មហាវិថីនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

ទី២ **ធនាគារ** ACELEDA BANK PLC ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ទី៣ **ធនាគារ** SHINHAN ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ៧៩ (អាគារវ៉ាន់ដាថោវើ) មហាវិថីកម្ពុជាក្រោម សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ**

១.រឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុ

២.កូនបំណុលត្រូវផ្ញើប្រាក់រំដោះចំនួន 130,000 USD (មួយសែនបីម៉ឺន) ដុល្លារអាមេរិក ដើម្បីទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

៣.ហាមឃាត់កូនបំណុលទី៣មិនឲ្យបើកប្រាក់ក្នុងគណនីធនាគាររបស់កូនបំណុលឲ្យទៅកូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុ

៤.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

**បញ្ជីសិទ្ធិលើបំណុល ៖** ដូចមានភ្ជាប់នៅក្នុងឯកសារស្ដីពីសិទ្ធិលើបំណុល

**បញ្ជីសារពើភណ្ឌនៃវត្ថុ ៖** ដូចមានភ្ជាប់នៅក្នុងឯកសារស្ដីពីបញ្ជីសារពើភណ្ឌនៃវត្ថុ

**សេចក្ដីបញ្ជាក់ដំបូង**

១.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥។ (ភស្តុតាង $X_1$)

២.លិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥។ (ភស្តុតាង $X_2$)

៣.សៀវភៅគណនីធនាគាររបស់ Y ។ (ភស្តុតាង $X_3$)

៤.លិខិតដាស់តឿនរបស់ X ។ (ភស្តុតាង $X_4$)

## សំអាងហេតុ

១.ផ្អែកតាមភស្តុតាង $X_1$និងភស្តុតាង $X_2$ អាចឲ្យតុលាការសន្និដ្ឋានបានថាឈ្មោះ Y (កូនបំណុល) បានខ្ចីប្រាក់ពីឈ្មោះ X (ម្ចាស់បំណុល) ដែលមានខ្លឹមសារថាប្រាក់ដើមចំនួន **100,000 USD** (មួយសែន) ដុល្លារអាមេរិក ការប្រាក់ **10%**ក្នុងមួយឆ្នាំ ការប្រាក់យឺតយ៉ាវ **20%** ក្នុងមួយឆ្នាំ និងកំណត់ពេលសងគឺថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ហើយ ក៏បានទទួលប្រាក់កម្ចីនេះគ្រប់ចំនួន ផងដែរ។ ទោះបីកាលកំណត់សងបានមកដល់ក៏ដោយ ក៏កូនបំណុលនៅតែមិនសងប្រាក់ដើម និងការប្រាក់ (ការប្រាក់ធម្មតា និងការប្រាក់យឺតយ៉ាវ) រហូតមកដល់ថ្ងៃដាក់ពាក្យសុំ។ តុលាការទទួលស្គាល់បានថា ម្ចាស់បំណុលមានសិទ្ធិលើបំណុលចំពោះកូនបំណុលចំនួន **130,000 USD** (មួយសែនបីម៉ឺន) ដុល្លារអាមេរិក គិតមកត្រឹមថ្ងៃដាក់ពាក្យសុំនេះ។

២.ផ្អែកតាមភស្តុតាង $X_4$ អាចឲ្យតុលាការសន្និដ្ឋានបានថាកូនបំណុលបានទទួលការដាស់តឿនឲ្យសងប្រាក់ ប៉ុន្តែកូនបំណុលមិនបានអនុវត្តករណីយកិច្ចនោះក្នុងអំឡុងពេលដែលបានកំណត់ឡើយ។

៣.ផ្អែកតាមភស្តុតាង $X_3$ អាចឲ្យតុលាការសន្និដ្ឋានបានថាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន គឺសិទ្ធិលើបំណុលដែលជាប្រាក់ក្នុងគណនីធនាគាររបស់កូនបំណុល។ តុលាការអាចទទួលស្គាល់បានថា អចលនវត្ថុមានកំណត់នៅក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុ ជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុល។

៤.តុលាការអាចទទួលស្គាល់បានថា មានភាពចាំបាច់ក្នុងការរឹបអូសជាបណ្តោះអាសន្ន នូវសិទ្ធិលើបំណុលជាប្រាក់ក្នុងគណនីធនាគារទាំងបីកន្លែងរបស់កូនបំណុល ដើម្បីធានាសិទ្ធិ របស់ម្ចាស់បំណុលក្នុងការទាមទារឲ្យសងប្រាក់ សម្រាប់ការអនុវត្តដោយបង្ខំនាពេលអនាគត ក្នុងគោលដៅធានាឲ្យបាននូវការអនុវត្ត នៅចន្លោះពេលបណ្តឹងអង្គសេចក្តីមិនទាន់ស្ថាពរ ឬ មានអានុភាពអនុវត្ត។

៥.តុលាការអាចទទួលស្គាល់ការស្នើសុំរបស់ម្ចាស់បំណុល ហេតុនេះកូនបំណុលគប្បី ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

**សេចក្តីសម្រេចបញ្ចប់**

១.រឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុរបស់កូនបំណុល ដូចមានកំណត់នៅក្នុង បញ្ជីសារពើភណ្ឌនៃវត្ថុ

២.កូនបំណុលត្រូវផ្ញើប្រាក់រំដោះចំនួន **130,000 USD** (មួយសែនបីម៉ឺន) ដុល្លារអាមេរិក ដើម្បីទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន

៣.ហាមឃាត់កូនបំណុលទី៣មិនឲ្យបើកប្រាក់ក្នុងគណនីធនាគាររបស់កូនបំណុលឲ្យ ទៅកូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីសាពើភណ្ឌនៃវត្ថុ

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

ដីកាសម្រេចនេះអាចប្តឹងតវ៉ាបានតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧

**ចៅក្រម**

# ឧបសម្ព័ន្ធទី៤
# ពាក្យបណ្តឹងសុំតវ៉ាលុបចោល
# ដីកាសម្រេចរក្សាការពារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

"ឫ"

**ពាក្យសុំលុបចោលដីកា**
**សម្រេចរឹបអូសជាបណ្ដោះអាសន្ន**

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃទី.31...ខែ..08..ឆ្នាំ2022

លេខ៖...៦៩.........TPL.២២...

លោក... ..........
ថ្ងៃទី...31.ខែ..08...ឆ្នាំ2022

**មេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុល៖** ខ្ញុំបាទមេធាវី អត្តលេខ និងលោកមេធាវី អត្តលេខ ជាមេធាវីតំណាងដោយអាណត្តិឱ្យកូនបំណុលឈ្មោះ ភេទប្រុស អាយុ ៣៤ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិពងទឹក ឃុំរការប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី២៩.០៨.២០២២ ជាសម្គាល់ ។

**ម្ចាស់បំណុល៖** ឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១៦៤អឺ0 ភូមិក្រាំងអង្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

សាលាដំបូងរាជធានីភ្នំពេញ
ចូល
លេខ......0020073
ថ្ងៃទី 31 ខែ 08 ឆ្នាំ 2022

**សូមគោរពចូលមក**

**ឯកឧត្ដម ប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**សូមមេត្តាជ្រាប។**

**កម្មវត្ថុ៖**-សំណើរសុំលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ៣២៨ "រ" ដ.រ ចុះថ្ងៃទី២១.០៧.២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**យោង៖**-សំណុំរឿងរក្សាការពារលេខ ២០៥ ចុះថ្ងៃទី០៦.០៥.២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-លិខិតតំណាងដោយអាណត្តិ លេខ ៦៦ TPL ២២ ចុះថ្ងៃទី២៩.០៨.២០២២ ។ (ថតចម្លង)

-ដីកាសម្រេចលេខ ២៩០ អ.ឃ.ក ចុះថ្ងៃទី១២.០៤.២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។ (ថតចម្លង)

-ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ៣២៨ "រ"ដ.រ ចុះថ្ងៃទី ២១.០៧.២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-លិខិតលក់រថយន្ត ចុះថ្ងៃទី២៥.១០.២០១៨ ។ (ថតចម្លង)

-លិខិតលក់រថយន្ត ចុះថ្ងៃទី២៥.១០.២០១៨ ។ (ថតចម្លង

-លិខិតទិញរថយន្ត ចុះថ្ងៃទី០៤.០២.២០១៩ ។ (ថតចម្លង)

-ប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី០៥.១០.២០០៩ ។ (ថតចម្លង)

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំ មានកិត្តិយស សូមជម្រាបជូន ឯកឧត្ដមប្រធាន មេត្តាជ្រាបថា៖ ម្ចាស់បំណុលបានប្ដឹងសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ៣២៨ "រ"ដ.រ ចុះថ្ងៃទី២១.០៧.២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយរឹបអូសជាបណ្ដោះអាសន្ននូវចលនវត្ថុដែលជារថយន្តម៉ាក TOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2K-4242 ផលិតនៅឆ្នាំ២០០៨ ដោយមានលេខម៉ាស៊ីន 1VD0019075 លេខតួ JTMHV09J084009074 ដោយហាមឃាត់កូនបំណុលធ្វើការផ្ទេរកម្មសិទ្ធិលក់ ដូរ ជួល ដាក់បញ្ចាំ ដាក់ប្រាតិភោគធ្វើអំណោយ ធ្វើអច្ច័យទាន និងផ្ដល់សិទ្ធិឃាត់ទុក ជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នដែលជាកម្មសិទ្ធិរបស់កូនក្ដីយើងខ្ញុំ។ ចំពោះរថយន្តម៉ាក TOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2K-4242 កូនក្ដីយើង

បានទិញពីឈ្មោះ ក្នុងតម្លៃ 48,000 USD (បួនម៉ឺនប្រាំបីពាន់ដុល្លាអាមេរិក) តាមរយៈលិខិតទិញរថយន្ត ចុះ ០៤.០២.២០១៩ ជាសំអាង។ ដោយនៅពេលនោះឈ្មោះ បានបង្ហាញពីប្រវត្តិនៃការលក់-ទិញរថយន្តមកកាន់កូនក្តីយើងខ្ញុំ លិខិតលក់រថយន្ត ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ដែលមានលោក លក់រថយន្តទៅអោយលោក ដោយនេ ដដែលនោះលោក បានលក់រថយន្តទៅអោយលោក ដែលមានលិខិតលក់រថយន្ត ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០ ដោយពិនិត្យឃើញថារថយន្តនេះ មានឯកសារលក់-ទិញរថយន្ត និងមានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី០៥.១០.២០០៩ ត្រឹមត្រូវ តាមទម្ នៃការលក់-ទិញរថយន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយ ទើបកូនក្តីយើងខ្ញុំសម្រេចចិត្តទិញ។ ករណីនេះ បញ្ជាក់បានថាកូនក្តីយើងខ្ញុំ ជនសុចរិត ដូច្នេះម្ចាស់បំណុលពុំមានចំណងគតិយុត្តិណាមួយជាមួយកូនក្តីយើងខ្ញុំទេ ។

ផ្អែកតាមដីកាសម្រេចលេខ ២៩០ អ.យ.ក ចុះថ្ងៃទី១២.០៤.២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សំណុំរឿងព្រហ្មទណ្ឌលេខ១៨៨៨ ចុះថ្ងៃទី២៥.០៣.២០១៩ រវាងលោក ជាមួយលោក ហើយតុលាការក៏ប សម្រេចប្រគល់រថយន្តម៉ាកTOYOTA LANCRUISER ពណ៌ខ្មៅ ពាក់ផ្លាកលេខភ្នំពេញ2K-4242 មកអោយកូនក្តីយើងខ្ញុំម្តងរួចមកហើយ

ចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ៣២៨ “រ” ដ.រ ចុះថ្ងៃទី២១.០៧.២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ បានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិក្នុងការប្រើប្រាស់ ដោយកូនក្តីយើងខ្ញុំត្រូវការរថយន្តក្នុងការប្រកបរបរចិញ្ចឹមជីវិត ការរឹបអូសនេះបានធ្វើឲ្យ ពាល់ដល់ស្ថានភាពសេដ្ឋកិច្ចក្នុងគ្រួសារ និងបាត់បង់ផលប្រយោជន៍របស់កូនក្តីយើងខ្ញុំយ៉ាងធ្ងន់ធ្ងរ។

យោងតាមមាត្រា៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានចែងអំពីភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។ នេ ក្នុងករណីនេះ កូនក្តីយើងខ្ញុំ មិនបានទិញរថយន្តពីលោក ទេ គឺទិញពីលោក ហើយក៏មិនបានជាប់ពាក់ព័ន្ធអំ ឆបោកណាមួយឡើយ។ ហេតុដូច្នេះ ពុំមានភាពចាប់បាច់ដែលត្រូវរឹបអូសជាបណ្តោះអាសន្ននូវចលនវត្ថុដែលជារថយន្តម៉ាក TOYOT LANCRUISER ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2K-4242 របស់កូនក្តីយើងខ្ញុំទេ ។

**<u>សំណូមពរ៖</u>**

យើងខ្ញុំ សូមសំណូមពរសុំឲ្យតុលាការ មេត្តាសម្រេចចេញលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ៣២៨ “រ” ដ.រ ចុះថ្ងៃទី២១.០៧.២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ចោលជាអសារបង់ ដោយសារអង្គហេតុនេះ ធ្លាប់បានតុលាការសម្រេចម្តងរួច មកហើយ និងស្នើសុំដីកាសម្រេចនេះ មានអានុភាពអនុវត្តភ្លាម ។

អាស្រ័យហេតុនេះសូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចចេញលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ៣២៨ “រ” ដ.រ ចុះថ្ងៃទី២១.០៧.២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយក្តីអនុគ្រោះ។

សូម ឯកឧត្តមប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ថ្ងៃពុធ ៥ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

AVOCAT ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី

មេធាវី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

404

ថ្ងៃទី 10 ខែ 03

## ពាក្យបណ្ដឹងសុំតវ៉ាលុបដីកាសម្រេចរក្សាការពារ

កូនបំណុល៖ ឈ្មោះ ភេទស្រី កើតឆ្នាំ១៩៦៧ ជនជាតិខ្មែរ អាសយដ្ឋាន

ភូមិ ឃុំ ស្រុក ខេត្តកណ្ដាល។ Tel ០៨៨ ៧៣ ៧៥ ៣៨៥

**សូមគោរពជូនមក**

លោកចៅក្រម និងក្រឡាបញ្ជី

**ឯកឧត្តមប្រធានសាលាដំបូងខេត្តកណ្ដាល**

ទទួលបន្ទុក ពិនិត្យជាសមត្ថកិច្ច ។ *សូមមានប្រាប។*

កម្មវត្ថុ: ស្នើសុំតវ៉ាលុបដីកាសម្រេចរក្សាការពារ។

យោង: សំណុំរឿងរក្សាការពារលេខ: ១១៣ រកព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថា៖ ឈ្មោះ បានដាក់ពាក្យសុំរក្សាការពារ ដែលមាន សំណុំរឿងរក្សាការពារលេខ: ១១៣ រកព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល។ នៅក្នុងដីកាសម្រេចរក្សាការពារលេខ៖ ០២៩ ដកសរ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល តុលាការបានសម្រេច សេចក្ដីដូចខាងក្រោម៖

១-រឹបអូស អចលនវត្ថុ (ដី) ដែលស្ថិតនៅភូមិ ឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលមានក្បាលដីលេខ ៣១០ ដែលមានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣១៩ ,ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ,ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៨ មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១១៦០១-០៣១០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល ជាបណ្ដោះអាសន្ន ដើម្បីរក្សាស្ថានភាពដើមនៃអចលនវត្ថុនោះ និងរង់ចាំតុលាការសម្រេចដល់អង្គសេចក្ដីចប់ជាស្ថាពរ។

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

ភាគីដែលមិនសុខចិត្ត នឹងដីកាសម្រេចនេះ មានសិទ្ធិប្ដឹងតវ៉ាតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

យើងខ្ញុំសូមជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថា៖ ចំពោះដីកាសម្រេចដែលមានខ្លឹមសារដូចមានរៀបរាប់ ខាងលើពិតជាប៉ះពាល់យ៉ាងខ្លាំង ដល់ផលប្រយោជន៍ស្របច្បាប់របស់នាងខ្ញុំ ដោយហេតុថា នាងខ្ញុំបានលក់ដីឱ្យទៅឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៧៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៦អា ផ្លូវបេតុង ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយមានអ្នកតំណាងឈ្មោះ ដែលមានកិច្ចសន្យាទ្រនាប់ដៃ កក់ប្រាក់ទិញលក់ដី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ ដីមួយ កន្លែងទំហំ ១៤២១ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅក្នុងព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដោយភាគីទាំងពីរ បានព្រៀមព្រៀងគ្នាថា ផុតកំណត់រយៈពេលចំនួន ៣០ ថ្ងៃ ចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ តទៅ ប្រាក់ដែលបានកក់នោះ ត្រូវជាច់ប្រាក់កក់ ជាសារបង់។ រហូតមកដល់ពេលនេះដីទាំងមួយកន្លែងរបស់នាងខ្ញុំនោះ បានរំលោយកិច្ចសន្យា បាត់ហើយ។ នាងខ្ញុំបានជូនដំណឹងទៅឈ្មោះ ជាអ្នកតំណាងឱ្យឈ្មោះ ចំនួន ៣ ដងរួមមកហើយ ព្រមទាំងបានលាយល័ក្ខជាអក្សរទៀតផង។ នៅពេលនាងខ្ញុំ រកលក់ដីបន្ត ទៀត លោកមេឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បានប្រាប់ថា ក្បាលដីមួយកន្លែងខាងលើនេះ គឺ ជាប់ដីកាសម្រេចរក្សាការពារ បាត់ទៅហើយ ដោយម្ចាស់បំណុលឈ្មោះ

យអ្នកជាកពាក្យបណ្ដឹងនេះ។ ដូច្នេះដើម្បីការពារដល់ផលប្រយោជន៍ ស្របច្បាប់របស់នាងខ្ញុំ សំណូមពរ ឯកឧត្តមប្រធាន មេត្តាសម្រេចតាមការស្នើសុំ របស់នាងខ្ញុំ ដោយក្តីអនុគ្រោះ។

អាស្រ័យដូចបាន ជម្រាបជូនខាងលើសូម ឯកឧត្តមលោកប្រធាន មេត្តាពិនិត្យ និងសម្រេចតាមការស្នើសុំដូចកម្មវត្ថុ និងសំណូមពរខាងលើដោយក្តី អនុគ្រោះ។

សូម ឯកឧត្តមលោកប្រធាន មេត្តាទទួលនូវការគោរពអំពីនាងខ្ញុំ។

ធ្វើនៅ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២

**ស្នាមមេដៃស្ដាំ**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ ៖......១៨៥..........

# ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

យើង **ឈួន ទិសាល** ចៅក្រម នៃសាលាដំបូងខេត្តកណ្តាល

បានឃើញ មាត្រា ៦២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យ ប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦។

បានឃើញ សំណុំរឿងរក្សាការពារលេខ៖ ១១៣រកព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ។

ម្ចាស់បំណុលនៃបណ្តឹងតវ៉ា(កូនបំណុល)ឈ្មោះ ភេទស្រី កើតឆ្នាំ១៩៦៧ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ ឃុំ ស្រុក ខេត្តកណ្តាល កូនបំណុលនៃបណ្តឹងតវ៉ា (ម្ចាស់បំណុល) ឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៧៦ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៦ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

ដែលមានកម្មវត្ថុបណ្តឹង: **ស្នើសុំតវ៉ាដីកាសម្រេចរក្សាការពារ**

**សំអាងហេតុ**

-ដើម្បីដំណើរការនីតិវិធីបណ្តឹង និងសកម្មភាពផ្សេងៗទៀត ទៅតាមច្បាប់ទាក់ទងនឹងសំណុំរឿងក្តីខាងលើ គប្បីតម្រូវឲ្យម្ចាស់បំណុលនៃបណ្តឹងតវ៉ា(កូនបំណុល) ឈ្មោះ ថ្វ បង់ប្រាក់ចំនួន ១៥០.០០០ រៀល (ដប់ប្រាំម៉ឺនរៀលគត់) មកតុលាការ។

**ហេតុដូច្នេះសម្រេច**

បង្គាប់ឱ្យម្ចាស់បំណុលនៃបណ្តឹងតវ៉ា(កូនបំណុល) ឈ្មោះ ភេទស្រី កើតឆ្នាំ១៩៦៧ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ឃុំ ស្រុក ខេត្តកណ្តាល ឲ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធចំនួន ១៥០.០០០ រៀល (ដប់ប្រាំម៉ឺនរៀលគត់) នៅសាលាដំបូងខេត្តកណ្តាល ក្នុងរយៈពេល ០១ សប្តាហ៍ បន្ទាប់ពីថ្ងៃទទួលបានដីកានេះ ជាកំណត់ដើម្បីតុលាការចាត់ការរឿងក្តីនេះតាមច្បាប់។

ថ្ងៃ.......ខែ.......ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
កណ្តាល,ថ្ងៃទី ........ ខែ........ឆ្នាំ២០២២

**ចៅក្រម**

ឈួន ទិសាល

យើង.................................ជា...........................បានប្រគល់
ដីកាកោះនេះដល់ឈ្មោះ.............................................................
ទីលំនៅភូមិ..............ឃុំ...........ស្រុក.........ខេត្ត............នៅថ្ងៃទី....
......ខែ.........ឆ្នាំ...........ផ្ទាល់ដៃរួចហើយ ។

ធ្វើនៅថ្ងៃទី............ខែ................ឆ្នាំ២០២២

អ្នកទទួល　　　　អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧
ដីកាសម្រេចលេខ ៣៦ "ស" ដ.រ
ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧

# ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

# យើង J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា៥៥២ និងមាត្រា៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានឃើញសំណុំរឿងរក្សាការពារលេខ១០ ចុះថ្ងៃទី០២-០៣-២០១៧

-បានឃើញពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារចុះថ្ងៃទី០២-០៣-២០១៧

-បានឃើញពាក្យសុំតវ៉ាចំពោះការរក្សាការពារ ចុះថ្ងៃទី២២-០៣-២០១៧

**ម្ចាស់បំណុល** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** ៖ឈ្មោះ P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអាគារ .... ជាន់ទី.... បន្ទប់ .........ផ្លូវលេខ............ សង្កាត់........ ខណ្ឌ............. រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ ................។

**កូនបំណុល** ៖ ឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ១០ ផ្លូវលេខ៣១០ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៥ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** ៖ ឈ្មោះ B ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអាគារ .... ជាន់ទី.... បន្ទប់ .........ផ្លូវលេខ............ សង្កាត់........ ខណ្ឌ............. រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ .................។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំតវ៉ាទាមទារឲ្យតុលាការចេញ**

១.លុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ២០ "ខ" ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ

២.ប្រាក់ប្រជាប់ក្ដីជាបន្ទុករបស់កូនបំណុល

៣.ដីកាសម្រេចនេះមានអានុភាពភ្លាមៗ។

**សេចក្ដីបញ្ជាក់ដំបូង**

១.លិខិតសងប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧។ (ភស្តុតាង $Y_1$)

២.សៀវភៅធនាគាររបស់ Y។ (ភស្តុតាង $Y_2$)

## សំអាងហេតុ

១.ផ្អែកតាមភស្តុតាង $X_1$និងភស្តុតាង $X_2$ អាចឲ្យតុលាការសន្និដ្ឋានបានថាឈ្មោះ Y

២.ផ្អែកតាមភស្តុតាង $X_3$និងភស្តុតាង $X_4$ អាចឲ្យតុលាការសន្និដ្ឋានបានថា

៣.ផ្អែកតាមភស្តុតាង $X_5$ អាចឲ្យតុលាការសន្និដ្ឋានបានថា

៤.តុលាការមិនទទួលស្គាល់ការតវ៉ារបស់កូនបំណុលនោះទេ ហេតុនេះកូនបំណុល ត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្ដីទាំងស្រុង។

## សេចក្ដីសម្រេចបញ្ចប់

១.ទទួលស្គាល់ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ២០ "ខ" ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ[1]

២.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

ដីកាសម្រេចនេះអាចប្ដឹងជំទាស់បានតាមមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងអំឡុងពេល ០២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូន។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧

**ចៅក្រម**

[1] មាត្រា ៥៥៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# ឧបសម្ព័ន្ធទី៥
# ដីកាកោះ, លិខិតអញ្ជើញស្តីពីកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ,កំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ , ពាក្យសុំពន្យារពេល , លិខិតតាស់តឿនឱ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## ដីកាកោះ

យើង **ម្លូន ឌិសាល** ចៅក្រមសាលាដំបូងខេត្តកណ្ដាល

អញ្ជើញ ៖ ឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៧៦ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៦ ផ្លូវបេតុង ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ម្ចាស់បំណុល(ជាកូនបំណុលនៃបណ្ដឹងតវ៉ា) ។

| | |
|---|---|
| សញ្ញាណរឿងក្ដី និង ភាគី | សំណុំរឿងរក្សាការពារលេខ: ១១៣រកព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ការទាមទារដោយដើមចោទ ៖**ស្នើសុំតវ៉ាដីការក្សាសម្រេចរក្សាការពារ**<br>+ម្ចាស់បំណុលនៃបណ្ដឹងតវ៉ា(កូនបំណុល)ឈ្មោះ<br>+កូនបំណុលនៃបណ្ដឹងតវ៉ា (ម្ចាស់បំណុល) ឈ្មោះ |
| កាលបរិច្ឆេទ និង ទីកន្លែងដែល បង្ហាញខ្លួន | ថ្ងៃទី.០៩..... ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង .......... នាទីព្រឹក/ល្ងាច<br>☑ សាលាដំបូងខេត្តកណ្ដាល ☐ បន្ទប់សវនាការទី.....☐បន្ទប់ទី ០១ |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☐ នីតិវិធីត្រៀម ☑ ទាញហេតុផលផ្ទាល់មាត់☐ ប្រកាសសាលក្រម<br>................................................................................................ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ | ☑ ឯកសារទាក់ទងនឹងបណ្ដឹង |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃ.................ខែ...........ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

កណ្ដាល,ថ្ងៃទី..២០. ខែ..មេសា ឆ្នាំ២០២២

**ចៅក្រម**

ម្លូន ឌិសាល

យើង..................................................................ជា...................................................................

បានប្រគល់ ដីកាកោះនេះឱ្យឈ្មោះ..................................មានទីលំនៅបច្ចុប្បន្ននៅភូមិ............................

ឃុំ......................................ស្រុក............................................ខេត្ត..............................នៅថ្ងៃទី..................

ខែ..................ឆ្នាំ...................ហើយយើងបានប្រាប់ថាសាមីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី

នៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការខេត្តកណ្ដាល ។

ក្រឡាបញ្ជី និង ចុងចៅក្រម(ឈ្មោះ) អ្នកទទួល អ្នកប្រគល់

20. 4. 22

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

# លិខិតអញ្ជើញ

យើង **ឡុង ទិសាល** ចៅក្រមសាលាដំបូងខេត្តកណ្តាល

អញ្ជើញ ៖ ឈ្មោះ ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ជាកូនបំណុលនៃពាក្យសុំតវ៉ា (ម្ចាស់បំណុល) មានអាស័យដ្ឋានផ្ទះលេខ ២០៥ ផ្លូវលេខ ២៥៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជាអ្នកដាក់ពាក្យសុំតវ៉ាលើដីកាសម្រេចរក្សាការពារ ។

| | |
|---|---|
| សញ្ញាណរឿងក្តី និង ភាគី | សំណុំរឿងរក្សាការពារ លេខ: ១១៣ រកព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩<br>កម្មវត្ថុ ៖ ប្តឹងសុំតវ៉ាលើដីកាសម្រេចរក្សាការពារ<br>+ម្ចាស់បំណុលនៃពាក្យសុំតវ៉ា (កូនបំណុល) ឈ្មោះ<br>+ កូនបំណុលនៃពាក្យសុំតវ៉ា (ម្ចាស់បំណុល) ឈ្មោះ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលបង្ហាញខ្លួន | **ថ្ងៃទី.១០.. ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ០៩ ព្រឹក**<br>☑ សាលាដំបូងខេត្តកណ្តាល ☐ បន្ទប់សវនាការទី....... ☐ បន្ទប់ទី ០១ |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☑ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់<br>........................................................................................................ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ<br>( សំគាល់ដោយសញ្ញា ☑ ) | ☑ ឯកសារទាក់ទងនឹងបណ្តឹង |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥
កណ្តាល, ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២
**ចៅក្រម**

យើង.................................................................ជា........................................................... បាន ប្រគល់ ដីកាកោះនេះឱ្យឈ្មោះ....................................មានទីលំនៅបច្ចុប្បន្ននៅភូមិ.................................. ឃុំ ....................................ស្រុក........................................ខេត្ត..........................នៅថ្ងៃទី................. ខែ ................ឆ្នាំ..................ហើយយើងបានប្រាប់ថាសាមីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការខេត្តកណ្តាល ។

អ្នកទទួល អ្នកប្រគល់

ក្រឡាបញ្ជី និង ដូងកែវ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

## កំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

-សំណុំរឿងរក្សាការពារលេខ ១១៣ រកព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ។

-កាលបរិច្ឆេទ និងទីកន្លែង៖ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រាំបួនព្រឹក នៅបន្ទប់(ណ) នៃសាលាដំបូងខេត្តកណ្តាល ។

**ចៅក្រម៖ លោក ម្លូខ ទិសាល ចៅក្រមសាលាដំបូងខេត្តកណ្តាល**

**ក្រឡាបញ្ជី៖ លោកស្រី ឆឹខ ដួខកែខ ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល**

ភាគីដែលបង្ហាញខ្លួនជាអាទិ៍ ៖

**-ម្ចាស់បំណុល** ឈ្មោះ ភេទប្រុស អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ (កូនបំណុលនៃពាក្យសុំតវ៉ារក្សាការពារ) ។

**មានអ្នកតំណាងដោយអាណត្តិ** លោកស្រី ។

**-កូនបំណុល** ឈ្មោះ សាន្ត ចាន់ថូ ភេទស្រី កើតឆ្នាំ១៩៦៧ មានអាស័យដ្ឋានបច្ចុប្បន្ន ឃុំ ស្រុក ខេត្តកណ្តាល (ម្ចាស់បំណុលនៃពាក្យសុំតវ៉ារក្សាការពារ) ។

**មានអ្នកតំណាងដោយអាណត្តិ** គ្មាន ។

**កម្មវត្ថុ ៖** តវ៉ាចំពោះដីកាសម្រេចរក្សាការពារ។

-កូនបំណុល ឈ្មោះ បានថ្លែងការណ៍ថា ៖ នាងខ្ញុំសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារលេខ ០២៤ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ដោយមូលហេតុថា ដីកាសម្រេចរក្សាការពារនេះនាងខ្ញុំទើបតែបានទទួល ។ នាងខ្ញុំមានដីទំហំ១៤២១ ម៉ែត្រការ៉េ ដែលក្បាលដីមានលេខ ៣១០ ដែលមានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣១៤ ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៤ ដែលមានទីតាំងស្ថិតនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ នាងខ្ញុំបានលក់ដីឲ្យក្រុមហ៊ុនឈ្មោះ ដោយបានធ្វើកិច្ចសន្យាទូទាត់ដៃ និងកក់ប្រាក់ទិញលក់ដីចំនួន ២០០០ (ពីរពាន់) ដុល្លារអាមេរិក ក្នុង តម្លៃ ១៥ ដុល្លាអាមេរិក ក្នុង១ម៉ែត្រការ៉េ លើទំហំដីសរុប ។ ក្រោយមកមិនឃើញអ្នកទិញដីមកទាក់ទងបង់ប្រាក់តាមកិច្ចសន្យាជាមួយនាងខ្ញុំ នាងខ្ញុំក៏បានលក់ដីនេះឲ្យទៅតតិយជនតែម្តង ។

-លោកស្រី ជាមេធាវីតំណាងដោយអាណត្តិឲ្យម្ចាស់បំណុល (កូនបំណុលនៃពាក្យសុំតវ៉ា) ឈ្មោះ បានថ្លែងការណ៍ថា ៖ ក្នុងនាមកូនក្តី នាងខ្ញុំសុំតុលាការសម្រេចតម្កល់ដីកាសម្រេចរក្សាការពារលេខ ០២៤ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល ។ ដោយហេតុថា កូនក្តីនាងខ្ញុំបានទិញដីទំហំ ១៤២១ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានក្បាលដី លេខ ៣១០ ដែលមានព្រំខាងជើងជាប់នឹងក្បាលដីលេខ ៣១៤ ខាងត្បូងជាប់នឹងក្បាលដីលេខ ៣០៥ ខាងលិចជាប់នឹងក្បាលដីលេខ ៣០៩ និងខាងកើតជាប់នឹងក្បាលដីលេខ ៣០៤ ។ ដីនេះកូនបំណុលបានលក់ឲ្យកូនក្តីនាងខ្ញុំ ដោយកូនបំណុលបានទទួល

ប្រាក់កក់ទ្រនាប់ដៃពីក្ូនក្តីនាងខ្ញុំចំនួន ២,០០០ (ពីរពាន់) ដុល្លាអាមេរិក ហើយកូនបំណុលត្រូវធ្វើការផ្ទេរសិទ្ធិ និងផ្តិតមេដៃលើអក្សរ ព្រមទាំងប្រគល់ឯកសារកាន់កាប់ច្បាប់ដើមមកឲ្យកូនក្តីនាងខ្ញុំ ប៉ុន្តែក្រោយពេលកូនក្តីនាងខ្ញុំប្រគល់ប្រាក់កក់ ២,០០០ (ពីរពាន់) ដុល្លាអាមេរិករួចហើយ កូនបំណុលបែរជាមកទាមទារឲ្យកូនក្តីនាងខ្ញុំតំឡើងថ្លៃដីឲ្យគាត់ ច្រើនជាងថ្លៃដីដែលមាននៅក្នុងកិច្ចសន្យា ទើបគាត់ព្រមលក់ដីឲ្យ ។ ក្រោយពីចចារគ្នាមិនបាន កូនក្តីនាងខ្ញុំបានយកប្រាក់ទៅប្រគល់ឲ្យកូនបំណុល ក៏កូនបំណុលមិនព្រម ហើយកូនបំណុលបានអះអាងថា ឈប់លក់ដីនេះ ឲ្យកូនក្តីនាងខ្ញុំហើយ បើកូនក្តីនាងខ្ញុំព្រមឲ្យតម្លៃដីតាមការទាមទារលើសពីការកំណត់នៅក្នុងកិច្ចសន្យាទ្រនាប់ដៃកក់ប្រាក់លក់ដី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ ដោយកាលនោះកូនបំណុលលក់ដីឲ្យខ្លួនក្នុងតម្លៃ ១៥ ដុល្លាអាមេរិក ក្នុង១ម៉ែត្រការ៉េ ដោយមិនមានធ្វើការដោះស្រាយគ្នាជាមួយកូនបំណុលតទៅទៀតបាន និងបារម្ភ ថាកូនបំណុលយកដីនេះទៅលក់បន្ត ទើបកូនក្តីនាងខ្ញុំដាក់ពាក្យសុំរក្សាការពារដីនេះ មកកាន់តុលាការតែម្តង ។

-តុលាការពិនិត្យភស្តុតាង។

-តុលាការថយទៅពិចារណា និងជូនដំណឹងអំពីដីកាសម្រេចនៅពេលក្រោយ។

-តុលាការសំរេចបញ្ចប់នីតិវិធី។

-បញ្ឈប់កំណត់ហេតុនៅម៉ោង ដប់ និងសាមសិបនាទីព្រឹក ថ្ងៃខែឆ្នាំដដែល ។

| **ម្ចាស់បំណុល** | **មេធាវី** | **កូនបំណុល** | **ក្រឡាបញ្ជី** | **ចៅក្រម** |
| --- | --- | --- | --- | --- |

សាលាដំបូងខេត្តកណ្ដាល

លេខ: 807

ថ្ងៃទី 04 ខែ 05 ឆ្នាំ 20.22.

ម៉ោង 10 និង 00 នាទី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**ពាក្យសុំពន្យាពេល**

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ៨៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញជាម្ចាស់បំណុលនៅក្នុងសំណុំរឿងរក្សាការពារលេខ១១៣រកព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល។

**សូមគោរពជូន**

**លោកចៅក្រមទទួលបន្ទុករឿងក្ដីសាលាដំបូងខេត្តកណ្ដាល**

**កម្មវត្ថុ:**ស្នើសុំពន្យាពេលការទាញហេតុផលដោយផ្ទាល់មាត់។

**យោង:**ដីកាកោះចុះថ្ងៃទី២០ខែមេសាឆ្នាំ២០២២។

តបតាមកម្មវត្ថុនិងយោងខាងលើខ្ញុំសូមជំរាបលោកចៅក្រមមេត្តាជ្រាបថា: ខ្ញុំត្រូវបានលោកចៅក្រមកោះហៅចូលរួមការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី០៤ ខែឧសភាឆ្នាំ២០២២ ដោយមិនបានកំណត់ពេលវេលា ម៉្យាងទៀតដោយសារតែខ្ញុំបាទទើបបានទទួលដីកាកោះនាថ្ងៃទី០៣ខែឧសភាឆ្នាំ២០២២ ខ្ញុំមិនអាចចូលរួមការទាញហេតុផលដោយផ្ទាល់មាត់បាន ដោយសារខ្ញុំទើបទទួលបានដីកាហើយខ្ញុំពុំមានពេលវេលាសម្រាប់ពឹងពាក់មេធាវី ហេតុនេះខ្ញុំស្នើសុំអោយលោកចៅក្រមមេត្តាពន្យាពេលនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទៅពេលក្រោយដើម្បីអោយខ្ញុំមានពេលវេលាសមរម្យអាចចូលរួមនីតិធីបាន។

អាស្រ័យដូចបានជំរាបជូនខាងលើនេះ សូមលោកចៅក្រមមេត្តាពន្យាពេលនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ទៅពេលក្រោយដោយក្ដីអនុគ្រោះ។

សូមលោកចៅក្រមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ខែឧសភាឆ្នាំ២០២២

ស្នាមមេដៃ



(៤)

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លិខិតលេខ............

## លិខិតដាស់តឿនឲ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍

**យើង ........... ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ**

**មាត្រា ៤០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

**សូមជម្រាបជូន**

**ធនាគារ ABA (ADVANCED BANK OF ASIA LIMITED)**

អគារលេខ១៤៨ មហាវិថីនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

**<u>កម្មវត្ថុ</u>** ៖ សូមដាក់សេចក្តីថ្លែងការណ៍មកតុលាការក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃបានទទួលឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២០ "ខ" ដ.រ ចុះថ្ងៃទី០៩-០៣-២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយសរសេរបញ្ជាក់អំពីចំណុច ដូចខាងក្រោម ៖

ទី១ អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ប្រភេទប្រាក់ ចំនួនទឹកប្រាក់ និងខ្លឹមសារនៃសិទ្ធិលើបំណុល

ទី២ អត្ថិភាព ឬនត្ថិភាពនៃឆន្ទៈសង និងទំហំនៃការសង ឬមូលហេតុដែលមិនសង

ទី៣ បើមានសញ្ញាណនៃបុគ្គលដែលមានអាទិភាពជាងម្ចាស់បំណុលនៃការអនុវត្តចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ ប្រភេទនៃសិទ្ធិរបស់បុគ្គលនោះ និងទំហំនៃអាទិភាព

ទី៤ អត្ថិភាព ឬនត្ថិភាពនៃការរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ ដោយម្ចាស់បំណុលផ្សេងទៀត។

ប្រសិនបើ ធនាគារ ABA មិនបានធ្វើសេចក្តីថ្លែងការណ៍ តាមការដាស់តឿនដូចមានកំណត់ខាងលើ ដោយចេតនា ឬមានកំហុស ឬបានធ្វើសេចក្តីថ្លែងការណ៍ខុសពីការពិត ធនាគារ ABA ត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត ដែលបានកើតឡើង។

សេចក្តីដូចមានកំណត់ សូម **ធនាគារ** ABA សម្របសម្រួលតាមនីតិវិធីច្បាប់។

សូម **ធនាគារ** ABA ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧

**ក្រឡាបញ្ជី**

<u>ឯកសារភ្ជាប់</u>

ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២០ "ខ "ដ.រ ចុះថ្ងៃទី០៩-០៣២០១-៧ របស់សាលាដំបូងរាជធានីភ្នំពេញ

**រៀបចំដោយលោកមេធាវី អ៊ីវ ប៊ុលី**